ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# វិទ្យាសាស្ត្រ

# ជីវវិទ្យា ១០



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# ជីវវិទ្យា

## ថ្នាក់ទី ១០

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | អ្នកស្រី យិម យីហ៊ុប | អ្នកស្រី វ៉ាល់ សោរ |
| | អ្នកស្រី ហែម វ៉ាន់នី | អ្នកស្រី ហ៊ុយ ចន្ទូ |
| | អ្នកស្រី ស្រី សុម៉ាលី | លោក ឱ បុណ្ណា |
| **អ្នកវាយអត្ថបទ** | អ្នកស្រី ហាក់ ផាន្នី | |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | អ្នកស្រី ម៉ក់ វាសនា | |
| **អ្នករចនាទំព័រ** | លោក ហាក់ វណ្ណថា | |

សូមថ្លែងអំណរគុណចំពោះ
ការជួយឧបត្ថម្ភរបស់អង្គការ JICA

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៧៥៨ អយក.ប្រក. ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៧ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៨

ISBN 9-789-995-000-745

# អារម្ភកថា

សៀវភៅជីវវិទ្យាថ្នាក់ទី 10 បានចងក្រងឡើងជាជំនួយដល់សិស្សានុសិស្សផ្នែកមធ្យមសិក្សាទុតិយភូមិ ។ សារៈសំខាន់នៃសៀវភៅនេះ ផ្តល់ឱ្យសិស្សនូវចំណេះដឹងអំពីភាពប្លែកៗគ្នានៃភាវរស់នៅក្នុងធម្មជាតិ បាតុភូតផ្សេងៗដែលកើតមាននៅជុំវិញខ្លួនយើង មុខងារនៃសរីរាង្គនៅក្នុងខ្លួននិងបច្ចេកទេសផ្សេងៗដែលគេអនុវត្តក្នុងវិស័យកសិកម្មក្នុងពេលបច្ចុប្បន្ន ។

សៀវភៅជីវវិទ្យាមានទម្រង់ដូចខាងក្រោម :

- មេរៀននីមួយៗមានវត្ថុបំណងច្បាស់លាស់
- ខ្លឹមសារមេរៀនភ្ជាប់ដោយរូបភាព សង្ខេបមេរៀននិងសំណួរដែលជាជំនួយឱ្យសិស្សងាយយល់និងចងចាំមេរៀន ។
- នៅចុងបញ្ចប់របស់មេរៀននីមួយៗ មានពិសោធន៍ដែលជាសកម្មភាពបន្ថែមសម្រាប់ឱ្យសិស្សអនុវត្តដោយខ្លួនឯង ដើម្បីពង្រីកបំណិនក្នុងការសង្កេត ពិចារណា វិភាគ . . . ។
- នៅចុងជំពូកនីមួយៗមានសំណួរបញ្ចប់ជំពូកដែលជាសំណួរពង្រឹងចំណេះដឹង សំណួរត្រិះរិះវិភាគឬសន្និដ្ឋានលើខ្លឹមសារមេរៀនទាំងអស់ ។

គណៈកម្មការនិពន្ធ សូមថ្លែងអំណរគុណចំពោះអង្គការ JICA ជាពិសេសអ្នកជំនាញការជប៉ុនដែលបានជួយផ្តល់យោបល់ទាំងផ្នែកបច្ចេកទេសនិងបទពិសោធដល់អ្នកនិពន្ធ ព្រមទាំងលោកគ្រូ អ្នកគ្រូដែលបានជួយផ្តល់យោបល់និងចូលរួមក្នុងការសាកល្បង រួមទាំងគណៈកម្មការវាយតម្លៃដែលបានជួយត្រួតពិនិត្យនិងផ្តល់យោបល់លើខ្លឹមសារនៅក្នុងសៀវភៅនេះ ។

ដើម្បីជួយឱ្យសៀវភៅកាន់តែល្អប្រសើរឡើង គណៈកម្មការយើងខ្ញុំរង់ចាំទទួលការរិះគន់ការផ្តល់យោបល់និងកែលំអកំហុសឆ្គងបន្ថែមពីសំណាក់លោកគ្រូ អ្នកគ្រូនិងប្អូនសិស្សានុសិស្សដោយក្តីរីករាយ ។

**គណៈកម្មការនិពន្ធ**

# បញ្ជីអត្ថបទ

**ទំព័រ**


សេចក្តីផ្តើមជីវវិទ្យា ........ 1

**ជំពូក1 : នានាភាពនៃភាវរស់** ........ 7

1. ចំណែកថ្នាក់និងដើមឈើ មែកធាងពូជអម្បូរ ........ 8

2. វីរុសនិងបាក់តេរី ........ 14

3. ប្រូទីស ........ 20

4. ផ្សិត ........ 26

5. រុក្ខជាតិ ........ 34

6. សត្វ ........ 42

**ជំពូក2 : ឯកសណ្ឋានភាពនៃភាវរស់** ........ 57

1. កោសិកា ........ 58

2. ប្រូការីយ៉ូតនិងអឺការីយ៉ូត ........ 62

**ជំពូក3 : មេតាបូលីស** ........ 65

1. រស្មីសំយោគ ........ 66

2. ដង្ហើមកោសិកា ........ 74

**ជំពូក4 : ជីវវិទ្យាមនុស្ស** ........ 83

1. ប្រព័ន្ធគ្រោងឆ្អឹង ........ 84

2. ប្រព័ន្ធសាច់ដុំ ........ 90

**ជំពូក5 : ជីវវិទ្យាក្នុងវិស័យកសិកម្ម** ........ 97

1. ជី ........ 98

2. ការបង្កាត់ ........ 106

# សេចក្តីផ្តើម : ជីវវិទ្យា

**ចប់មេរៀននេះ សិស្សអាច**

- ▢ បង្ហាញអត្តសញ្ញាណពិសេសរបស់ភាវៈរស់
- ▢ សង្កេតវត្ថុពិសោធន៍ដោយមីក្រូទស្សន៍ ។

## 1. និយមន័យ

ជីវវិទ្យា ជាការសិក្សាអំពីភាវៈរស់ រួមមានរូបផ្គុំ នាទី ប្រភពនិងការវិវត្ត ការធ្វើចំណែកថ្នាក់ អន្តរកម្ម និងរបាយភាវៈរស់នៅលើផែនដី ។

ការសិក្សាផ្នែកជីវវិទ្យា មានសារប្រយោជន៍យ៉ាងហោចណាស់ក៏យើងអាចស្គាល់ពីខ្លួនរបស់យើងផ្ទាល់ ដូចជាសរីរាង្គផ្សេងៗនៅក្នុងរាងកាយ ការរំលាយអាហារ ដំណកដង្ហើមជាដើម ។ ក្រៅពីនេះ ជីវវិទ្យាមានទំនាក់ទំនងជាមួយនឹងវិស័យផ្សេងៗទៀតដូចជា វិស័យកសិកម្មនិងវេជ្ជសាស្ត្រ ។ អ្នកស្រាវជ្រាវខិតខំបង្កើនទិន្នផលកសិកម្ម ដោយត្រួតពិនិត្យលើការប្រើប្រាស់ជីគីមី ថ្នាំសម្លាប់សត្វល្អិតជាដើម ។ ចំពោះវិស័យវេជ្ជសាស្ត្រ អ្នកវិទ្យាសាស្ត្រប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដើម្បីបង្កើតវ៉ាក់សាំងប្រឆាំងនឹងមេរោគផ្សេងៗដែលបង្កជំងឺ ដូចជាមេរោគគ្រុនចាញ់ជាដើម ។

## 2. លក្ខណៈពិសេសនៃជីវិត

ភាវៈរស់ទាំងអស់មានលក្ខណៈពិសេសមួយចំនួន ដូចជា រូបផ្គុំ ការប្រើប្រាស់ថាមពល តំណបរំញោច ការធំធាត់ ការលូតលាស់ និងការបន្តពូជ ។

### 2.1 រូបផ្គុំ

សារពាង្គកាយទាំងអស់បង្កឡើងពីកោសិកា ។ ដូចនេះកោសិកា ជាឯកតាបង្កនៃរូបផ្គុំនិងនាទីនៅក្នុងសារពាង្គកាយ ។ យើងអាចមើលឃើញកោសិកាតូចល្អិតនេះដោយមីក្រូទស្សន៍តែប៉ុណ្ណោះ ។

សារពាង្គកាយអាចជាឯកកោសិកាឬពហុកោសិកា ។ សារពាង្គកាយឯកកោសិកាមានបាក់តេរីជាសារពាង្គកាយដែលមានចំនួនច្រើនជាងគេនៅលើផែនដី ។ សារពាង្គកាយពហុកោសិកា ជាសារពាង្គកាយដែលបង្កឡើងពីកោសិកាជាច្រើន ហើយកោសិកាទាំងនោះមាននាទីខុសៗគ្នា ។

*ឧទាហរណ៍* សារពាង្គកាយរបស់អ្នក បង្កឡើងពីកោសិកាមួយរយលានពាន់ ($10^{11}$) ។ កោសិកាយ៉ាងប្រភេទផ្សេងៗនៅក្នុងរាងកាយរបស់យើង ដូចជាកោសិកាសាច់ដុំនិងកោសិកាប្រសាទធ្វើការរួមគ្នាដើម្បីទ្រទ្រង់ជីវិតរបស់យើង ។

## 2.2 តំណបរំញោច

តើអ្នកធ្លាប់បានសំគាល់ឃើញថាដើមរុក្ខជាតិបែរទៅរកពន្លឺដែរឬទេ? រុក្ខជាតិនិងសារពាង្គកាយដទៃទៀតមានប្រតិកម្មទៅនឹងបម្រែបម្រួលនៅក្នុងបរិស្ថាន ។ បម្រែបម្រួលនៃមជ្ឈដ្ឋានជុំវិញសារពាង្គកាយដែលបណ្តាលឱ្យសារពាង្គកាយមានប្រតិកម្មហៅថា **រំញោច** ។ រំញោចមានបម្រែបម្រួល សីតុណ្ហភាព ពន្លឺ សំឡេង និងកត្តាផ្សេងៗទៀត ។ ប្រតិកម្មរបស់សារពាង្គកាយទៅនឹងរំញោចហៅថា **តំណបរំញោច** ។ *ឧទាហរណ៍* តើអ្នកធ្លាប់ភ្ញាក់នឹងស៊ីផ្លេរថយន្តដែរឬទេ ? សំឡេងជារំញោចដែលបណ្តាលឱ្យមានតំណប ។



*រូបទី 1 : តំណបរំញោច រុក្ខជាតិទៅនឹងពន្លឺ*

## 2.3 ការប្រើប្រាស់ថាមពល

កោសិការបស់សារពាង្គកាយប្រើប្រាស់ថាមពលនៅពេលដែលសារពាង្គកាយត្រូវការ ដូចជា ដំណកដង្ហើម ការកន្ត្រាក់របស់បេះដូង ការអាន ការគិត . . . ។ កោសិកាទាំងនេះធ្វើការជានិច្ចកាលនិងខ្លាំងក្លា ។ *ឧទាហរណ៍* នៅពេលយើងអាន កោសិកាភ្នែកនិងខួរក្បាលកំពុងធ្វើការ ។ កោសិកាឈាមក៏កំពុងធ្វើប្រតិកម្មគីមីយ៉ាងមមាញឹកនៅក្នុងរាងកាយរបស់យើងដែរ ។

## 2.4 ការធំធាត់និងការលូតលាស់

ភាវៈរស់អាចធំធាត់និងលូតលាស់ ។ ការធំធាត់ជាលំនាំមួយដែលសារពាង្គកាយក្លាយជាធំ ។ ការលូតលាស់ជាលំនាំនៃការផ្លាស់ប្តូរដែលកើតមាននៅក្នុងរយៈពេលនៃការរស់នៅរបស់សារពាង្គកាយ ដើម្បីបង្កើតបានជាសារពាង្គកាយមួយសាំញ៉ាំនិងពេញលេញ ។




*រូបទី 2 :ការលូតលាស់របស់មេអំបៅ*

## 2.5 ការបន្តពូជ

លក្ខណៈពិសេសមួយទៀត គឺសមត្ថភាពបន្តពូជឬការបង្កើតកូនចៅដែលមានលក្ខណៈប្រហាក់ប្រហែលនិងមេបា ។ *ឧទាហរណ៍* សត្វព្រាបពងជាស៊ុតដែលលូតលាស់បានជាកូនព្រាប ។ កូនព្រាបនេះមានលក្ខណៈស្រដៀងនឹងមេបារបស់វា ។

# 3. មីក្រូទស្សន៍

ការបង្កើតមីក្រូទស្សន៍ ធ្វើឱ្យអ្នកស្រាវជ្រាវអាចរកឃើញនិងសិក្សាអំពីកោសិកា។ មីក្រូទស្សន៍ជាឧបករណ៍មួយដែលអាចពង្រីករូបភាពនៃវត្ថុតូចឱ្យទៅជាធំបាន ។ មីក្រូទស្សន៍ដែលមានកែវពង្រីកលើសពីមួយហៅថា **មីក្រូទស្សន៍សមាស** ។

## 3.1 មីក្រូទស្សន៍សមាស

មីក្រូទស្សន៍សមាសប្រើកែវពង្រីកលើសពីមួយ ។ វាអាចពង្រីករូបភាពវត្ថុមួយបានធំជាងការប្រើមីក្រូទស្សន៍ដែលប្រើកែវពង្រីកតែមួយ ។ ដំបូងពន្លឺឆ្លងកាត់តាមវត្ថុពិសោធន៍បន្ទាប់មកឆ្លងកាត់តាមកែវពង្រីកទាំងពីរដូចបង្ហាញក្នុងរូបទី3 ។ កែវពង្រីកទីមួយស្ថិតនៅក្បែរវត្ថុពិសោធន៍សម្រាប់ពង្រីកវត្ថុនេះ ។ កែវពង្រីកនេះគេហៅថា**អុបសិចទីប** ។ កែវពង្រីកទីពីរ **អូគុយឡែ**ដែលស្ថិតនៅក្បែរភ្នែកសម្រាប់ពង្រីករូបភាពដែលបង្កើតបានដោយអុបសិចទីប ។ **សរុបការពង្រីកទាំងអស់របស់មីក្រូទស្សន៍ស្មើនិងផលគុណនៃការពង្រីករបស់អុបសិចទីបនិងការពង្រីករបស់អូគុយឡែ** ។ *ឧទាហរណ៍* សម្រាប់មីក្រូទស្សន៍គំរូជាច្រើន កែវពង្រីកអុបសិចទីប(ធំ)អាចពង្រីក40ដង ($40\times$ ) ។ អូគុយឡែអាចពង្រីកបាន10ដង ($10\times$ ) ។ ដូចនេះ សរុបការពង្រីករបស់អុបសិចទីបនិងអូគុយឡែគឺ $40\times10$ ឬ 400 ដង ។



*រូបទី3 : រូបភាពពង្រីកដោយមីក្រូទស្សន៍*

## 3.2 ផ្នែកផ្សេងៗរបស់មីក្រូទស្សន៍និងនាទីរបស់វា

1. ដៃ : សម្រាប់ទ្រទ្រង់បំពង់អូគុយឡែ ។
2. អូគុយឡែ : មានកញ្ចក់ពង្រីកសម្រាប់ឆ្លុះមើលរូបភាពពិត ។
3. បំពង់អូគុយឡែ : ស្ថិតនៅចម្ងាយសមស្របចន្លោះរវាងអូគុយឡែនិងអុបសិចទីប ។
4. ផ្ទាប់បង្វិល : ភ្ជាប់បំពង់អូគុយឡែនិងអុបសិចទីបមួយដែលមានអានុភាពពង្រីកធំនិងអុបសិចទីបមួយទៀតដែលមានអានុភាពពង្រីកតូច ។

5. **អុបសិចទីប** : កែវពង្រីកមានពីរ ។ មួយមានអានុភាពពង្រីកធំ (40× ) មួយទៀតមានអានុភាពពង្រីកតូច (10× ) ។



*រូបទី4 : មីក្រូទស្សន៍សមាស*

6. **រ៉ឺស័រ** : សម្រាប់គៀបបន្ទះកញ្ចក់ឱ្យជាប់នៅលើថាស ។
7. **ថាស** : ជាបន្ទះពណ៌ខ្មៅរាងបួនជ្រុងទ្រវែងសម្រាប់ដាក់បន្ទះកញ្ចក់ ។
8. **ដ្យាប្រាម** : សម្រាប់តម្រូវអាំងតង់ស៊ីតេពន្លឺឱ្យចូលក្នុងបំពង់អូគុយលែ ។
9. **កញ្ចក់ទេរ** : សម្រាប់ទាញពន្លឺចូលទៅក្នុងដ្យាប្រាម បន្ទះកញ្ចក់និងកែវពង្រីកអូគុយលែ ។
10. **បាត** : សម្រាប់ទ្រមីក្រូទស្សន៍ ។
11. **វីសធំ** : សម្រាប់មួលបំពង់អូគុយលែលើកឡើងនិងដាក់ចុះ ។
12. **វីសតូច** : សម្រាប់មួលសម្រួលគំហើញវត្ថុពិសោធន៍ឱ្យបានច្បាស់ ។

## មេរៀនសង្ខេប

- ជីវវិទ្យាជាការសិក្សាអំពីភាវៈរស់ ។
- ភាវៈរស់មានលក្ខណៈពិសេសមួយចំនួនដូចជា រូបធាតុ ការប្រើប្រាស់ថាមពល តំណបរំញោច ការចំធាត់ ការលូតលាស់ និងការបន្តពូជ ។
- មីក្រូទស្សន៍ ជាឧបករណ៍មួយដែលអាចពង្រីករូបភាពវត្ថុតូចឱ្យទៅជាធំបាន ។ មីក្រូទស្សន៍ដែលមានកែវពង្រីកច្រើនហៅថា មីក្រូទស្សន៍សមាស ។

## សំណួរនិងលំហាត់

1. តើភាវៈរស់មានលក្ខណៈពិសេសអ្វីខ្លះ ?
2. ចូរពន្យល់អំពីភាពខុសគ្នារវាងការចំធាត់និងការលូតលាស់ ។ ចូរឱ្យឧទាហរណ៍បញ្ជាក់ ។
3. ហេតុអ្វីបានជាភាវៈរស់ត្រូវការថាមពល ?
4. តើមីក្រូទស្សន៍អាចជួយអ្វីខ្លះដល់អ្នកវិទ្យាសាស្ត្រ ?

# ពិសោធន៍ : ការប្រើប្រាស់មីក្រូទស្សន៍

## 1. វត្ថុបំណង

សង្កេតវត្ថុពិសោធន៍ដោយមីក្រូទស្សន៍ ។

## 2. សម្ភារៈ

កន្ត្រៃ ក្រដាសកាសែតឬអក្សរពុម្ព បំពង់បន្តក់ទឹក ទឹក បន្ទះកញ្ចក់ បន្ទះកញ្ចក់ស្តើង កូនតង្កៀប មីក្រូទស្សន៍ សរសៃអំបោះពណ៌ក្រហម និងពណ៌ស ។

## 3. ដំណើរការ

### ក. របៀបទី 1

- កាត់អក្សរពុម្ពមួយ " e " ចេញពីក្រដាសកាសែត ។
- បន្តក់ទឹកមួយតំណក់ចំកណ្តាលបន្ទះកញ្ចក់ ។ ប្រើតង្កៀបចាប់យកអក្សរ " e " ដាក់ក្នុងតំណក់ទឹក ដោយយកមុខអក្សរឡើងលើ ។ ដាក់បន្ទះកញ្ចក់ស្តើងឱ្យកើតជាមុំ 45° ជាមួយបន្ទះកញ្ចក់ដែលមានដាក់អក្សរនោះ ហើយបន្ទាបវាយឺតៗគ្របពីលើតំណក់ទឹកនោះ ធ្វើយ៉ាងណាកុំឱ្យមានពពុះខ្យល់ ។ ប្រសិនបើមានត្រូវធ្វើម្តងទៀត ។
- យកបន្ទះកញ្ចក់កៀបក្រោមរ៉ឺស័រលើថាសមីក្រូទស្សន៍ ដើម្បីឱ្យតួអក្សរឈមមុខមករកយើង និងស្ថិតនៅចំប្រហោងមូលដែលនៅចំកណ្តាលថាស ។ កែសម្រួលកញ្ចក់ទេរដើម្បីឱ្យពន្លឺចាំងចំអក្សរ ។
- មើលមីក្រូទស្សន៍ពីចំហៀង ។ មួលវីសធំដើម្បីបន្ទាបអុបសិចទីបលេខតូចយឺតៗរហូតដល់ជិតបន្ទះកញ្ចក់ឬវត្ថុពិសោធន៍ ។ ពិនិត្យតាមអូគុយឡែដោយបើកភ្នែកទាំងពីរ ។ មួលដំឡើងបំពង់អូគុយឡែរហូតដល់យើងមើលឃើញអក្សរ ។
- មួលវីសតូច ដើម្បីសម្រួលគំហើញរូបភាពពិតឱ្យបានច្បាស់ ។ គូរអ្វីដែលយើងមើលឃើញ ។
- ឆ្លុះមើលតាមអូគុយឡែ ។ រំកិលបន្ទះកញ្ចក់យឺតៗទៅស្តាំឬឆ្វេងធ្វើយ៉ាងណា ឱ្យមើលវត្ថុពិសោធន៍នោះឃើញច្បាស់ ។
- បង្វិលអុបសិចទីបលេខធំនៅពីលើកន្លែងនោះ ។ យកចិត្តទុកដាក់ពិនិត្យដោយប្រើវីសតូចប៉ុណ្ណោះ ។ គូរអ្វីដែលយើងមើលឃើញ ។

ខ. របៀបទី 2



*រូបទី 5 . សរសៃអំបោះពិនិត្យដោយមីក្រូទស្សន៍*

- យកសរសៃអំបោះទាំងពីរពណ៌ដាក់ខ្វែងគ្នានៅលើបន្ទះកញ្ចក់ រួចបន្តក់ទឹក ។
- ពិនិត្យសរសៃអំបោះដោយមីក្រូទស្សន៍ ជាមួយអុបសិចទីបលេខតូច បន្ទាប់មកលេខធំ ។ ប្រៀបធៀបអ្វីដែលអ្នកបានឃើញជាមួយអុបសិចទីបទាំងពីរ ។

**4.** សន្និដ្ឋាន

ក. នៅពេលអ្នករំកិលបន្ទះកញ្ចក់ទៅឆ្វេងឬស្ដាំ តើអក្សររំកិលដូចម្ដេចដែរ ?

ខ. ជាមួយនឹងអុបសិចទីបលេខតូចនិងលេខធំ តើអ្នកឃើញមានការខុសគ្នាដូចម្ដេចខ្លះ ?

គ. តើអុបសិចទីបណាមួយដែលផ្ដល់រូបភាពពិតរបស់សរសៃអំបោះច្បាស់ជាងគេ ?

ជំពូក 1

# នានាភាពនៃភាវៈរស់




ព្រៃជាជម្រករបស់ភាវៈរស់ច្រើនប្រភេទ រួមមានចាប់តាំងពីសារពាង្គកាយតូចល្អិតរហូតដល់សារពាង្គកាយធំៗ ។ ក្នុងជំពូកនេះ អ្នកនឹងឃើញថានៅលើផែនដីយើងនេះ មានភាវៈរស់យ៉ាងច្រើនអនេកដែលមានរូបរាងប្លែកៗ ។

**មេរៀនទី 1 : ចំណែកថ្នាក់និងដើមឈើមែកធាងពូជអម្បូរ**

**មេរៀនទី 2 : វីរុសនិងបាក់តេរី**

**មេរៀនទី 3 : ប្រូទីស**

**មេរៀនទី 4 : ផ្សិត**

**មេរៀនទី 5 : រុក្ខជាតិ**

**មេរៀនទី 6 : សត្វ**

មេរៀនទី

# 1 ចំណែកថ្នាក់និងដើមឈើមែកធាងពូជអម្បូរ

**ចប់មេរៀននេះ សិស្សអាច**

- ឱ្យនិយមន័យការធ្វើចំណែកថ្នាក់
- ធ្វើអត្តសញ្ញាណការធ្វើចំណែកថ្នាក់ភាវៈរស់
- បកស្រាយទំនាក់ទំនងភាវៈរស់ក្នុងដើមឈើមែកធាងពូជអម្បូរ ។

ចូរពិនិត្យរូបភាពនៅទំព័របើកជំពូក អ្នកសង្កេតឃើញមានភាវៈរស់ច្រើនប្រភេទ ។ ប៉ុន្តែបើអ្នកសង្កេតឱ្យបានល្អិតល្អន់ អ្នកនឹងឃើញសត្វមួយចំនួនមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ទន្ទឹមនោះអ្នកក៏សង្កេតឃើញមានលក្ខណៈខុសគ្នាផងដែរ ។ អ្នកអាចរៀបភាវៈរស់ទាំងនោះជាក្រុម ដោយផ្អែកទៅលើពណ៌ ទំហំ ទ្រង់ទ្រាយឬលក្ខណៈផ្សេងទៀតដែលអ្នកបានសង្កេត ។

## 1. ចំណែកថ្នាក់ភាវៈរស់

ច្រើនពាន់ឆ្នាំកន្លងមក មនុស្សយើងទទួលស្គាល់ថានៅលើផែនដីមានភាវៈរស់រាប់លានប្រភេទ ។ សត្វមួយចំនួនមានក្រញាំនិងធ្មេញមុត ហើយដើរលើដី ។ សត្វមួយចំនួនទៀត មានស្លាបនិងចំពុះ ហើយហើរលើអាកាស ។ សត្វមួយចំនួនផ្សេងទៀត មានស្រកានិងព្រុយហើយហែលនៅក្នុងទឹក ។

ដើម្បីស្គាល់ច្បាស់ថា តើសត្វទាំងនេះមានលក្ខណៈដូចម្ដេចនិងងាយស្រួលក្នុងការហៅឈ្មោះ ជីវវិទូបានរៀបភាវៈរស់ទៅតាមក្រុមដែលហៅថា **ការធ្វើចំណែកថ្នាក់** ។ វិទ្យាសាស្ត្រនៃការធ្វើចំណែកថ្នាក់និងការហៅឈ្មោះភាវៈរស់ហៅថា **តាក់សូណូមី** ។ ចំណែកថ្នាក់ គឺជាការផ្គុំគំនិត ព័ត៌មានឬវត្ថុផ្សេងៗដោយផ្អែកលើលក្ខណៈប្រហាក់ប្រហែលគ្នារបស់វា ។

តាមចំណែកថ្នាក់ទំនើប គេចែកភាវៈរស់ជាប្រាំពីរកម្រិតសំខាន់ៗគឺ រជ្ជៈ សាខា ថ្នាក់ លំដាប់ អម្បូរ ពួក និងប្រភេទ ។ ក្រុមដែលធំជាងគេបង្អស់ហៅថា រជ្ជៈ ។ ក្រុមបន្ទាប់គឺ សាខា ។ សាខានីមួយៗកើតពីថ្នាក់ច្រើន ។ ថ្នាក់នីមួយៗមានលំដាប់ ។ លំដាប់ចែកជាអម្បូរជាច្រើនដែលមានទំនាក់ទំនងជាមួយពួក ។ ពួកនីមួយៗចែកជាច្រើនប្រភេទទៀត ។

ប្រព័ន្ធចំណែកថ្នាក់ដែលគេប្រើសព្វថ្ងៃ ចែកភាវៈរស់ជាប្រាំរជ្ជៈគឺ រជ្ជៈសត្វ រជ្ជៈរុក្ខជាតិ រជ្ជៈផ្សិត រជ្ជៈប្រូទីស និងរជ្ជៈម៉ូណេរ៉ា។




*រូបទី1.1: ចំណែកថ្នាក់ទីទុយ*

## 2. នាមខ្លីទ្វេនាមរបស់ភាវៈរស់

ពាក្យសម្រាប់សំគាល់ពួកនិងប្រភេទរបស់ភាវៈរស់នីមួយៗជាឈ្មោះវិទ្យាសាស្ត្រ ។ ឈ្មោះពួកផ្តើមដោយអក្សរធំ ឯឈ្មោះប្រភេទត្រូវផ្តើមដោយអក្សរតូច ។ *ឧទាហរណ៍* ឈ្មោះពួកនិងប្រភេទរបស់សត្វចចកគឺ កានីស លុពុស (*Canis lupus*) ។ ឈ្មោះទាំងពីរនេះជាអត្តសញ្ញាណរបស់ភាវៈរស់ ។ ទោះបីភាគច្រើនជាឈ្មោះឡាតាំង ប៉ុន្តែមួយចំនួនក៏ជាឈ្មោះក្រិកផងដែរ ។ ជីវវិទូបានប៉ាន់ស្មានឃើញថាមានភាវៈរស់ប្រមាណដប់លានប្រភេទខុសៗគ្នាដែលនៅរស់សព្វថ្ងៃនេះ ។ ភាវៈរស់ជាច្រើនត្រូវបានធ្វើអត្តសញ្ញាណនិងដាក់ឈ្មោះរួចហើយ ។ តារាងទី1 បង្ហាញពីចំណែកថ្នាក់ក្រុមសារពាង្គកាយមួយចំនួន ។ ក្រុមនីមួយៗបង្ហាញនូវលក្ខណៈពិសេសរបស់ភាវៈរស់ ។ *ឧទាហរណ៍* សត្វគោស្ថិតនៅក្នុងលំដាប់ " Carnivora " កានីវ៉ូរ៉ា(ស៊ីសាច់នៅ) ដែលជាពាក្យឡាតាំងសម្រាប់សំគាល់ស៊ីសាច់នៅជាអាហារ ។ ភាវៈរស់មួយចំនួនទៀតក៏ស្ថិតក្នុងលំដាប់នេះដែរដូចជា ឆ្កែ ចចក ខ្លាឃ្មុំជាដើម ។ ក្រឡេកមើលតារាងទី1 ម្តងទៀត ហើយកត់សំគាល់ថា សត្វគោស្ថិតក្នុងអម្បូរ ផេលីដា ( Felidae) ។

អម្បូរនេះមិនមែនមានតែតោទេ ប៉ុន្តែមានសត្វឆ្មាផ្សេងៗទៀត រួមទាំងឆ្មាដែលគេចិញ្ចឹមតាមផ្ទះផងដែរ(ឆ្មាស្រុក)។

ចំណេះដឹងនេះផ្តល់នូវគំនិតល្អមួយថា តើសត្វតោធ្វើសកម្មភាពនិងមានរូបរាងដូចម្តេច? ទោះបីជាអ្នកមិនដែលឃើញវាក៏ដោយ។ អ្នកយល់ឃើញដូចនេះ ព្រោះសត្វតោនិងឆ្មាស្រុកមិនមែនស្ថិតក្នុងពួកនិងប្រភេទដូចគ្នាទេ។ នេះបង្ហាញថា ពួកវាមានលក្ខណៈមួយចំនួនខុសគ្នា។ ***ឧទាហរណ៍*** អ្នកតាក់សូណូមីបញ្ចូលសត្វតោក្នុងពួកប៉ង់តេរ៉ា ( *Panthera* ) ជាមួយសត្វឆ្មាធំៗផ្សេងទៀត។ ឆ្មាទាំងអស់ស្ថិតក្នុងពួកប៉ង់តេរ៉ា ( *Panthera* ) គ្រហឹម។ ពួកវាមិនមែនស្ថិតក្នុងក្រុមសត្វធ្វើខុរៗទេ។ ឆ្មាផ្សេងទៀតរួមទាំងឆ្មាស្រុកស្ថិតក្នុងពួកផេលីស( *Felis* )។ វាគ្រាន់តែធ្វើខុរៗ តែវាមិនគ្រហឹមទេ។ ដូចនេះសត្វតោស្ថិតក្នុងប្រភេទឡេអូ ( *Leo* )។ ក្នុងករណីនេះសត្វតោ ប៉ង់តេរ៉ា ឡេអូ ( *Panthera leo* ) ជាសត្វដែលលោតឆ្លងកាត់កងក្នុងពេលលេងសៀកឬជាសត្វដែលដេកសណ្តូកខ្លួនយ៉ាងកម្ជិលក្នុងទ្រុងនាសួនសត្វ។ ឯផេលីស ដូមេស្ទីគុស *Felis domesticus* ជាឈ្មោះវិទ្យាសាស្ត្ររបស់សត្វឆ្មាស្រុក។

តារាងទី 1 : ចំណែកថ្នាក់សារពាង្គកាយប្រាំបែបខុសគ្នា

| | តោ | ខ្ទឹមបារាំង | ផ្សិត (ដែលបរិភោគបាន) | ប៉ារ៉ាមេស៊ី | បាក់តេរី |
|---|---|---|---|---|---|
| រជ្ជៈ Kingdom | អានីម៉ាលីយ៉ា Animalia | ប្លាន់តា Plantae | ហ្វុនហាយ Fungi | ប្រូទិសតា Protista | ម៉ូណេរ៉ា Monera |
| សាខា Phylum | គ័រដា Chordata | ត្រាកេអូភីតា Tracheophyta | បាស៊ីឌីយ៉ូមីសែត Basidiomycetes | ស៊ីលីយ៉ូផរ៉ា Ciliophora | អឺបាក់តេរីយ៉ាសា Eubacteriacea |
| ថ្នាក់ Class | ម៉ាំម៉ាលីយ៉ា Mammalia | អង់ស្យូស្ពែម Angiospermae | អូម៉ូបាស៊ីឌីយ៉ូមីសែត Homobasidiomycetes | គ្លីយ៉ាតា Cliatea | ស៊ីសូមីសែត Schizomycetes |
| លំដាប់ Order | កានីវ៉ររ៉ា Carnivora | លីលីអាល់ Liliales | អាការីកាល់ Agaricales | អ៊ីមេណូស្តូម៉ាទីដា Hymenostomatida | អឺបាក់តេរីយ៉ាល់ Eubacteriales |
| អម្បូរ Family | ផេលីដា Felidae | លីលីអាសេ Liliaceae | អាការីកាសា Agaricaceae | ប៉ារ៉ាមេស៊ីដា Paramecidae | ឡាក់តូបាស៊ីឡាសា Lactobacilaceae |
| ពួក Genus | ប៉ង់តេរ៉ា *Panthera* | អាល់លីយ៉ុម *Allium* | អាការីគុស *Agaricus* | ប៉ារ៉ាមេស៊ីយ៉ុម *Paramecium* | ឡាក់តូបាស៊ីលុស *Lactobacillus* |
| ប្រភេទ Species | ឡេអូ *leo* | សេប៉ា *cepa* | កាំប៉េស្ទ្រី *campestris* | កូដាទុម *caudatum* | ប៊ុលការីយុស *bulgarius* |

## 3. លក្ខណៈដូចនិងលក្ខណៈខុសគ្នារបស់ភាវៈរស់

ការរៀបភាវៈរស់នៅក្នុងក្រុមដូចគ្នា និងអ្វីដែលជីវវិទូបានធ្វើនៅក្នុងចំណែកថ្នាក់ ។ ជីវវិទូបានផ្គុំភាវៈរស់ដោយផ្អែកលើលក្ខណៈដូចនិងលក្ខណៈខុសគ្នារបស់ពួកវា ។

ជីវវិទូតែងតែប្រើគ្រោងឆ្អឹងសត្វជាជំនួយក្នុងការធ្វើចំណែកថ្នាក់ ។រូបទី1.2បង្ហាញពីលក្ខណៈដូចគ្នានៃទម្រង់អវយវៈផ្នែកខាងមុខរបស់សត្វដែលអាចឱ្យយើងធ្វើចំណែកថ្នាក់នៅក្នុងក្រុមជាមួយគ្នាក្នុងករណីថនិកសត្វ ។ អវយវៈមុខរបស់សត្វឆ្អឹងកង ផ្គុំឡើងដោយបណ្តុំឆ្អឹងសំខាន់ៗដូចគ្នាដែលគេហៅថា សរីរាង្គអូម៉ូឡូក ។ ទោះបីសរីរាង្គអូម៉ូឡូកទាំងនោះមានមុខងារផ្សេងគ្នាក៏ដោយ ប៉ុន្តែវាមានទម្រង់ខាងក្នុងដូចគ្នា ។ ផ្ទុយទៅវិញសត្វមួយចំនួនមានសរីរាង្គស្រដៀងគ្នាប៉ុន្តែវាវិវត្តមកពីប្រភពផ្សេងគ្នា ។




*រូបទី 1.2- សរីរាង្គអូម៉ូឡូករបស់ថនិកសត្វ*

*ឧទាហរណ៍* ស្លាបមេអំបៅនិងស្លាបបក្សីជាសរីរាង្គដែលមានលក្ខណៈស្រដៀងគ្នា ព្រោះវាអាចហើរបានដូចគ្នា ។ ប៉ុន្តែស្លាបមេអំបៅគ្មានឆ្អឹង ឯស្លាបបក្សីមានឆ្អឹង ។ ទម្រង់បែបនេះ គេហៅថា សរីរាង្គអាណាឡូក ។

## 4. ដើមឈើមែកធាងពូជអម្បូរ

ជីវវិទូបានធ្វើអត្តសញ្ញាណប្រភេទសត្វច្រើនជាង 1.5លាន រួចមកហើយ ។ ក្នុងមួយឆ្នាំៗ អ្នកវិទ្យាសាស្ត្របានរកឃើញប្រភេទថ្មីៗកាន់តែច្រើនឡើងៗ ។ ការធ្វើចំណែកថ្នាក់សត្វជួយដល់ជីវវិទូឱ្យដឹងពីភាពប្លែកៗគ្នារបស់សត្វទាំងនោះ ។ ពួកគេបានធ្វើចំណែកថ្នាក់សត្វជា35 សាខាធំៗ ។

ដើម្បីតាងទំនាក់ទំនងក្នុងចំណោមក្រុមសត្វផ្សេងៗ ជីវវិទូតែងតែប្រើដ្យាក្រាមមែកធាងដែលគេហៅថា ដើមឈើមែកធាងពូជអម្បូរ ។ ដើមឈើមែកធាងពូជអម្បូរជាប្រវត្តិនៃការវិវត្តរបស់សារពាង្គកាយមួយប្រភេទឬមួយក្រុម ។ មែកធាងនេះចង្អុលបង្ហាញថា ក្រុមសារពាង្គកាយដែលមានទំនាក់ទំនងជាមួយគ្នា វិវត្តពីបុព្វសត្វរួមនៅពេលណា ហើយក្នុងករណីមួយចំនួន តើពួកវាញែកចេញពីគ្នាយ៉ាងដូចម្តេច?

ជីវវិទូមិនបានដឹងពិតប្រាកដពីដំណើរនៃការវិវត្តដែលកើតមានឡើងទេ ។ ផ្ទុយទៅវិញពួកគាត់គ្រាន់តែសន្និដ្ឋានដោយផ្អែកលើភស្តុតាងដែលពួកគាត់រកឃើញតែប៉ុណ្ណោះ ។ ជីវវិទូបានបង្កើតសម្មតិកម្ម " គ្រប់សត្វទាំងអស់កើតឡើងពីបុព្វសត្វឯកកោសិកា " ។ សត្វទាំងឡាយត្រូវបានធ្វើចំណែកថ្នាក់ដោយផ្អែកលើថា តើសត្វទាំងនោះមានទំនាក់ទំនងរវាងគ្នានិងគ្នាយ៉ាងដូចម្តេច ? ទំនាក់ទំនងនេះត្រូវបានកំណត់ដោយរូបធាតុរបស់រាងកាយសត្វ



*រូបទី13 : ដើមឈើមែកធាងពូជអម្បូរ*

របៀបលូតលាស់របស់សត្វនិងសម្ភារៈតំណពូជ ( ADN )របស់វា ។ សម្ភារៈតំណពូជជាធាតុគីមីក្នុងកោសិកាដែលកំណត់លក្ខណៈតំណពូជនៃភាវៈរស់នីមួយៗ ។

## មេរៀនសង្ខេប

- ការធ្វើចំណែកថ្នាក់មានន័យថា ការផ្តុំគំនិត ព័ត៌មានឬវត្ថុផ្សេងៗដោយផ្អែកលើភាពប្រហាក់ប្រហែលគ្នា ។ ភាវៈរស់ទាំងឡាយត្រូវបានបែងចែកជា រជ្ជៈ សាខា ថ្នាក់ លំដាប់ អម្បូរ ពួក និងប្រភេទ ។ រជ្ជៈទាំងប្រាំរបស់ភាវៈរស់មាន ម៉ូណេរ៉ា ប្រូទីស ផ្សិត រុក្ខជាតិ និងសត្វ ។
- នាមវល្លិទ្វេនាមឬឈ្មោះវិទ្យាសាស្ត្ររបស់ភាវៈរស់ត្រូវបានសំគាល់ដោយឈ្មោះរបស់ពួកនិងឈ្មោះប្រភេទ ។
- ដើមឈើមែកធាងពូជអម្បូរ ជាប្រវត្តិនៃការវិវត្តរបស់សារពាង្គកាយមួយប្រភេទឬមួយក្រុម ។

## ? សំណួរនិងលំហាត់

1. ដូចម្តេចដែលហៅថាចំណែកថ្នាក់ ?
2. ហេតុអ្វីបានជាអ្នកវិទ្យាសាស្ត្រធ្វើចំណែកថ្នាក់ ?
3. តើនាមវល្លិទ្វេនាមគឺជាអ្វី ?
4. តើភាវៈរស់ចែកចេញជាប៉ុន្មានកម្រិតសំខាន់ៗ ? អ្វីខ្លះ ?

# ពិសោធន៍ : ការធ្វើចំណែកថ្នាក់ស្លឹក

ស្លឹករុក្ខជាតិមានលក្ខណៈពិសេសមួយចំនួនគួរឱ្យកត់សំគាល់ដូចជាៈ




**1.** វត្ថុបំណង : បង្ហាញពីរបៀបធ្វើចំណែកថ្នាក់ស្លឹករុក្ខជាតិ ។

**2.** សម្ភារៈ : ស្លឹករុក្ខជាតិស្រស់ 10ប្រភេទ (តាមដែលអាចរកបាន)ក្រដាសផ្ទាំងធំ ជ័រកាវ ហ្វឺត ។

**3.** ដំណើរការ

- សង្កេតស្លឹករុក្ខជាតិម្តងមួយៗយ៉ាងយកចិត្តទុកដាក់ ដោយពិនិត្យលើលក្ខណៈប្រហាក់ប្រហែលគ្នា ផ្អែកទម្រង់ស្លឹក ការតម្រៀបរបស់ស្លឹក ទ្រនុងស្លឹក និងគែមស្លឹកជាដើម ។
- ចែកស្លឹករុក្ខជាតិជាពីរក្រុម ដោយផ្អែកលើលក្ខណៈពិសេសរបស់វា (យ៉ាងហោចណាស់លក្ខណៈមួយដូចគ្នា) ។
- គូរដ្យាក្រាមហើយធ្វើកំណត់ត្រាពីចំណែកថ្នាក់នៅលើនោះ ។ បិទស្លឹករុក្ខជាតិដោយកាវក្បែរការពណ៌នារបស់វា ។
- ពិនិត្យមើលលក្ខណៈផ្សេងៗទៀតដែលអាចជួយអ្នកឱ្យចែកស្លឹករុក្ខជាតិជាក្រុមតូចៗបន្តទៀត ។ ពណ៌នាលក្ខណៈ ពិសេសនៃក្រុមតូចៗទាំងនេះក្នុងដ្យាក្រាម ហើយបិទស្លឹករុក្ខជាតិនៅខាងក្រោមការពណ៌នានេះ ។ បន្តការពណ៌នាពីលក្ខណៈពិសេសថ្មីៗផ្សេងទៀតនិងបិទស្លឹករុក្ខជាតិរហូតដល់ក្រុមនីមួយៗនៅសល់ស្លឹកតែមួយ ។

**4.** សន្និដ្ឋាន

ពិនិត្យមើលដ្យាក្រាមស្លឹករុក្ខជាតិរបស់មិត្តរួមថ្នាក់ ។ ពិភាក្សាលើក្រុម លក្ខណៈដែលអ្នកគិតថាប្រសើរបំផុត ។

មេរៀនទី

# 2 វីរុសនិងបាក់តេរី

ចប់មេរៀននេះ សិស្សអាច

- ❒ បង្ហាញពីរូបផ្គុំរបស់វីរុសនិងបាក់តេរី
- ❒ ពន្យល់ពីរបៀបបន្តពូជរបស់វីរុសនិងបាក់តេរី
- ❒ ឱ្យឧទាហរណ៍បាក់តេរីមានប្រយោជន៍និងបាក់តេរីចង្រៃ ។

នៅក្នុងធម្មជាតិមានភាវៈរស់រាប់លានប្រភេទដែលមានទំហំនិងរូបរាងខុសៗគ្នា ។ ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រនិងមីក្រូទស្សន៍ បានបង្ហាញឱ្យពិភពលោកឃើញនូវសារពាង្គកាយតូចល្អិតជាច្រើន ដែលហៅថា **មីក្រូសារពាង្គកាយ** ។ ភាវៈរស់ទាំងនេះស្ថិតនៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងធម្មជាតិ ។

## 1. វីរុស

**វីរុស** ជាភាគតូចល្អិតបំផុតដែលស្ថិតនៅចន្លោះភាវៈមានជីវិតនិងភាវៈគ្មានជីវិត ។ វាជ្រៀតចូលទៅក្នុងកោសិការស់ហើយបន្តពូជ ។ វីរុសមិនមែនជាកោសិកាទេ វាគ្មានលក្ខណៈជាសារពាង្គកាយទេ ព្រោះវាគ្មានធាតុកោសិកាអ្វីទាំងអស់សម្រាប់ចិញ្ចឹមជីវិតនិងការលូតលាស់របស់វា ។ លក្ខណៈមួយដែលប្រដូចវីរុសទៅនឹងសារពាង្គកាយ គឺវាអាចបន្តពូជបាន ហើយបន្តពូជបានតែនៅក្នុងកោសិកាមានជីវិតប៉ុណ្ណោះ ។

### 1.1 រូបផ្គុំ

វីរុសតូចជាងកោសិកា។ វាមានរូបរាងនិងទំហំខុសៗគ្នា។ វីរុសខ្លះមានរាងមូលនិងខ្លះទៀតមានរាងកូនដំបងឬសរសៃជាដើម ។ វីរុសខ្លះមានរាងស្មុគ្រស្មាញ ដូចជា បាក់តេរីយ៉ូផាស ។ បាក់តេរីយ៉ូផាសជាវីរុសដែលបង្កជំងឺដល់បាក់តេរី ។




*រូបទី2.1 រូបរាងផ្សេងៗរបស់វីរុស*

ថ្វីបើវីរុសមានរូបរាងខុសៗគ្នា ប៉ុន្តែគ្រប់វីរុសទាំងអស់មានរូបផ្តុំប្រហែលគ្នា ។ វាបង្កឡើងពីផ្នែកពីរសំខាន់ គឺស្រោមខាងក្រៅជា **ប្រូតេអ៊ីន** សម្រាប់ការពារនិងស្នូលខាងក្នុងជាសម្ភារៈតំណពូជសម្រាប់បង្កើតវីរុសថ្មីៗទៀត ។

## 1.2 ការបន្តពូជ




*រូបទី 2.2 វដ្តបន្តពូជរបស់វីរុស*

បញ្ជាក់: បាក់តេរីយ៉ូផាសជាប្រភេទមួយរបស់វីរុស ។ គ្រប់វីរុសទាំងអស់មានការបន្តពូជដូចខាងលើ ។

## 1.3 វីរុសនិងជំងឺ

វីរុសបង្កជំងឺ ។ វីរុសខ្លះបង្កជំងឺយ៉ាងធ្ងន់ធ្ងរដល់រាងកាយដូចជា ជំងឺអេដស៍ ។ វីរុសខ្លះទៀតបង្កជំងឺក្នុងរយៈពេលខ្លី ហើយឆាប់ជាសះស្បើយ ដូចជា ជំងឺគ្រុនផ្តាសាយ ។ តើវីរុសផ្តាសាយបង្កជំងឺយ៉ាងដូចម្តេច ?

ពេលចូលតាមច្រមុះនិងមាត់ វីរុសផ្តាសាយបានទៅរាតត្បាតលើកោសិកាបំពង់កឬវាធ្វើដំណើរឆ្លងកាត់ផ្លូវដង្ហើម ។ ពេលទៅដល់កោសិកាណាមួយ វានឹងចូលក្នុងកោសិកានោះហើយបំផ្លាញដោយបង្កើតវីរុសថ្មីៗទៀតជាច្រើន ។

វីរុសអាចបង្កជំងឺដល់រុក្ខជាតិនិងសត្វចិញ្ចឹមមាន ឆ្កែនិងឆ្មា។ *ឧទាហរណ៍* ដើមប៉ោមរាតត្បាតដោយវីរុសម៉ូសាអ៊ិចដែលធ្វើឱ្យវាមានផ្លែតិច ។ ឆ្កែនិងឆ្មាអាចស្លាប់ដោយសារជំងឺដែលបណ្តាលពីវីរុស ដូចជា ជំងឺឆ្កែឆ្កួតជាដើម ។

| ជំងឺ | របៀបឆ្លង | រោគសញ្ញា |
|---|---|---|
| កញ្ជ្រិល | ចរន្តខ្យល់ | កន្ទួលក្រហមលើស្បែក ឡើងកម្តៅ តឹងច្រមុះ និងឈឺបំពង់ក ។ |
| អុតស្វាយ | ចរន្តខ្យល់ | គ្រុន ស្នាមកន្ទួលលើស្បែក ។ |
| ស្រឡទែន | ចរន្តខ្យល់ | ហើមក្រពេញទឹកមាត់ ។ |
| គ្រុនផ្តាសាយធំ | ចរន្តខ្យល់ | គ្រុន ឈឺក្បាល ឈឺសាច់ដុំ ឈឺបំពង់ក ក្អក ហៀរសំបោរ ។ |
| រលាកថ្លើម | ឈាម ចំណីអាហារ ទឹក ការរួមភេទ | គ្រុន គ្រុនរងា ចង្អោរ ហើមថ្លើម ស្បែកលឿង ឈឺសន្លាក់ ។ |
| គ្រុនស្វិតដៃជើង | ចំណីអាហារ ទឹក | ឈឺក្បាល តឹងកញ្ចឹងក សាច់ដុំកម្រើកលែងបាន ។ |
| អេដស៍ | ការរួមភេទ ការប្រើម្ជុលចាក់ថ្នាំរួមគ្នា ឆ្លងពីម្តាយទៅកូន | ប្រព័ន្ធស៊ាំចុះខ្សោយ មានប្រជុំរោគសញ្ញានៃជំងឺឱកាសនិយមផ្សេងៗ ហើយបណ្តាលឱ្យស្លាប់ ។ |
| ផ្តាសាយបក្សី | បក្សីមានជំងឺឬងាប់ កាកសំណល់របស់បក្សីឈឺឬងាប់ កន្លែងចិញ្ចឹមបក្សី សាច់បក្សីចម្អិនមិនឆ្អិនល្អ បឹងឬត្រពាំងមានបក្សីហែល ... | ឈឺក្បាល ឈឺសាច់ដុំ ថប់ដង្ហើម ក្តៅលើសពី 38°C (ក្រោយពីការប៉ះពាល់បក្សីឈឺឬងាប់រយៈពេល7ថ្ងៃ) ។ |

## 2. បាក់តេរី

នៅក្នុងអំឡុងចុងឆ្នាំ1600 តាមរយៈមីក្រូទស្សន៍របស់លោក ឡេ វ៉ាន់ហ៊ុក (Anton van Leeuwenhock)បានមើលឃើញនៅក្នុងកម្ទេចកំទីដែលគាត់បានកោសចេញពីជើងធ្មេញរបស់គាត់នូវសារពាង្គកាយខ្លះមានរាងដូចដង្កូវឆ្មារៗ ។ តែគាត់មិនអាចមើលឃើញផ្នែកខាងក្នុងរបស់វាទេ ។

## 2.1 រូបផ្គុំ

ក្រោយមកតាមរយៈមីក្រូទស្សន៍ទំនើបរបស់គាត់ ឡេវ៉ាន់ហ៊ុក បានឃើញរូបផ្គុំលំអិតរបស់សារពាង្គកាយឯកកោសិកានេះគឺ **បាក់តេរី** ។ វាជាឯកកោសិកា ប្រូការីយ៉ូត ។ ធាតុកោសិកាមានតែរីបូសូមទេ ។ វាគ្មានណ្វៃយ៉ូទេ សម្ភារៈតំណពូជ(ADN )ស្ថិតនៅផ្គុំគ្នាត្រង់ផ្នែកកណ្តាលរបស់កោសិកា ។




*រូបទី2.3 បាក់តេរី*

កោសិកាបាក់តេរីខ្លះមានផ្លាសែលដែលជួយឱ្យកោសិកាផ្លាស់ទីបាន ។ វាអាចមានផ្លាសែលមួយ ច្រើន ឬគ្មាន ។ បាក់តេរីគ្មានផ្លាសែល ផ្លាស់ទីតាមរយៈខ្យល់ ចរន្តទឹក វត្ថុផ្សេងៗឬមធ្យោបាយផ្សេងទៀត ។ បាក់តេរីភាគច្រើន ជាបរជីពដែលមានរបៀបចិញ្ចឹមជីវិតរបស់វាជា សាប្រូភីតឬបរាសិត ។ បាក់តេរីខ្លះទៀតជាស្វ័យជីព ។

បាក់តេរីមានទំហំតូច ។ បាក់តេរីដែលមានទំហំមធ្យម មានអង្កត់ផ្ចិតប្រហែល 2μm ។ ផ្អែកតាមរូបរាងរបស់បាក់តេរី គេចែកវាជាបីក្រុមគឺ បាក់តេរីមានរាងដំបងហៅថា បាស៊ី រាងស្វ៊ែហៅថា កុកស៊ី និងរាងស្ពៀហៅថា ស្ពៀរីឡូម ។

## 2.2 ការបន្តពូជ

ក្នុងមជ្ឈដ្ឋានដែលមានអាហារគ្រប់គ្រាន់ សីតុណ្ហភាពនិងកត្តាផ្សេងទៀតសមស្រប វាអាចកើនចំនួនយ៉ាងរហ័ស ។ បាក់តេរីខ្លះទៀតកើនចំនួនមួយជាពីរដងរៀងរាល់ 20នាទីម្តង ។ ការបន្តពូជរបស់វាប្រព្រឹត្តទៅដោយភេទនិងដោយឥតភេទ ។

### ក. ការបន្តពូជដោយឥតភេទ

បាក់តេរីបន្តពូជដោយបំបែកខ្លួនជាពីរ ។ កោសិកា មេមួយចែកខ្លួនបានជាកោសិកាកូនពីរដែលកោសិកាកូននីមួយៗដូចគ្នាបេះបិទនឹងកោសិកាមេ ។



*រូបទី2.4 ការបន្តពូជដោយឥតភេទរបស់បាក់តេរី*

### ខ. ការបន្តពូជដោយភេទ

បាក់តេរីខ្លះបន្តពូជដោយភេទ ។ ក្នុងការបន្តពូជដោយភេទ មេបាទាំងពីរបន្សំនូវសម្ភារៈតំណពូជចូលគ្នា ដើម្បីបង្កើតសារពាង្គកាយមួយថ្មីដែលមានលក្ខណៈខុសពីមេបាទាំងពីរ ។ លំនាំនេះហៅថាជំនាប់ប្តូរដែលបាក់តេរីមួយផ្ទេរសម្ភារៈតំណពូជខ្លះទៅឱ្យបាក់តេរីមួយផ្សេងទៀត តាមស្ពានចម្លង ។ បន្ទាប់ពីផ្ទេរហើយ កោសិកាទាំងពីរផ្តាច់ចេញពីគ្នា ។ លទ្ធផលនៃជំនាប់ប្តូរមិនបានបង្កើនចំនួនកោសិកាបាក់តេរីទេ ។




*រូបទី2.5 ការបន្តពូជដោយភេទឬជំនាប់ប្តូរ*

## 2.3 បាក់តេរីមានប្រយោជន៍និងបាក់តេរីចង្រៃ

### ក. បាក់តេរីមានប្រយោជន៍

- បាក់តេរីបំបែកកាកសំណល់អាហារក្នុងពោះវៀនមនុស្ស
- បាក់តេរីដែលប្រើប្រាស់ក្នុងផ្នែកឧស្សាហកម្មផលិតអាហារដូចជា ទឹកដោះគោជូរ ប៊ឺរ ប្រូម៉ាស ទឹកខ្មេះ . . . ។ បាក់តេរីផលិតអង់ទីប្យូទិចសំខាន់ៗ ដូចជា ស្រ្តិបតូមីស៊ីន អេរីត្រូមីស៊ីន . . . ។
- បាក់តេរីសាប្រូភីតបំបែកសាកសពសត្វឬរុក្ខជាតិឱ្យទៅជាសារធាតុសំខាន់សម្រាប់ជីមានជីជាតិ
- បាក់តេរីភ្ជាប់អាសូតដែលមាននៅក្នុងកំពកឫសដើមសណ្តែក
- បាក់តេរីស្វ័យជីពដែលប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យដើម្បីផលិតអាហារ ហើយបញ្ចេញអុកស៊ីសែនទៅក្នុងបរិយាកាស ។

### ខ. បាក់តេរីចង្រៃ

- បាក់តេរីបង្កជំងឺឆ្លងចំពោះមនុស្ស សត្វ និងរុក្ខជាតិ ។ *ឧទាហរណ៍* ជំងឺរាគ ជំងឺកាមរោគ ជំងឺរបេងជាដើម ។
- បាក់តេរីផលិតជាតុពុលនៅក្នុងអាហារដែលធ្វើឱ្យអាហារមានក្លិនជូរ ។ ប្រសិនបើយើងបរិភោគនឹងបណ្តាលឱ្យឈឺ ។ វិធីពីរបែបដែលជួយបន្ថយល្បឿនកុំឱ្យអាហារឆាប់ផ្អូមគឺការដាក់អាហារក្នុងទូរទឹកកកឬទូរក្លាសេនិងការកម្តៅម្ហូប ។

## មេរៀនសង្ខេប

- លក្ខណៈមួយដែលប្រដូចវីរុសទៅនឹងសារពាង្គកាយគឺ វាអាចបន្តពូជបាន ។
- គ្រប់វីរុសទាំងអស់បង្កឡើងពីផ្នែកពីរសំខាន់គឺ ស្រោមខាងក្រៅ ជាប្រូតេអ៊ីនសម្រាប់ការពារវីរុសនិងស្នូលខាងក្នុងជាសម្ភារៈតំណពូជ ។
- វីរុសបញ្ជូនសម្ភារៈតំណពូជទៅក្នុងកោសិកាផ្ទុល ។ បន្ទាប់មកសម្ភារៈតំណពូជនិងប្រូតេអ៊ីនរបស់វីរុសដែលសំយោគនៅក្នុងកោសិកាផ្ទុល ផ្គុំបានជាវីរុសថ្មីៗ ។
- ជំងឺផ្សេងៗដែលបង្កដោយវីរុសមាន ជំងឺផ្តាសាយ កញ្ជ្រិល ស្រឡទែន អេដស៍ជាដើម ។
- បាក់តេរី ជាឯកកោសិកាប្រូការីយ៉ូតដែលគ្មានណ្វៃយ៉ូពិតប្រាកដ ។
- បាក់តេរីចែកជាបីក្រុមតាមរូបរាងគឺ កុកស៊ី បាស៊ី និងស្ពៀរីឡូម ។
- បាក់តេរីខ្លះបន្តពូជដោយឥតភេទ ខ្លះទៀតបន្តពូជដោយភេទគឺ ជំនាប់ប្តូរ ។ ក្នុងលំនាំនេះបាក់តេរីមួយផ្ទេរសម្ភារៈតំណពូជ ខ្លះឱ្យទៅបាក់តេរីមួយផ្សេងទៀត ។
- បាក់តេរីភាគច្រើនជាភ្នាក់ងារបង្កជំងឺដល់មនុស្ស សត្វ និងរុក្ខជាតិ ។ បាក់តេរីខ្លះទៀតផ្តល់ប្រយោជន៍យ៉ាងសំខាន់សម្រាប់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ។

## សំណួរនិងលំហាត់

1. តើវីរុសគឺជាអ្វី ?
2. តើផ្នែកសំខាន់ពីររបស់វីរុសគឺអ្វីខ្លះ ?
3. ចូររៀបរាប់ពីរបៀបបន្តពូជរបស់វីរុស ។
4. តើបាក់តេរីជាអ្វី ?
5. តើរូបរាងបីបែបសំខាន់របស់បាក់តេរីគឺអ្វីខ្លះ ?
6. តើបាក់តេរីបន្តពូជដូចម្តេច ?
7. ចូររៀបរាប់ពីបាក់តេរីមានប្រយោជន៍និងបាក់តេរីចង្រៃ ។

មេរៀនទី

# 3 ប្រូទីស

**ចប់មេរៀននេះ សិស្សអាច**

- ធ្វើអត្តសញ្ញាណអំពីលក្ខណៈពិសេសរបស់ប្រូទីសទាំងបីក្រុម
- ឱ្យឧទាហរណ៍ពីប្រូទីសដែលបង្កជំងឺដល់មនុស្ស
- ឱ្យឧទាហរណ៍បាក់តេរីមានប្រយោជន៍និងបាក់តេរីចង្រៃ
- ពណ៌នាពីរបៀបចម្លងនិងរបៀបការពារជំងឺរាកមូល គ្រុនចាញ់
- ប្រៀបធៀបប្រូទីសសត្វនិងប្រូទីសរុក្ខជាតិ ។

អ្នកវិទ្យាសាស្ត្រចែកភាវៈរស់ជាប្រាំរជ្ជៈ ។ ប្រូទីសជារជ្ជៈមួយក្នុងចំណោមរជ្ជៈទាំងប្រាំ ។ ប្រូទីសជាសារពាង្គកាយឯកកោសិកាឬពហុកោសិកាអឺការីយ៉ូត ។ គេចែកប្រូទីសជាបីក្រុមគឺ ប្រូទីសសត្វ ប្រូទីសរុក្ខជាតិ និងប្រូទីសផ្សិត ។

## 1. ប្រូទីសសត្វ

ប្រូទីសសត្វ ជាប្រូតូសូអ៊ែ ឯកកោសិកា បរជីព ។ វារស់នៅក្នុងទឹកសាប ទឹកប្រៃ ក្នុងដី ឬក្នុងសារពាង្គកាយផ្សេងទៀត ។ គេចែកប្រូទីសសត្វជាបួនក្រុមទៅតាមរបៀបរស់នៅនិងរបៀបផ្លាស់ទី ។

### 1.1 ប្រូតូសូអ៊ែផ្លាស់ទីដោយជើងបញ្ឆោត : អាមីប




ក. រូបផ្គុំអាមីប ខ. ការបន្តពូជរបស់អាមីប

រូបទី3.1 អាមីប

អាមីបប្រើជើងបញ្ឆោត សម្រាប់ផ្លាស់ទីនិងចាប់យកអាហារ ។វាបន្តពូជដោយឥតភេទគឺកោសិកាមេមួយចែកខ្លួនបានជាកោសិកាកូនពីរ ។ អាមីបមានរូបរាងមិនកំណត់ ហើយវាជាសារពាង្គកាយឯកកោសិកាដែលរស់នៅក្នុងកន្លែងមិនស្អាតដូចជា ដីភក់ ទឹកកខ្វក់ជាដើម ។ វាអាចរស់នៅជាបរាសិតក្នុង

ពោះវៀនមនុស្ស ហើយបង្កជំងឺរាកមួល ។ អាមីបរស់នៅក្នុងទម្រង់ជាគីសដែលជួយឱ្យវាធន់និងលក្ខខណ្ឌមិនសមស្រប (សីតុណ្ហភាពខ្ពស់ មជ្ឈដ្ឋានអាស៊ីត ឬបាស . . .) ដោយផ្អាកសកម្មភាពក្នុងរយៈពេលដ៏យូរ ។ គីស ត្រូវបានបញ្ចេញមកក្រៅសារពាង្គកាយតាមលាមក ។ មនុស្សឆ្លងជំងឺនេះ កាលណាគេបរិភោគអាហារឬផឹកទឹកដែលមានគីស ។

## 1.2 ប្រូតូស្វូអ៊ែផ្លាស់ទីដោយរោមញ័រ : ប៉ារ៉ាមេស៊ី

ប៉ារ៉ាមេស៊ី ជាប្រភេទទីពីរនៃប្រូតូស្វូអ៊ែដែលខ្លួនវារុំព័ទ្ធទៅដោយរោមញ័រ ។ វាប្រើរោមញ័រនេះសម្រាប់ធ្វើចលនានិងបញ្ចូលអាហារក្នុងមាត់ ។ តាមធម្មតាប៉ារ៉ាមេស៊ីបន្តពូជដោយឥតភេទ ដោយការចែកខ្លួនវាជាពីរ ។ ពេលខ្លះវាបន្តពូជដោយភេទតាមដំណើរជំនាប់ប្តូរ ។ ប៉ារ៉ាមេស៊ី រស់ក្នុងទឹកសាបនិងទឹកប្រៃ ។



*រូបទី3.2 រូបផ្ដុំប៉ារ៉ាមេស៊ី*

## 1.3 ប្រូតូស្វូអ៊ែផ្លាស់ទីដោយផ្លាសែល

ប្រូតូស្វូអ៊ែប្រភេទនេះមានផ្លាសែលមួយឬច្រើន ។ វាប្រើប្រាស់ផ្លាសែលសម្រាប់ធ្វើចលនា ។ ប្រូតូស្វូអ៊ែខ្លះមានប្រយោជន៍ ។ *ឧទាហរណ៍* ប្រូតូស្វូអ៊ែបរាសិតលើពោះវៀនសត្វកណ្តៀរ ។ វាជួយបំបែកឈើដែលកណ្តៀរស៊ីឱ្យទៅជាម៉ូលេគុលស្ករសម្រាប់ខ្លួនវានិងកណ្តៀរ ។ ប្រូតូស្វូអ៊ែខ្លះទៀតចង្រៃ ។ *ឧទាហរណ៍* សាឌីយ៉ា (Giardia) រស់នៅក្នុងទឹកសាបដូចជា ទឹកជ្រោះ ទន្លេ បឹង ។ នៅពេលមនុស្សផឹកទឹកមិនស្អាត វាភ្ជាប់ខ្លួននឹងពោះវៀន ដោយចិញ្ចឹមជីវិតនិងបន្តពូជនៅទីនោះ ។ នៅពេលនោះ មនុស្សអាចមានជំងឺពោះវៀនយ៉ាងធ្ងន់ធ្ងរហៅថាឡាំប្លីយ៉ាស ( *LAMBLIASE* ) ។


*រូបទី3.3 សាឌីយ៉ា*

## 1.4 ប្រូតូស្វូអ៊ែបន្តពូជតាមរយៈស្ប៉ រ : ស្ប៉ូរ៉ូស្វូអ៊ែ

ស្ប៉ូរ៉ូស្វូអ៊ែ ជាប្រភេទប្រូទីសសត្វដែលរស់នៅជាបរាសិតលើសត្វនិងមនុស្ស ។ ការបន្តពូជរបស់វាធ្វើឡើងតាមរយៈស្ប៉ ។ *ឧទាហរណ៍* ប្លាស្មូដ្យូមជាប្រភេទស្ប៉ូរ៉ូស្វូអ៊ែដែលបង្កជំងឺគ្រុនចាញ់ដល់មនុស្ស ។ បរាសិតនេះឆ្លងមកមនុស្សតាមរយៈមូសដែកគោលញី ។ ខាងក្រោមនេះជាវដ្តជីវិតរបស់ប្លាស្មូដ្យូមនិងដំណាក់កាលផ្សេងៗនៃការបន្តពូជរបស់វា ។ វដ្តជីវិតរបស់ប្លាស្មូដ្យូមពឹងពាក់លើមជ្ឈដ្ឋានពីរគឺ:

- ក្នុងបំពង់អាហាររបស់មូស ក្រោយពេលវាបឺតឈាមអ្នកឈឺ :

កាម៉ែត(ស្ប៉ូ) → ស៊ុតបង្កកំណើត → គីស(ផ្ទុកស្ប៉ូជាច្រើន) → គីសផ្ទុះបែកបញ្ចេញស្ប៉ូ → ស្ប៉ូចូលក្នុងក្រពេញទឹកមាត់មូស ។

- ក្នុងខ្លួនអ្នកជាដែលត្រូវមូសចម្លងរោគដោយខាំ :

ស្ប៉ូចូលតាមឈាម → ថ្លើម(ស្ប៉ូបន្តពូជ) → គោលិកាក្រហម(ស្ប៉ូបន្តពូជ) →

គោលិកាក្រហមផ្ទុះបញ្ចេញស្ប៉ូ → ផ្ដើមវដ្តថ្មីក្នុងខ្លួនមូសផ្សេងទៀត<br>
→ ទៅបំផ្លាញគោលិកាក្រហមផ្សេងទៀត




*រូបទី3.4 វដ្តជីវិតរបស់ប្លាស្មូដ្យូម*

ប្លាស្មូដ្យូមបំផ្លាញគោលិកាក្រហម ដោយបញ្ចេញជាតិពុលនិងកាកសំណល់ទៅក្នុងឈាមដែលធ្វើឱ្យមានចំណាប់គ្រុននិងរោគសញ្ញាផ្សេងៗនៃជំងឺគ្រុនចាញ់ ។

គ្រុនចាញ់ជាជំងឺដ៏សាហាវមួយអាចបង្កគ្រោះថ្នាក់ដល់ស្លាប់ ។ គេអាចព្យាបាលជំងឺនេះដោយប្រើថ្នាំ ប៉ុន្តែប្រការដែលសំខាន់ជាងនេះគឺ ត្រូវបំផ្លាញជម្រកមូសនិងដេកក្នុងមុង ។

## 2. ប្រូទីសរុក្ខជាតិ

ប្រូទីសរុក្ខជាតិភាគច្រើនជាសារាយ ។ វាជាភាវៈរស់ស្វ័យជីពដែលអាចធ្វើរស្មីសំយោគ ។ ប្រូទីសខ្លះជាសារពាង្គកាយឯកកោសិកាដែលមានផ្លាសែល ខ្លះទៀតជាសារពាង្គកាយពហុកោសិកា ។ ប្រូទីសរុក្ខជាតិមាន អឺគ្លែន ឌីយ៉ាតូមេ និងសារាយ ។

### 2.1 អឺគ្លែន



រូបទី3.5 រូបផ្គុំអឺគ្លែន

អឺគ្លែនជាសារពាង្គកាយឯកកោសិកា ។វាមានលក្ខណៈជាប្រូទីសសត្វផងនិងរុក្ខជាតិផង ។ អឺគ្លែនជាភាវៈរស់បរជីពពេលគ្មានពន្លឺនិងជាភាវៈរស់ស្វ័យជីព ពេលមានពន្លឺ ។

### 2.2 ឌីយ៉ាតូមេ


រូបទី3.6 កោសិកាឌីយ៉ាតូមេ

ឌីយ៉ាតូមេជាប្រូទីសឯកកោសិកា ។ វាជាចំណីរបស់ត្រីនិងសត្វនៅក្នុងទឹក ។ សារពាង្គកាយរបស់វាស្រោបដោយសំបកជាតិស៊ីលីសដែលគេអាចច្នៃធ្វើជាថ្នាំដុសធ្មេញឬវត្ថុផ្សេងៗនៅពេលដែលវាងាប់ ។

### 2.3 សារាយ



រូបទី3.7 សារាយត្នោត

សារាយភាគច្រើន ជាសារពាង្គកាយពហុកោសិកា ខ្លះទៀតជាសារពាង្គកាយឯកកោសិកា(សារាយបៃតងខ្លះ) ។ សារាយមានបីក្រុម គឺសារាយបៃតង សារាយក្រហម និងសារាយត្នោត ។ សារាយជាអាហាររបស់ត្រីនិងសត្វរស់ក្នុងទឹក ។ មនុស្សប្រើប្រាស់សារាយជាអាហារឬផលិតអាកា- អាកា(Agar-agar) ដែលជាសារធាតុសំខាន់សម្រាប់បណ្ដុះបាក់តេរីនៅក្នុងមន្ទីរពិសោធន៍ ។ ភាពលើសលប់នៃសារាយបង្កើនបរិមាណអុកស៊ីសែនរលាយក្នុងទឹកនិងបន្ថយកង្វក់ក្នុងទឹក ។

## 3. ប្រូទីសផ្សិត

ប្រូទីសផ្សិត ជាភាវៈរស់បរជីព ។ កោសិការបស់វាមានភ្នាសគ្រោង ហើយបន្តពូជតាមរយៈស្ព័ ។ ក្នុងប្រូទីសផ្សិតមានស្លែភក់និងផ្សិតទឹក ។

## 3.1 ស្លែភក់



រូបទី38 ស្លែភក់

ស្លែភក់ ជាសារពាង្គកាយឯកកោសិកា ។ វាផ្លាស់ទីនិងស៊ីអាហារ(បាក់តេរីនិងរុក្ខជាតិរលួយ)ដោយប្រើជើងបញ្ឆោតដូចអាមីប ។ ស្លែភក់អាចមានរូបរាងដូចជា ដុំចាហួយមួយយ៉ាងធំដោយការភ្ជាប់ជាមួយគ្នារវាងកោសិការបស់វាជាច្រើន ។

## 3.2 ផ្សិតទឹក

ផ្សិតទឹករស់នៅក្នុងទឹកនិងកន្លែងសើម ។ វាស៊ីសាកសពក្នុងទឹកជាអាហារហើយខ្លះទៀតវាជាបរាសិតលើសត្វទឹក(ត្រី . . . ) និងលើរុក្ខជាតិដូចជាដំឡូងបារាំង ពោតជាដើម ។

### មេរៀនសង្ខេប

- ប្រូទីស ជាសារពាង្គកាយឯកកោសិកាឬពហុកោសិកា ជាបរជីពឬស្វ័យជីព ។ ប្រូទីសចែកជាបីក្រុមគឺ ប្រូទីសសត្វ ប្រូទីសរុក្ខជាតិ ប្រូទីសផ្សិត ។
- តាមរបៀបរស់នៅនិងការផ្លាស់ទី គេចែកប្រូទីសសត្វជាបួនក្រុមគឺ អាមីប ប៉ារ៉ាមេស៊ីសាឌីយ៉ា និងស្ប៉ូរ៉ូស្វូអ៊ែ ។ វាបន្តពូជដោយភេទនិងឥតភេទ ។ ប្រូទីសសត្វភាគច្រើនជាបរាសិត ។
- ប្រូទីសរុក្ខជាតិឯកកោសិកាមាន អឺគ្លែននិងឌីយ៉ាតូមេ ។ ប្រូទីសរុក្ខជាតិពហុកោសិកាមានសារាយបៃតង សារាយក្រហម និងសារាយត្នោត ។ ប្រូទីសរុក្ខជាតិជាចំណីរបស់ត្រីនិងសត្វទឹកផ្សេងទៀត ។
- ប្រូទីសផ្សិតមានស្លែភក់និងផ្សិតទឹក ។ ប្រូទីសផ្សិតខ្លះ ដូចជា ផ្សិតទឹក បរាសិតលើសត្វទឹក

## ? សំណួរនិងលំហាត់

1. តើប្រូទីសជាអ្វី ? វាមានប៉ុន្មានក្រុម ?
2. តើអាមីបបង្កជំងឺអ្វីដល់មនុស្ស ? តើធ្វើដូចម្ដេចដើម្បីជៀសវាងពីការបង្ករោគនេះ ?
3. តើជំងឺគ្រុនចាញ់បណ្ដាលមកពីអ្វី ?
4. ហេតុអ្វីបានជាគេចាត់ទុកអឺគ្លែនជាប្រូទីសសត្វផង រុក្ខជាតិផង ?

# ពិសោធន៍ : ការសង្កេតប្រូទីសទឹកសាប

## 1. វត្ថុបំណង

សង្កេតលក្ខណៈប្រូទីសទឹកសាប ។

## 2. សម្ភារៈ

ទឹកត្រពាំងឬទឹកថ្លុក បំពង់បន្តក់ បន្ទះកញ្ចក់ បន្ទះកញ្ចក់ស្តើង មីក្រូទស្សន៍ ។

## 3. ដំណើរការ

- បន្តក់ទឹកត្រពាំងមួយតំណក់ទៅលើបន្ទះកញ្ចក់ ហើយយកបន្ទះកញ្ចក់ស្តើងគ្របពីលើតំណក់ទឹកនោះថ្នមៗ ។
- ប្រើអុបសិចទីបលេខតូច ហើយរំកិលចុះឡើងរហូតដល់ឃើញរូបភាពប្រូទីសច្បាស់ ។ បើត្រូវការ អ្នកអាចប្រើអុបសិចទីបលេខធំដើម្បីពិនិត្យមើល ។




## 4. សន្និដ្ឋាន

ចូរគូររូបប្រូទីសទឹកសាបដែលអ្នកមើលឃើញ ។

មេរៀនទី

# 4 ផ្សិត

ចប់មេរៀននេះ សិស្សអាច

- ធ្វើអត្តសញ្ញាណនូវលក្ខណៈពិសេសរបស់ផ្សិតនិងលីកែន
- ប្រៀបធៀបពីផ្សិតមានប្រយោជន៍និងផ្សិតគ្មានប្រយោជន៍
- ពណ៌នាពីការបន្តពូជរបស់ផ្សិត
- មានស្មារតីថែរក្សាលីកែននិងផ្សិតដែលមានប្រយោជន៍ចំពោះធម្មជាតិ ។

អ្នកធ្លាប់ស្គាល់ផ្សិតផ្ទួរដែលដុះលើនំប៉័ងឬបាយផ្អូម និងផ្សិតដែលដុះក្នុងចម្ការឬព្រៃក្រោយផ្ទះរបស់អ្នកដែរឬទេ ។ ទាំងអស់នេះសុទ្ធតែជាផ្សិត ។ ផ្សិតភាគច្រើនបង្ហាញនូវលក្ខណៈសំខាន់ៗមួយចំនួន ។ វាជាភាវៈរស់ដូចរុក្ខជាតិគ្មានសរសៃនាំនិងគ្មានក្លរ៉ូភីល ។ ហេតុដូច្នេះហើយ ផ្សិតមិនអាចធ្វើរស្មីសំយោគបានទេ ។ វាត្រូវតែស្រូបយកអាហារពីភាវៈរស់ដទៃទៀត ។ វាជាសារពាង្គកាយបរជីពនិងបន្តពូជដោយស្ប៉ ។

## 1. រូបផ្ទុំ

ផ្សិតមានច្រើនបែបយ៉ាង ចាប់ពីឯកកោសិការហូតដល់ពហុកោសិកា ។ ផ្សិតទាំងអស់បង្កឡើងពីកោសិកាដែលរុំព័ទ្ធជុំវិញដោយភ្នាសគ្រោង ។ កោសិការបស់ផ្សិតភាគច្រើនមានរូបផ្ទុំជាអ៊ីប លើកលែងតែផ្សិតដែលងាយជាងគេបំផុត ដូចជា ដំបែ ។ អ៊ីបមានរាងជាបំពង់សរសៃឆ្មារៗ បែកមែកប្រទាក់ក្រឡាគ្នាដែលបង្កើតបានជាសារពាង្គកាយរបស់ផ្សិតពហុកោសិកា ។ អ៊ីបរបស់ផ្សិតខ្លះទៀត ជាសរសៃបន្តគ្នានៃស៊ីតូប្លាសដែលមានណ្វៃយ៉ូច្រើន ។ សារធាតុឆ្លងកាត់ដោយសេរីនិងយ៉ាងរហ័សតាមរយៈអ៊ីបនេះ ។



រូបទី៤.១ : ផ្សិតផ្ទួរដុះលើផ្លែក្រូច

ផ្សិតមានរូបរាងខុសៗគ្នា អាស្រ័យនឹងការតម្រៀបអ៊ីបរបស់វា ។ ក្នុងផ្សិតខ្លះ អ៊ីបមានរាងជាសរសៃឆ្មារៗបែកមែកប្រទាក់ក្រឡាគ្នាល្ហោលៗ (រង្វើល) ។ ផ្សិតខ្លះទៀត អ៊ីបរបស់វាតម្រៀបគ្នាយ៉ាងណែន ។ ជើងនិងមួករបស់វាកើតឡើងពីការតម្រៀបអ៊ីបយ៉ាងណែនដែលធ្វើឱ្យផ្សិតមានភាពរឹងមាំ ។ តែយ៉ាងណាក៏ដោយ នៅផ្នែកក្រោមដី អ៊ីបរបស់ផ្សិតបង្កើតបានជាសរសៃឆ្មារៗប្រទាក់ក្រឡាគ្នាល្ហោលៗ ។



*រូបទី4.2 : រូបផ្សិត*

ផ្សិតស្រូបយកអាហារតាមរយៈអ៊ីបដែលដុះចូលទៅក្នុងប្រភពអាហារ ។ ដំបូងផ្សិតដុះជាអ៊ីបនៅក្នុងអាហារ ។ បន្ទាប់មកសារធាតុគីមីរំលាយអាហារ (រសរំលាយអាហារ) ជ្រាបពីអ៊ីបទៅក្នុងអាហារ ។ សារធាតុគីមីនេះ បំបែកអាហារទៅជាម៉ូលេគុលតូចៗដែលអាចជ្រាបតាមអ៊ីបបាន ។

ផ្សិតភាគច្រើនបន្តពូជដោយ **ស្ប៉ រ** ។ ស្ប៉ រនេះផ្ទុកក្នុងសរីរាង្គពិសេសមួយ ហៅថា **ស្ប៉ រ៉ង់** ។ ពេលស្ប៉ រធ្លាក់នៅលើដីសើម វាលូតលាស់បានជាផ្សិតថ្មីៗទៀត ។

## 2. តួនាទីរបស់ផ្សិតក្នុងធម្មជាតិ

ផ្សិតមានឥទ្ធិពលលើមនុស្សនិងសារពាង្គកាយដទៃទៀតតាមរបៀបផ្សេងៗ ។ ផ្សិតមួយចំនួនធំជាអាហាររបស់មនុស្ស ។ ផ្សិតដើរតួយ៉ាងសំខាន់ក្នុងការបំបែកនិងបង្កើតវដ្តរូបធាតុនៅលើផែនដី ។ ផ្សិតមួយចំនួនបង្កជំងឺ ឯមួយចំនួនទៀតប្រយុទ្ធប្រឆាំងនឹងជំងឺ ។ នៅមានផ្សិតផ្សេងៗទៀតដែលរស់ជាសហប្រាណជាមួយសារពាង្គកាយដទៃទៀត ។

ផ្សិតផ្សរ ដំបែ និងផ្សិតធំជាប្រភពអាហារដ៏សំខាន់ ។ អ្នកធ្វើនំប៉័ងថែមដំបែទៅក្នុងម្សៅទន់ៗដើម្បីឱ្យម្សៅឡើងមេ ។ កោសិកាដំបែប្រើប្រាស់ស្ករ (ដែលបានមកពីការបំបែកអាមីដុងរបស់អង់ស៊ីមអាមីឡាស) ក្នុងម្សៅទន់ៗធ្វើជាអាហារ ហើយផលិតឧស្ម័នកាបូនិច ($CO_2$) ។ ឧស្ម័ននេះបង្កើតជាពពុះខ្យល់ដែលបណ្តាលឱ្យម្សៅទន់ៗនោះឡើងមេ ។ អ្នកឃើញពពុះខ្យល់ទាំងនេះដូចជារន្ធឬប្រហោងជាច្រើននៅពាសពេញក្នុងសាច់នំប៉័ង ។ ផ្សិតផ្សរត្រូវបានប្រើប្រាស់សម្រាប់ផលិតអាហារផងដែរ ដូចជា

ប្រូម៉ាសជាដើម ។ មនុស្សចូលចិត្តបរិភោគផ្សិតជាអាហារ ។ អ្នកមិនគប្បីប៉ះឬបរិភោគផ្សិតព្រៃដែលអ្នកមិនស្គាល់នោះទេ ព្រោះផ្សិតមួយចំនួនមានពិសពុលជាទីបំផុត ។

ដូចជាបាក់តេរីដែរ ផ្សិតភាគច្រើនជា**អ្នកបំបែក** ។ ***ឧទាហរណ៍*** ផ្សិតមួយចំនួនរស់នៅក្នុងដីបំបែកសារធាតុសរីរាង្គក្នុងភាវៈរស់ដែលងាប់ ។ លំនាំនេះផ្តល់មកវិញនូវសារធាតុសំខាន់ៗ (សារធាតុខនិជ) ទៅឱ្យដី ។ ប្រសិនបើពុំមានផ្សិតនិងបាក់តេរីទេនោះ ផែនដីត្រូវបានគ្របដណ្តប់ទៅដោយគំនរសាកសពសត្វនិងរុក្ខជាតិ ។

នៅក្នុងឆ្នាំ 1928 ជីវវិទូជាតិអេកូស ឈ្មោះ **អាឡិចសាន់ឌ័រផ្លេមីង** ( *Alexander Fleming*) បានពិនិត្យប្រអប់ប៉េទ្រីដែលគាត់បានបណ្តុះបាក់តេរីនៅក្នុងនោះ ។ គាត់សង្កេតឃើញថា ស្នាមអុចៗពណ៌ស្ទើរខៀវបៃតងរបស់ផ្សិតផ្សរកំពុងដុះនៅក្នុងកែវមួយ ។ គាត់ឆ្ងល់ថា ហេតុអ្វីបានជាគ្មានបាក់តេរីដុះក្បែរផ្សិតផ្សរនេះសោះ ។ អាឡិចសាន់ឌ័របានបង្កើតសម្មតិកម្មថា **ផ្សិតផ្សរផលិតសារធាតុម្យ៉ាងដែលសម្លាប់បាក់តេរីនៅក្បែរវា** ។ គាត់ឱ្យឈ្មោះផ្សិតផ្សរនោះថាពេនីសេល្យូម ។ ឯសារធាតុដែលបញ្ចេញដោយពេនីសេល្យូមឈ្មោះថា **ពេនីស៊ីលីន** ។

អាឡិចសាន់ឌ័របានចូលរួមក្នុងការអភិវឌ្ឍ **អង់ទីប្យូទិច** លើកដំបូងគឺ ពេនីស៊ីលីន ។ ចាប់តាំងពីមានរបកគំហើញថ្នាំពេនីស៊ីលីនមក **អង់ទីប្យូទិច**មួយចំនួនទៀតត្រូវបានចម្រាញ់ចេញពីផ្សិតនិងបាក់តេរី ។

ផ្សិតមួយចំនួនជាបរាសិតដែលបណ្តាលឱ្យមានជំងឺយ៉ាងធ្ងន់ធ្ងរចំពោះរុក្ខជាតិ ។ ផ្សិតដំដែលបង្កជំងឺដាច់អែល ( *Dutch elm*) ធ្វើឱ្យដើមអែលរាប់លានងាប់នៅអាមេរិកខាងជើងនិងអឺរ៉ុប ។ ជំងឺផ្សិតរុក្ខជាតិក៏មានឥទ្ធិពលទៅលើកសិផលផ្សេងៗដែរ ដូចជា ស្រូវ កប្បាស និងសណ្តែកសៀងដែលនាំមកនូវការខូចខាតកសិផលយ៉ាងសម្បើមជារៀងរាល់ឆ្នាំ ។

ផ្សិតមួយចំនួនទៀតបង្កជំងឺដល់មនុស្ស ។ ជំងឺផ្សិតដែលកើតមាននៅត្រង់ចន្លោះម្រាមជើងមានលក្ខណៈសើម បណ្តាលឱ្យរមាស់និងកន្ទួលក្រហាលក្រហាយ ។ ស្រែងនិងជំងឺផ្សិតផ្សេងទៀតបណ្តាលឱ្យរមាស់និងកន្ទួលនៅលើស្បែក ព្រោះផ្សិតដែលបង្កជំងឺទាំងនេះ ផលិតស្ប៉ូចំកន្លែងមានរបួសឬដំបៅ ។ ជំងឺនេះអាចឆ្លងរាលដាលយ៉ាងរហ័ស ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ជំងឺទាំងពីរនេះអាចព្យាបាលបានជាមួយថ្នាំអង់ទីផ្សិត ។



*រូបទី4.3 : រុក្ខជាតិមានកំពកឫស*

ផ្សិតខ្លះទៀតជួយរុក្ខជាតិឱ្យកាន់តែលូតលាស់ និងមានសុខភាពល្អ កាលណាអ៊ីបរបស់ផ្សិតដុះលើឫសរបស់រុក្ខជាតិនោះ ។ អ៊ីបពង្រាយនៅក្រោមដីស្រូបទឹកនិងសារធាតុចិញ្ចឹមពីដីឱ្យទៅរុក្ខជាតិ ។ដោយសារមានទឹកនិងសារធាតុចិញ្ចឹមគ្រប់គ្រាន់ រុក្ខជាតិនេះលូតលាស់កាន់តែរហ័សជាងរុក្ខជាតិដែលគ្មានផ្សិតជាដៃគូ ។ រុក្ខជាតិដែលជាដៃគូ ទទួលផលចំណេញពីផ្សិត ។ ផ្សិតផ្តល់អាហារលើសពីតម្រូវការដែលរុក្ខជាតិប្រើប្រាស់ហើយអាហារលើសនោះត្រូវបានស្តុកទុកក្នុងរុក្ខជាតិ ។

## 3. វដ្តជីវិតរបស់ផ្សិត

ផ្សិតមាននៅគ្រប់ទីកន្លែង ។ វិធីបន្តពូជរបស់វាធានានូវការរស់រានមានជីវិតនិងការពង្រាយ ។ តាមធម្មតា ផ្សិតបន្តពូជដោយស្ព័ ។ ស្ព័មានទម្ងន់យ៉ាងស្រាលដែលព័ទ្ធជុំវិញដោយសំបកការពារ ហើយអាចដឹកនាំយ៉ាងងាយទៅកាន់កន្លែងផ្សេងទៀត តាមខ្យល់ឬតាមទឹកហូរ ។ ផ្សិតបង្កើតស្ព័រាប់លានដែលភាគច្រើនអាចរស់ ។ មានតែស្ព័មួយចំនួនតូចប៉ុណ្ណោះដែលធ្លាក់ចំកន្លែងមានលក្ខខណ្ឌសមស្របសម្រាប់វាលូតលាស់ ។ ផ្សិតផលិតស្ព័នៅក្នុងស្ព័រ៉ង់ ។ រូបរាងស្ព័រ៉ង់ ប្រែប្រួលទៅតាមប្រភេទផ្សេងៗរបស់ផ្សិត ។ ចំពោះផ្សិតខ្លះ ដូចជាផ្សិតធំ ផ្នែកដែលយើងមើលឃើញជាស្ព័រ៉ង់ ។ ចំពោះផ្សិតផ្សេងទៀត *ឧទាហរណ៍* ផ្សិតផ្ការលើនំប៉័ង អ៊ីបរបស់វាដុះត្រង់ឡើងលើហើយនៅខាងចុងអ៊ីបនេះមានថង់ស្ព័មួយពណ៌ខ្មៅកើតឡើង ។ ថង់ស្ព័នេះជាស្ព័រ៉ង់ ។

### 3.1 ការបន្តពូជដោយឥតភេទ


*រូបទី4.4 : ការបន្តពូជរបស់ដំបែ*

ផ្សិតភាគច្រើនបន្តពូជដោយភេទនិងឥតភេទ ។ នៅពេលមានសំណើមនិងអាហារគ្រប់គ្រាន់ ផ្សិតផលិតស្ព័តាមការបន្តពូជដោយឥតភេទ ។ កោសិកាទាំងឡាយនៅផ្នែកខាងចុងអ៊ីបធ្វើចំណែកដើម្បីបង្កើតស្ព័ ។ ស្ព័លូតលាស់ជាផ្សិតថ្មីដែលដូចគ្នាបេះបិទនឹងផ្សិតមេ ។ កោសិកាដំបែបន្តពូជដោយឥតភេទហៅថា ការចេញពន្លក ។ ការចេញពន្លកនេះ

គ្មានការផលិតស្ប៉ូរទេ ។ កោសិកាដំបែតូចៗដុះចេញពីកោសិកាមេ ដូចគ្នាទៅនឹងការចេញពន្លករបស់មែកឈើ ។ កោសិកាថ្មីៗនេះបំបែកបន្តទៀត ហើយរស់នៅលើកោសិកាមេ ។

## 3.2 ការបន្តពូជដោយភេទ

ផ្សិតភាគច្រើនក៏អាចបន្តពូជដោយភេទបានដែរ ពិសេសនៅពេលលក្ខខណ្ឌនៃការលូតលាស់មិនសមស្រប ។ ក្នុងការបន្តពូជដោយភេទ អ៊ីបពីរលូតលាស់ជាមួយគ្នា បន្ទាប់មក មានបណ្តូរសម្ភារៈតំណពូជ ។ តាមពិតទម្រង់នៃការបន្តពូជថ្មីនេះ កើតឡើងពីការភ្ជាប់អ៊ីបនិងការផលិតស្ប៉ូរ ។ ស្ប៉ូរលូតលាស់ជាផ្សិតដែលមានសម្ភារៈតំណពូជខុសពីមេរបស់វា ។




*រូបទី4.5 : ការបន្តពូជរបស់ផ្សិតផ្សូរ*

## 4. លីកែន

លីកែន កើតឡើងពីផ្សិតនិងសារាយឬបាក់តេរីស្វ័យជីពដែលរស់នៅរួមគ្នាក្នុងទំនាក់ទំនងសហប្រាណមួយ ។ អ្នកប្រហែលជាប់ស្គាល់លីកែនក្រៀមដែលដុះនៅលើសំបកឈើឬថ្ម ។ ផ្សិតស្រូបយកអាហារដែលផលិតដោយសារាយឬបាក់តេរី ។ សារាយឬបាក់តេរីស្រូបទឹកនិងសារធាតុខនិជពីផ្សិតព្រមទាំងយកផ្សិតធ្វើជាជម្រកទៀតផង ។



*រូបទី4.6 : លីកែន*

គេតែងហៅលីកែនថាជាសារពាង្គកាយ "ត្រួសត្រាយ " ព្រោះវាជាសារពាង្គកាយទីមួយដែលកើតឡើងនៅលើថ្ម ក្នុងតំបន់ក្រោយពេលមានបន្ទុះភ្នំភ្លើងឬភ្លើងឆេះ ។ ពេលវេលាកន្លងទៅយ៉ាងយូរ លីកែនបំបែកថ្មបន្តិចម្តងៗឱ្យទៅជាដីដែលនៅទីនោះសារពាង្គកាយដទៃទៀតអាចលូតលាស់បាន ។ លីកែនក៏មានប្រយោជន៍ផងដែរ គេប្រើវាជាអាំងឌីកាទ័រ (សម្រាប់ចង្អុលបង្ហាញ) នៃកង្វក់ខ្យល់ ។ មានលីកែនច្រើនប្រភេទដែលមានភាពរួសទៅនឹងធាតុកខ្វក់ ហើយវាក៏ងាប់នៅពេលកម្រិតកង្វក់កើនឡើង ។ ដោយពិនិត្យលើការលូតលាស់របស់លីកែន អ្នកវិទ្យាសាស្ត្រអាចវាយតម្លៃគុណភាពខ្យល់ក្នុងតំបន់មួយបាន ។

## មេរៀនសង្ខេប

- ផ្សិតរួមមានដំបែ ផ្សិតផ្អេរ ផ្សិតធំ ក្រា និងលីកែន ។ ផ្សិតទាំងអស់បង្កឡើងពីកោសិកាដែលរុំព័ទ្ធជុំវិញដោយភ្នាសគ្រោង ។ផ្សិតជាភាវៈរស់ដូចរុក្ខជាតិគ្មានសរសៃនាំនិងគ្មានក្លរ៉ូភីល ។ វាជាសារពាង្គកាយបរជីព ព្រោះវាចិញ្ចឹមជីវិតដោយស្រូបយកអាហារពីសារពាង្គកាយដទៃទៀត ។
- ផ្សិតបន្តពូជដោយស្ប៉ ។ ស្ប៉មានទម្ងន់យ៉ាងស្រាលដែលព័ទ្ធជុំវិញដោយសំបកការពារ ហើយអាចដឹកនាំយ៉ាងងាយទៅកន្លែងផ្សេងទៀតតាមទឹកឬខ្យល់ ។ ផ្សិតខ្លះទៀតបន្តពូជដោយភេទ ។
- ផ្សិតភាគច្រើនជាអាហាររបស់មនុស្ស ខ្លះទៀតមាននាទីយ៉ាងសំខាន់គឺ ជាអ្នកបំបែកនិងបង្កើតវត្ថុរូបធាតុនៅលើផែនដី ។ ផ្សិតខ្លះទៀតបង្កជំងឺដល់មនុស្ស សត្វ និងរុក្ខជាតិ ខ្លះទៀតប្រឆាំងនឹងជំងឺ ។ ចំណែកផ្សិតខ្លះទៀតរស់ជាសហប្រាណជាមួយសារពាង្គកាយដទៃទៀត ។

## សំណួរនិងលំហាត់

1. តើអ៊ីបជាអ្វី ?
2. តើផ្សិតស្រូបយកអាហារចិញ្ចឹមជីវិតដោយរបៀបណា ?
3. តើផ្សិតមាននាទីដូចម្តេចខ្លះនៅក្នុងធម្មជាតិ ?
4. ដូចម្តេចហៅថា លីកែន ?
5. តើពេនីស៊ីលីនជាអ្វី ?

# ពិសោធន៍ ៖ ឥទ្ធិពលរបស់ស្ករលើសកម្មភាពដំបែ

**1.** វត្ថុបំណង ៖ សង្កេតពីឥទ្ធិពលរបស់ស្ករលើសកម្មភាពដំបែរួចទាញសេចក្ដីសន្និដ្ឋានពីការពិសោធនេះ ។

**2.** សម្ភារៈ ៖ ដបជ័រ 4 ប៉ោងប៉ោង4 ហ្វឺត ចង្កឹះ4 ស្ករ ម្សៅដំបែ ឬមេនំប៉័ង ទឹកក្ដៅឧណ្ហៗ ។

**3.** ដំណើរការ

- យកហ្វឺតសរសេរលើដបទាំង4 ៖ A , B , C , D ។ បន្ទាប់មកច្រកទឹកក្ដៅឧណ្ហៗ 0.50 ℓ ក្នុងដបទាំង4ស្មើៗគ្នា ។
- ដាក់ស្ករក្នុងដប B C និងD ចំនួន25g ។
- ដាក់ម្សៅដំបែ ចំនួន 6g ក្នុងដប A ។ បន្ទាប់មកយកចង្កឹះកូរឱ្យសព្វ រួចដាក់ប៉ោងប៉ោងលើមាត់ដបនោះឱ្យបានតឹងណែន ។
- ធ្វើដូចចំណុចទីបី ចំពោះដប B ហើយដប C ដាក់ដំបែ50gនិងដប D មិនចាំបាច់ដាក់ម្សៅដំបែទេ ។ រួចដាក់ដបទាំង4ទៅចំកន្លែងមានកម្ដៅក្ដៅល្មម ។
- រយៈពេល5 ម៉ោងក្រោយមកធ្វើការសង្កេត ហើយកត់ត្រានូវលក្ខណៈខុសគ្នារវាងប៉ោងប៉ោងនៅលើដបទាំង4 ដាក់ក្នុងតារាង ។ ទុកពិសោធន៍នេះរយៈពេល24 ម៉ោងដើម្បីឱ្យឃើញលក្ខណៈខុសគ្នាកាន់តែខ្លាំង ។

ចំណាំ ៖ ប៉ោងប៉ោងមុននឹងយកទៅដាក់លើមាត់ដប ត្រូវផ្លុំឬទាញឱ្យវែងសិន ។

| តារាងទិន្នន័យ | | |
|---|---|---|
| ដប | ការទស្សន៍ទាយ | ការសង្កេត |
| A : ដំបែសុទ្ធ 6g | | |
| B : ដំបែ 6g + ស្ករ 25g | | |
| C : ដំបែ 50g + ស្ករ 25g | | |
| D : ស្ករ 25g | | |




ដំបែ 6g　　ដំបែ 6g+ស្ករ 25g　　ដំបែ 50g + ស្ករ 25g　　ស្ករ 25g

## 4. វិភាគ

ក. តើប៉ោងប៉ោងណាខ្លះដែលប្រែប្រួលទំហំក្នុងរយៈពេលពិសោធន៍នេះ ។ តើវាប្រែប្រួលយ៉ាងដូចម្ដេច ?

ខ. ចូរពន្យល់ថា ហេតុអ្វីបានជាដបខ្លះប៉ោងប៉ោងរីកធំ ដបខ្លះទៀតប៉ោងប៉ោងមិនមានការប្រែប្រួលទំហំទេ ។

គ. ប្រៀបធៀបលទ្ធផលដប B ,C និង D ។

## 5. សន្និដ្ឋាន

ក. តើដំបែប្រើប្រាស់អ្វី ជាប្រភពអាហារ ?

ខ. តាមរយៈពិសោធន៍នេះ តើអ្នកយល់ដឹងអ្វីខ្លះអំពីដំបែ?

មេរៀនទី

# 5 រុក្ខជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ❒ បង្ហាញពីវដ្តជីវិតរបស់រុក្ខជាតិ
- ❒ ពណ៌នាពីលក្ខណៈពិសេសរបស់រុក្ខជាតិគ្មានសរសៃនាំ
- ❒ ពណ៌នាពីលក្ខណៈពិសេសរបស់រុក្ខជាតិមានសរសៃនាំ
- ❒ ប្រៀបធៀបរុក្ខជាតិមានសរសៃនាំនិងគ្មានសរសៃនាំ ។

រុក្ខជាតិស្ទើរទាំងអស់ ជាសារពាង្គកាយស្វ័យជីពដែលផលិតអាហារដោយខ្លួនឯង ។ រុក្ខជាតិទាំងអស់ជាសារពាង្គកាយពហុកោសិកា (អឺការីយ៉ូត) ហើយគ្រប់កោសិការុក្ខជាតិព័ទ្ធជុំវិញដោយភ្នាសគ្រោងឬភ្នាសសែលុយឡូស ។ ចំពោះរុក្ខជាតិដុះលើគោកត្រូវតែមានជីវិតស្រូបយកទឹកនិងសារធាតុចិញ្ចឹមពីមជ្ឈដ្ឋានជុំវិញរបស់វា ។ រុក្ខជាតិទាំងនេះស្តុកទឹក ដឹកនាំសារធាតុផ្សេងៗដើម្បីទ្រទ្រង់រាងកាយនិងបន្តពូជ ។

នៅលើពិភពលោកសព្វថ្ងៃនេះ មានរុក្ខជាតិរាប់ម៉ឺនប្រភេទ ។ អ្នកវិទ្យាសាស្ត្រផ្ទុំរុក្ខជាតិជាពីរក្រុមធំៗ រុក្ខជាតិគ្មានសរសៃនាំនិងរុក្ខជាតិមានសរសៃនាំ ។




*រូបទី5.1 វដ្តជីវិតរុក្ខជាតិ*

រុក្ខជាតិមានវដ្តជីវិតសាំញ៉ាំរួមមានពីរដំណាក់កាល : ដំណាក់កាលស្ប៉ូរ៉ូភីតនិងដំណាក់កាលកាម៉េតូភីត ។ ក្នុងដំណាក់កាលស្ប៉ូរ៉ូភីត រុក្ខជាតិផលិតស្ប៉ ។ វាជាកោសិកាតូចៗដែលអាចលូតលាស់ជាសារពាង្គកាយថ្មី ។ ស្ប៉លូតលាស់ក្នុងដំណាក់កាលមួយផ្សេងទៀតនៃរុក្ខជាតិហៅថាកាម៉េតូភីត ។ ក្នុងដំណាក់កាលនេះរុក្ខជាតិផលិតកោសិកាភេទពីរបែបគឺកាម៉េតឈ្មោលនិងកាម៉េតញី ។ រូបភាពទី5.1 បង្ហាញពីវដ្តជីវិតគំរូរបស់រុក្ខជាតិ ។

កាម៉េតញីនិងកាម៉េតឈ្មោលភ្ជាប់គ្នាបង្កើតបានជាស៊ីកូត ។ បន្ទាប់មកស៊ីកូតលូតលាស់ទៅជាស្ប៉រ៉ូភីត ។ ស្ប៉រ៉ូភីតផលិតស្ប៉ដែលលូតលាស់ក្នុងកាម៉េតូភីត ។ ក្រោយមក កាម៉េតូភីតផលិតកាម៉េតញីនិងកាម៉េតឈ្មោលហើយវដ្តនេះផ្ដើមសាជាថ្មី ។ តាមធម្មតា ស្ប៉រ៉ូភីតរបស់រុក្ខជាតិមើលទៅខុសពីកាម៉េតូភីត ។

# 1. រុក្ខជាតិគ្មានសរសៃនាំ

រុក្ខជាតិគ្មានសរសៃនាំមានពីរក្រុមធំៗ : ស្លែនិងអេប៉ាទិច ។ រុក្ខជាតិថ្នាក់ទាបទាំងនេះ រស់នៅតំបន់សើមដែលនៅទីនោះវាអាចស្រូបទឹកនិងសារធាតុចិញ្ចឹមដទៃទៀតដោយផ្ទាល់ពីបរិស្ថាន ។ មជ្ឈដ្ឋានទឹកជុំវិញវាក៏អាចឱ្យកាម៉េតឈ្មោលហែលទៅរកកាម៉េតញីបាន ។

## 1.1 ស្លែ

ស្លែជាក្រុមដែលមានប្រភេទច្រើនជាងគេបង្អស់នៃរុក្ខជាតិគ្មានសរសៃនាំ ។ វាមានលើសពី 10,000 ប្រភេទ ។ អ្នកប្រហែលធ្លាប់ឃើញស្លែដែលដុះតាមស្នាមប្រេះនៅតាមផ្លូវដើរ លើដើមឈើ និងក្នុងកន្លែងសើមមានម្លប់ ។ រូបភាពទី 5.2 បង្ហាញពីរូបផ្ដុំរបស់រុក្ខជាតិស្លែ ។ ស្លែពណ៌បៃតងមានរោមឆ្មារៗដែលជារុក្ខជាតិជំនាន់កាម៉េតូភីត ។



*រូបទី5.2 រូបផ្ដុំស្លែ*

រូបរាងរបស់ស្លែមើលទៅដូចជាស្លឹកតូចល្អិតដុះចេញពីទងដ៏តូចដូចដើម ។ ស្លែភ្ជាប់ទៅនឹងដីដោយឫសឆ្មារៗហៅថា **រីសូអ៊ីត** ដែលជួយក្នុងការស្រូបទឹកនិងសារធាតុចិញ្ចឹមពីដីថែមទៀត ។ ស្ប៉រ៉ូភីតដុះចេញពីកាម៉េតូភីត ។ វាមានទងឆ្មារៗដែលមានកន្សោមនៅខាងចុងសម្រាប់ផ្ទុកស្ប៉ ។

## 1.2 អេប៉ាទិច

អេប៉ាទិចមានជាង 8,000 ប្រភេទ ។ វាតែងដុះយ៉ាងក្រាស់នៅស្រទាប់លើនៃថ្មសើមឬលើដីសើមតាមដងអូរឬជ្រោះ ។ រុក្ខជាតិក្រុមនេះ ឱ្យឈ្មោះទៅតាមរូបរាងនៃកាម៉េតូភីតដែលមានរាងដូចស្លឹករុក្ខជាតិឬមើលទៅដូចជាថ្លើមមនុស្សផងដែរ ។ អេប៉ាទិចមានស្ប៉រ៉ូភីតដ៏តូចបំផុត ។

# 2. រុក្ខជាតិមានសរសៃនាំ

រុក្ខជាតិមានសរសៃនាំមាន បណ្ណង្គជាតិនិងរុក្ខជាតិមានគ្រាប់ ។ បណ្ណង្គជាតិមានជាលិកាសរសៃនាំពិតប្រាកដហើយមិនផលិតគ្រាប់ទេ ។ ជំនួសដោយការផលិតគ្រាប់ បណ្ណង្គជាតិផលិតស្ប៉ ។

តារាង " ក " សង្ខេបនូវលក្ខណៈពិសេសរបស់ស្លែ អេប៉ាទិច បណ្ណង្គជាតិ និងរុក្ខជាតិមានគ្រាប់ ។

*តារាង " ក "*

| រុក្ខជាតិគ្មានសរសៃនាំ | | រុក្ខជាតិមានសរសៃនាំ | |
|---|---|---|---|
| ស្លែ | អេប៉ាទិច | បណ្ណង្គជាតិ | រុក្ខជាតិមានគ្រាប់ |
| បន្តពូជដោយស្ប៉ | | | បន្តពូជដោយគ្រាប់ |

## 2.1 បណ្ណង្គជាតិ

បណ្ណង្គជាតិដែលរស់នៅសព្វថ្ងៃមានជាង 12,000 ប្រភេទ ។ បណ្ណង្គជាតិមានដើម ឫស ស្លឹកពិតប្រាកដ ដូចរុក្ខជាតិមានសរសៃនាំដទៃទៀតដែរ ។ ដើមរបស់បណ្ណង្គជាតិច្រើននៅក្រោមដី ។ ស្លឹកដុះចេញទៅលើដោយចេញពីផ្នែកខាងលើនៃដើម ។ ឯឫសដុះចុះក្រោម ដោយចេញពីផ្នែកខាងក្រោមនៃដើម ។ ឫសចងបណ្ណង្គជាតិភ្ជាប់ទៅនឹងដី ហើយស្រូបទឹកនិងសារធាតុចិញ្ចឹមពីក្នុងដីមកវិញ ។ សារធាតុទាំងនេះ ចូលទៅក្នុងជាលិកាសរសៃនាំរបស់ឫស ហើយធ្វើដំណើរតាមជាលិកានេះនៅក្នុងដើមនិង ស្លឹក ។

រូបភាពទី 5.3 បង្ហាញពីរូបផ្គុំរបស់បណ្ណង្គជាតិ ។ គួរកត់សំគាល់ថា ស្លឹកឬធាងរបស់បណ្ណង្គជាតិចែកជាផ្នែកតូចៗជាច្រើនដែលមើលទៅដូចជាកូនស្លឹកតូចៗ ។ ផ្ទៃខាងលើនៃធាងនីមួយៗពាសទៅដោយស្រទាប់គុយទីគុលដែលជួយការពាររំភាយចំហាយទឹក ។



*រូបទី 5.3 រូបផ្គុំបំប្រក*

អម្បូរបណ្ណង្គជាតិដែលយើងមើលឃើញថាជាធាងរបស់ចំប្រកនោះ វាជាដំណាក់កាលស្ប៉័រ៉ូភីត របស់រុក្ខជាតិ ។ នៅផ្នែកខាងក្រោមនៃធាងចាស់ៗ ស្ប៉័លូតលាស់ក្នុងថង់តូចៗ ។ ខ្យល់និងទឹកអាចដឹកនាំ ស្ប៉័ទៅកាន់ទីដ៏ឆ្ងាយ ។ ប្រសិនបើស្ប៉័ធ្លាក់ទៅលើដីសើមឬដីដែលមានម្លប់ វានឹងលូតលាស់ទៅជា កាម៉េតូភីត ។ កាម៉េតូភីតរបស់បណ្ណង្គជាតិជារុក្ខជាតិដ៏តូចដែលដុះទាបៗនៅលើដី ។

## 2.2 រុក្ខជាតិមានគ្រាប់

រុក្ខជាតិមានគ្រាប់ បង្ហាញនូវលក្ខណៈពិសេសសំខាន់ពីរយ៉ាងគឺ វាមានជាលិកាសរសៃនាំនិងប្រើ ប្រាស់លំអងព្រមទាំងគ្រាប់ដើម្បីបន្តពូជ ។ លើសពីនេះ គ្រប់រុក្ខជាតិមានគ្រាប់តែងតែមានឫស ដើម និងស្លឹក ។ រុក្ខជាតិមានគ្រាប់មានវដ្តជីវិតស្មុគស្មាញដែលមានដំណាក់កាលស្ប៉័រ៉ូភីតនិងកាម៉េតូភីត ។ ចំពោះរុក្ខជាតិមានគ្រាប់ រុក្ខជាតិដែលអ្នកមើលឃើញជាដំណាក់កាលស្ប៉័រ៉ូភីត ។ ឯដំណាក់កាល កាម៉េតូភីត អាចមើលឃើញបានដោយមីក្រូទស្សន៍ ។

រុក្ខជាតិអាចរស់នៅក្នុងមជ្ឈដ្ឋានផ្សេងៗគ្នា ។ រុក្ខជាតិមានគ្រាប់មិនត្រូវការទឹក ដើម្បីឱ្យកាម៉េត ឈ្មោលហែលទៅរកកាម៉េតញីទេ ។ផ្ទុយទៅវិញ រុក្ខជាតិមានគ្រាប់ផលិតលំអងដែលមានផ្ទុកកោសិកា ។ ក្រោយមកកោសិកានេះក្លាយជាកាម៉េតឈ្មោល ។ គ្រាប់លំអងបញ្ចេញកោសិកាបន្តពូជឈ្មោលដោយ ផ្ទាល់នៅក្បែរកោសិកាបន្តពូជញី ។ បន្ទាប់ពីកោសិកាបន្តពូជឈ្មោលបង្កកំណើតជាមួយកោសិកាបន្តពូជ ញីមកគ្រាប់ក៏លូតលាស់ ។ គ្រាប់ជាទម្រង់មួយដែលផ្ទុករុក្ខជាតិខ្ចីនៅខាងក្នុង ហើយព័ទ្ធជុំវិញដោយ សំបកការពារ ។ គ្រាប់ការពាររុក្ខជាតិខ្ចីពីភាពស្ងួតនៃមជ្ឈដ្ឋានខាងក្រៅ ។

### ក. គ្រាប់រុក្ខជាតិ

គ្រប់គ្រាប់រុក្ខជាតិបង្ហាញនូវលក្ខណៈ សំខាន់ដូចគ្នាមួយចំនួន ។ ខាងក្នុងគ្រាប់ជា ផ្នែកដែលលូតលាស់ជារុក្ខជាតិ ។ ប្រសិនបើ គ្រាប់មួយធ្លាក់ទៅលើដីដែលមានលក្ខខណ្ឌ ប្រកបរុក្ខជាតិនឹងដុះចេញពីគ្រាប់នោះ ហើយចាប់ផ្ដើមលូតលាស់ ។ គ្រាប់នីមួយៗ មានបីផ្នែក សំខាន់ៗ ៖ អំប្រីយ៉ុង ផ្នែកស្តុក អាហារនិងសំបកគ្រាប់ ។




*រូបទី5.4 រូបផ្ចិតគ្រាប់*

រុក្ខជាតិថ្មីដែលលូតលាស់ចេញពីស៊ុតកូតហៅថា អំប្រីយ៉ុង ។ អំប្រីយ៉ុងមានហើយជាស្រេចនូវឫស ដើម និងស្លឹក ។ នៅក្នុងគ្រាប់ទាំងអស់ អំប្រីយ៉ុងដែលមានក្លែបមួយឬពីរ ហៅថាកូទីឡេដុង ។ ចំពោះគ្រាប់រុក្ខជាតិខ្លះ អាហាររបស់វាស្តុកទុកក្នុងកូទីឡេដុង ។ រុក្ខជាតិខ្លះទៀត អាហារស្តុកទុកនៅខាងក្រៅអំប្រីយ៉ុង ។ រូបភាពទី 5.4 ប្រៀបធៀបទម្រង់ខុសៗគ្នានៃគ្រាប់ពោត សណ្តែក និងស្រល់ ។

## ខ. ឫសរុក្ខជាតិ

ឫសមាននាទីសំខាន់បីយ៉ាង ។ ឫសភ្ជាប់រុក្ខជាតិទៅនឹងដី ស្រូបទឹកនិងសារធាតុខនិជពីដី ហើយជួនកាលស្តុកអាហារទុកទៀតផង ។

រូបទី 5.5 បង្ហាញពីរូបផ្តុំរបស់ឫសមួយ ។ គួរកត់សំគាល់ថា នៅផ្នែកខាងចុងឫសត្រូវបានព័ទ្ធជុំវិញនិងការពារដោយទម្រង់មួយដែលហៅថាមួក ។ មួកការពារឫសក្នុងការប៉ះទង្គិចនិងថ្មនៅពេលឫសលូតលាស់ពីដី ។ ផ្នែកខាងក្រោយបន្ទាប់ពីមួកមានកោសិកាជាច្រើនធ្វើចំណែក ដើម្បីបង្កើតកោសិកាឫសថ្មីៗទៀត ។ រោមជញ្ជក់លូតលាស់ចេញពីផ្ទៃរបស់ឫស ។ រោមឆ្មារៗទាំងនេះអាចជ្រៀតចូលទៅក្នុងដីដើម្បីស្រូបទឹកនិងសារធាតុខនិជ ។



រូបទី5.5 រូបផ្តុំឫស

ជាលិកាសរសៃនាំស្ថិតនៅផ្នែកកណ្តាលនៃឫស ។ ទឹកនិងសារធាតុខនិជដែលត្រូវបានស្រូបចេញពីដី ធ្វើដំណើរយ៉ាងរហ័សទៅក្នុងស៊ីឡែម ។ សារធាតុទាំងនេះត្រូវបានដឹកនាំពីឫសតាមស៊ីឡែមឆ្ពោះទៅកាន់ដើមនិងស្លឹករុក្ខជាតិ ។ ផ្លូវអែមដឹកនាំអាហារដែលផលិតបាននៅក្នុងស្លឹកទៅកាន់ឫស ។ បន្ទាប់មក ជាលិកាឫសអាចប្រើប្រាស់អាហារនេះសម្រាប់លូតលាស់ឬស្តុកទុកដើម្បីឱ្យរុក្ខជាតិប្រើប្រាស់ទៅថ្ងៃក្រោយ ។

## គ. ដើមរុក្ខជាតិ

ដើមរុក្ខជាតិមាននាទីសំខាន់ពីរយ៉ាង ។ ដើមដឹកនាំសារធាតុរវាងឫសនិងស្លឹករុក្ខជាតិ ។ ដើមជាទម្ររបស់រុក្ខជាតិនិងទ្រស្លឹកឡើងដើម្បីឱ្យស្លឹករុក្ខជាតិបែរទៅរកពន្លឺថ្ងៃ ។ ផ្អែកលើរូបផ្ដុំរបស់ដើម គេចែកដើមរុក្ខជាតិជារុក្ខជាតិស្មៅនិងរុក្ខជាតិឈើ ។រុក្ខជាតិស្មៅមានដើមទន់ហើយ



រូបទី 5.6 រុក្ខជាតិស្មៅ

គ្មានជាតិឈើទេ ។ទាំងរុក្ខជាតិស្មៅនិងរុក្ខជាតិឈើដើមរបស់វាសុទ្ធតែមានជាលិកាផ្លូអែមនិងស៊ីឡែម ។ រូបទី 5.6 បង្ហាញពីរូបផ្ដុំក្នុងរបស់ដើមរុក្ខជាតិស្មៅ ។

## ឃ. ស្លឹករុក្ខជាតិ



រូបទី 5.7 រូបផ្ដុំស្លឹក

ស្លឹកមានទ្រង់ទ្រាយនិងទំហំខុសៗគ្នាយ៉ាងខ្លាំង ។ ដោយមិនគិតពីទ្រង់ទ្រាយខុសៗគ្នារបស់វា ស្លឹកមាននាទីយ៉ាងសំខាន់ចំពោះរុក្ខជាតិ ។ ស្លឹកចាប់យកថាមពលពន្លឺព្រះអាទិត្យហើយផលិតអាហារក្នុងដំណើររស្មីសំយោគ ។ បើយើងកាត់ស្លឹករុក្ខជាតិហើយពិនិត្យតាមគែមដែលកាត់នោះដោយមីក្រូទស្សន៍ អ្នកនឹងឃើញរូបផ្ដុំដូចក្នុងរូបទី 5.7 ។

ស្រទាប់ក្រៅបង្អស់នៃផ្នែកក្រោមនិងខាងលើផ្ទៃស្លឹក មាននាទីការពារកោសិកាខាងក្នុង ។ នៅចន្លោះស្រទាប់កោសិកាទាំងនេះមានទ្រនុងដែលមានស៊ីឡែមនិងផ្លូអែម ។ នៅលើស្រទាប់ផ្ទៃរបស់ស្លឹកមានស្តូម៉ាត ។ រន្ធនេះបើកនិងបិទនៅពេលឧស្ម័នចូលនិងចេញពីស្លឹក ។ នៅពេលស្តូម៉ាតបើកឱ្យឧស្ម័នកាបូនិចចូលទៅក្នុងស្លឹក ហើយអុកស៊ីសែននិងចំហាយទឹកចេញពីស្លឹកមកវិញ ។

## មេរៀនសង្ខេប

- រុក្ខជាតិស្ទើរទាំងអស់ ជាសារពាង្គកាយស្វ័យជីពដែលផលិតអាហារដោយខ្លួនឯង ។ រុក្ខជាតិជាសារពាង្គកាយពហុកោសិកា (អឺការីយ៉ូត)ដែលកោសិការបស់វាព័ទ្ធជុំវិញដោយភ្នាសគ្រោង ។ រុក្ខជាតិទាំងអស់ចែកជាពីរក្រុម : រុក្ខជាតិគ្មានសរសៃនាំនិងរុក្ខជាតិមានសរសៃនាំ ។ វដ្តជីវិតរបស់រុក្ខជាតិមានពីរដំណាក់កាលគឺ ស្ប៉័រ៉ូភីតនិងកាម៉េតូភីត ។
- រុក្ខជាតិគ្មានសរសៃនាំមានស្លែនិងអេប៉ាទិច ។ វាគ្មានដើម ស្លឹក និងឫសពិតប្រាកដទេ ។ វារស់នៅក្នុងតំបន់សើម ហើយអាចស្រូបទឹកនិងសារធាតុចិញ្ចឹមដោយផ្ទាល់ពីដី ។
- រុក្ខជាតិមានសរសៃនាំមានប៉ប្រកនិងរុក្ខជាតិមានគ្រាប់ ។ រុក្ខជាតិមានសរសៃនាំមានដើម ឫស និងស្លឹកពិតប្រាកដ ។ ឫសភ្ជាប់រុក្ខជាតិទៅនឹងដីហើយស្រូបយកទឹកនិងសារធាតុចិញ្ចឹមពីដីមកវិញ ។ ដើមដឹកនាំសារធាតុរវាងឫសនិងស្លឹក ។ វាទ្រទ្រង់រុក្ខជាតិនិងទ្រស្លឹក ។ ស្លឹកចាប់យកថាមពលពន្លឺព្រះអាទិត្យសម្រាប់ធ្វើរស្មីសំយោគ ។
- ប៉ប្រកគ្មានគ្រាប់ទេ វាបន្តពូជដោយស្ប៉ ។ រុក្ខជាតិមានគ្រាប់ប្រើប្រាស់លំអងនិងគ្រាប់សម្រាប់បន្តពូជ ។

## សំណួរនិងលំហាត់

1. តើដំណាក់កាលទាំងពីរនៃវដ្តជីវិតរុក្ខជាតិមានអ្វីខ្លះ ?
2. ដូចម្តេចហៅថារុក្ខជាតិគ្មានសរសៃនាំ ? រុក្ខជាតិមានសរសៃនាំ ?
3. រុក្ខជាតិមានសរសៃនាំនិងរុក្ខជាតិគ្មានសរសៃនាំខុសគ្នាដូចម្តេច ?
4. តើស្លែជារុក្ខជាតិដូចម្តេច ?
5. តើលក្ខណៈសំខាន់ពីរយ៉ាងរបស់រុក្ខជាតិមានគ្រាប់គឺអ្វីខ្លះ ?
6. ចូរប្រាប់ឈ្មោះផ្នែកទាំងបីរបស់គ្រាប់និងនាទីរបស់ផ្នែកនីមួយៗ ។

# ពិសោធន៍ : សង្កេតជាលិកាសរសៃនាំរបស់រុក្ខជាតិ

## 1. វត្ថុបំណង

- សង្កេតជាលិកាសរសៃនាំរបស់រុក្ខជាតិ
- បង្ហាញបាច់សរសៃនាំរបស់រុក្ខជាតិ ។

## 2. សម្ភារៈ

ល័ក្តក្រហម ដបជ័រ ទឹក ត្រកួន 1-2 ទង ។

## 3. ដំណើរការ




- យកទឹកប្រហែល 50ml និងល័ក្តក្រហមដាក់ក្នុងដបរួចកូរឬក្រឡុករហូតដល់ល័ក្តរលាយអស់ ។
- យកត្រកួនដាក់ត្រាំក្នុងទឹកល័ក្តក្រហមនោះ ។
- ទុករយៈពេល 24 ម៉ោង ។
- កាត់ទងត្រកួនរួចសង្កេតជាលិកាសរសៃនាំ ។

ចំណាំ : គ្រូអាចរៀបចំដំណើរការពិសោធនេះឱ្យបានហើយស្រេចមុនមួយថ្ងៃ ។

## 4. វិភាគ

ហេតុអ្វីបានជាសារធាតុខនិជនិងទឹកដែលស្រូបដោយឫសអាចឡើងទៅដល់ស្លឹកបាន ។

## 5. សន្និដ្ឋាន

តាមរយៈពិសោធន៍នេះ តើអ្នកសង្កេតឃើញដូចម្តេច ចំពោះការស្រូបទឹកនិងសារធាតុខនិជរបស់រុក្ខជាតិ ?

មេរៀនទី

# 6 សត្វ

**ចប់មេរៀននេះ សិស្សអាច**

- ❒ បង្ហាញពីជំងឺមួយចំនួនដែលបណ្ដាលពីសត្វឥតឆ្អឹងកង
- ❒ ប្រៀបធៀបសត្វឆ្អឹងកងនិងសត្វឥតឆ្អឹងកង
- ❒ មានសញ្ញាណពីលក្ខណៈពិសេសរបស់សត្វទាំងប្រាំថ្នាក់ ។

សារពាង្គកាយពហុកោសិកាដែលស្ថិតនៅក្នុងរជ្ជៈសត្វផ្ដុំឡើងដោយជាលិកា សរីរាង្គ និងប្រព័ន្ធសរីរាង្គឬប្រដាប់ ។ ខុសពីរុក្ខជាតិ សត្វគ្មានក្លរ៉ូភីលទេ ។ ដូចនេះ វាមិនអាចផលិតអាហារដោយខ្លួនឯងបានទេ ។ សត្វទាំងអស់ចែកជាពីរក្រុមគឺ ក្រុមសត្វឥតឆ្អឹងកងដែលគ្មានឆ្អឹងកងខ្នងនិងក្រុមមួយទៀតជាសត្វឆ្អឹងកងដែលមានឆ្អឹងកងខ្នង ។ ក្នុងដើមឈើមែកធាងពូជអម្បូរ ក្រុមសត្វឆ្អឹងកងមានសាខាតែមួយក្រុម ឯក្រុមសត្វឥតឆ្អឹងកងមានសាខាច្រើន ដូចបង្ហាញក្នុងរូបទី 6.1 ។




*រូបទី6.1 : ដើមឈើមែកធាងពូជអម្បូរសត្វ*

| ក្រុម | សាខា |
|---|---|
| សត្វឆ្អឹងកង | សត្វឆ្អឹងកង (ត័រដេ) |
| សត្វឥតឆ្អឹងកង | អេប៉ុង ស្ទីដារីយ៉ា ដង្កូវខ្លួនសំប៉ែត ដង្កូវខ្លួនមូល ដង្កូវខ្លួនកង់ សិប្បិសត្វ អាកត្រូប៉ូត អេគីណូឌែម |

# 1. សត្វឥតឆ្អឹងកង

នៅក្នុងសាខាសត្វឥតឆ្អឹងកង យើងសិក្សាពីដង្កូវខ្លួនសំប៉ែត ដង្កូវខ្លួនមូលនិងដង្កូវខ្លួនកង់តែប៉ុណ្ណោះ ។

## 1.1 ដង្កូវខ្លួនសំប៉ែត

ដង្កូវខ្លួនសំប៉ែត មានរាងសំប៉ែតទន់ ។ ដង្កូវខ្លះមានប្រវែង 10 ទៅ 12m ខ្លះទៀតតូចមានប្រវែង 1mm ។ ដង្កូវខ្លះរស់នៅដោយសេរីហើយហែលយ៉ាងលឿនលើដុំថ្មក្នុងស្រះឬរំអិលខ្លួនលើដីសើម ។ ដង្កូវខ្លះទៀតជាបរាសិតក្នុងសារពាង្គកាយធ្មូល ។ រូបទី 6.2 បង្ហាញពីវដ្តជីវិតរបស់ដង្កូវខ្លួនសំប៉ែតដែលពឹងពាក់លើធ្មូលពីរគឺ មនុស្សនិងសត្វខ្យង ។



*រូបទី 6.2 : វដ្តជីវិតរបស់ដង្កូវក្នុងឈាម*

ដង្កូវខ្លួនសំប៉ែតមួយផ្សេងទៀតដែលបរាសិតលើមនុស្សគឺ តេញ៉ា ។ ពេលពេញវ័យ តេញ៉ាមានប្រវែងរហូតដល់ 10m ។ ក្បាលរបស់វាមានឈ្នប់និងទំពក់សម្រាប់ថ្គក់ជាប់ទៅនឹងពោះវៀន ។ មនុស្ស

និងកើតជំងឺនេះ នៅពេលគេបរិភោគសាច់គោឬសាច់ជ្រូកដែលមានគីសដោយមិនបានសម្លាប់ឬចម្អិនមិនបានឆ្អិនល្អ ។ រូបភាពទី 6.3 បង្ហាញពីវដ្តជីវិតរបស់តេញ៉ា ។



*រូបទី 6.3: វដ្តជីវិតតេញ៉ា*

អ្នកកើតជំងឺនេះ មានអាការៈរមួលពោះ រសេះរសោះ ក្អួតចង្អោរ បរិភោគច្រើនតែស្គមហើយខ្សោយ ។

## 1.2 ដង្កូវខ្លួនមូល



① មនុស្សបរិភោគអាហារឬទឹកដែលមានពងព្រូន ។

② ស៊ុតញាស់នៅក្នុងពោះវៀនតូច ។

③ កូនញាស់ចូលក្នុងសរសៃឈាមហើយធ្វើដំណើរទៅសួត ។

④ កូនញាស់ធ្វើដំណើរទៅបំពង់កហើយត្រូវបានលេប ។

⑤ ព្រូនពេញវ័យរស់នៅក្នុងពោះវៀនតូច ។

⑥ ពងព្រូនធ្លាក់មកជាមួយលាមក ។

*រូបទី 6.4: វដ្តជីវិតព្រូន*

ដង្កូវខ្លួនមូល មានរាងមូលស្រួចចុងដើម ។ វារស់នៅក្នុងទឹក លើដី ខ្លះទៀតជាបរាសិតក្នុងសារពាង្គកាយភាវៈរស់ដទៃទៀត ។ ដង្កូវខ្លួនមូលមានព្រូននិងអៀនជាដើម ។

ព្រូនជាសត្វចង្រៃដែលរស់នៅជាបរាសិតលើមនុស្សចាស់និងកូនក្មេង ។ វាជាសត្វឯកភេទ ។ ព្រូនញីមួយពងបានរាប់ម៉ឺនស៊ុត ។ រូបទី 6.4 បង្ហាញពីវដ្តជីវិតរបស់ព្រូននៅក្នុងសារពាង្គកាយមនុស្ស ។

## 1.3 ដង្កូវខ្លួនកង់

ដង្កូវខ្លួនកង់មានរាងជាកង់ៗ ខ្លះវែង ខ្លះទៀតខ្លី ។ ក្នុងក្រុមនេះមានឈ្លើង (បរាសិតក្រៅ)និងជន្លេន ។ ជន្លេនមានស្បែកស្ដើងហើយសើម ។ បណ្ដូរឧស្ម័នធ្វើឡើងដោយឆ្លងកាត់ស្បែក ។ ជន្លេនមានប្រដាប់រត់ឈាមបិទ ។




*រូបទី6.5 : រូបផ្ដុំជន្លេន*




*រូបទី6.6 : ការបន្តពូជជន្លេន*

ជន្លេនជាសត្វទ្វេភេទ ។ ជន្លេនមួយមានភេទពីរ ហើយបង្កើតកាម៉េតបាន2ប្រភេទ ។ ប៉ុន្តែវាមិនធ្វើស្វ័យបង្កកំណើតទេ ។ ពេលពាក់គ្នាជន្លេន 2 ភ្ជាប់គ្នាផ្នែកពោះនិងក្បាល ហើយប្ដូរកាម៉េតគ្នា ។ ជន្លេននីមួយៗរក្សាកាម៉េតដែលវាទទួលបានក្នុងថង់ពិសេសមួយ ។ ស៊ុតបង្កកំណើតត្រូវបានរុំព័ទ្ធដោយជាតិស្លេស្មខាប់ដែលបញ្ចេញដោយចង្កំសម្រាប់ការពារស៊ុត ។ រយៈពេល 3-4 អាទិត្យក្រោយកូនជន្លេននឹងចេញពីស្លេស្ម ។

ជន្លេនជាដង្កូវខ្លួនកង់ដែលមានប្រយោជន៍ ។ វាស៊ីស្លឹកឈើនិងរូបធាតុពុករលួយ ។ ជន្លេនធ្វើឱ្យដីមានជីជាតិនិងធូរដែលងាយដល់ការលូតលាស់របស់រុក្ខជាតិ ។ វាក៏ជាអាហាររបស់ត្រីនិងបក្សីផងដែរ ដូចជា មាន់ ទាជាដើម ។

# 2. សត្វឆ្អឹងកង

សត្វឆ្អឹងកង ជាសត្វដែលមានឆ្អឹងកងខ្នង ។ ឆ្អឹងខ្នងជាផ្នែកមួយនៃគ្រោងឆ្អឹងក្នុង ។ គ្រោងឆ្អឹងក្នុងទ្រទ្រង់រាងកាយនិងជួយឱ្យសារពាង្គកាយផ្លាស់ទីបាន ។ ក្រៅពីនេះ វាជួយបង្កើនទំហំនៅពេលសត្វរីកធំធាត់ ដោយមិនបាច់ជម្រុះគ្រោងឆ្អឹងចោលនៅពេលរីកទំហំមិនដូចសត្វល្អិតដែលមានគ្រោងឆ្អឹងក្រៅទេ ។

ឆ្អឹងខ្នងកើតឡើងពីបណ្ដុំឆ្អឹងកងជាច្រើនដែលបន្តគ្នាជាជួរ ។ សន្លាក់ចល័តរវាងឆ្អឹងកងនីមួយៗធ្វើឱ្យឆ្អឹងអាចបត់បែនបាន ។ អ្នកអាចឱនទៅមុខព្រោះឆ្អឹងអ្នកអាចពត់បាន ។ ក្នុងឆ្អឹងកងនីមួយៗមានប្រហោងដែលមានខួរឆ្អឹងខ្នង ។

សត្វឆ្អឹងកងមាន5ថ្នាក់គឺ ថ្នាក់ត្រី អំភីប និងល្មូន(សត្វអថេរកម្ដៅ )ហើយបក្សី និងថនិកសត្វ (សត្វថេរកម្ដៅ) ។

## 2.1 ថ្នាក់ត្រី

ត្រីជាសត្វឆ្អឹងកងរស់ក្នុងទឹក វាប្រើប្រាស់ព្រុយសម្រាប់ហែល ។ សារពាង្គកាយគ្របដណ្ដប់ដោយស្រកាស្ដើងសំប៉ែត ។ ត្រីដកដង្ហើមតាមស្រកី ។

### ក. រូបផ្ដុំត្រី




*រូបទី6.7 : រូបផ្ដុំត្រី*

រូបទី 6.7 បង្ហាញពីរូបផ្ដុំត្រី ។ គួរកត់សំគាល់ថា ត្រីមានប្លោកខ្យល់ដែលពេញដោយឧស្ម័ន ។ ប្លោកខ្យល់នេះជួយឱ្យត្រីមានលំនឹងក្នុងជម្រៅទឹកខុសៗគ្នា ។

### ខ. ប្រដាប់របត់ឈាម

ត្រីចាប់យកអុកស៊ីសែនដែលរលាយក្នុងទឹក ។ ទឹកចូលតាមមាត់ ហើយបញ្ចេញតាមស្រកី ។ នៅលើស្រកីមានសរសៃឈាមឆ្មារៗ ។ ពេលទឹកស្រោចលើស្រកី អុកស៊ីសែនសាយចូលក្នុងសរសៃឈាម ។ ព្រមពេលគ្នាដែរ ឧស្ម័នកាបូនិចសាយចេញពីសរសៃឈាមក្នុងស្រកីចូលទៅក្នុងទឹកវិញ ។ ចេញពីស្រកីអុកស៊ីសែនត្រូវបានដឹកនាំតាមឈាមទៅគ្រប់កោសិកាទាំងអស់តាមប្រដាប់របត់ឈាមបិទ ។ បេះដូងត្រីមាន 2ថត ។ បេះដូងត្រីរុញឈាមមួយជុំគឺ ចេញពីបេះដូងទៅស្រកី ចេញពីស្រកីទៅផ្នែកផ្សេងៗនៃរាងកាយ បន្ទាប់មកត្រឡប់មកបេះដូងវិញ ដូចបង្ហាញក្នុងរូបទី 6.8 ។




*រូបទី6.8 : របត់ឈាមត្រី*

### គ. ការបន្តពូជ

ត្រីភាគច្រើនមានការបង្កកំណើតក្រៅដែលប្រព្រឹត្តទៅនៅក្នុងទឹក ។ ត្រីញីបញ្ចេញស៊ុតមកក្រៅ ត្រីឈ្មោលហែលពីលើត្រីញី ហើយបញ្ចេញស្ពែម៉ាតូសូអ៊ីតទៅលើស៊ុត ដើម្បីបង្កកំណើត ។ កូនញាស់លូតលាស់ក្រៅសារពាង្គកាយមេ ដោយសារចំណីអាហារដែលមាននៅក្នុងថង់ពោះរបស់វា ។

## 2.2 ថ្នាក់អំភីប

អំភីប ជាសត្វឆ្អឹងកងអថេរកម្តៅដែលមានលទ្ធភាពរស់នៅលើគោកផងនិងក្នុងទឹកផង ។ ពាក្យអំភីបមានន័យថារស់នៅក្នុងមជ្ឈដ្ឋានពីរ ។ កូនញាស់រស់នៅក្នុងទឹក ដល់ពេលពេញវ័យវារស់នៅលើដី ហើយត្រឡប់ទៅក្នុងទឹកវិញដើម្បីបន្តពូជ ។ ថ្នាក់អំភីបមានលំដាប់ពីរគឺ លំដាប់សាឡាម៉ង់ (មានកន្ទុយ) និងលំដាប់កង្កែបនិងគីង្គក់ (គ្មានកន្ទុយ) ។

## ក. រូបផ្គុំកង្កែប




*រូបទី6.9 : រូបផ្គុំកង្កែប*

## ខ. ប្រដាប់របត់ឈាម

កង្កែបទើបនិងញាស់ប្រើប្រាស់ស្រកីដើម្បីចាប់យកអុកស៊ីសែនពីក្នុងទឹកដែលវារស់នៅក្នុងរយៈពេលបម្រែរូប ។ កង្កែបពេញវ័យដកដង្ហើមតាមសួត និងស្បែក ។ កូនក្អុកមានប្រដាប់របត់ឈាមទោល បេះដូងមាន2ថតដូចត្រី ។ ប៉ុន្តែកង្កែបពេញវ័យមានប្រដាប់របត់ឈាមទ្វេ បេះដូងមាន3ថត ។ ថតលើ2សម្រាប់ទទួលឈាម ។ ថតលើមួយទទួលឈាមសម្បូរអុកស៊ីសែនពីសួតហើយថតលើមួយទៀតទទួលឈាមខ្សត់អុកស៊ីសែនពីសរីរាង្គ ។ ចេញពីថតលើឈាមធ្វើចលនាចូលថតក្រោមដោយរុញឈាមទៅសួតនិងទៅសរីរាង្គដូចបង្ហាញក្នុងរូបទី 6. 10 ។




*រូបទី6.10 : របត់ឈាមកង្កែប*

### គ. ការបន្តពូជនិងការលូតលាស់

កង្កែបបន្តពូជនៅរដូវភ្លៀង ។ កង្កែបឈ្មោលបញ្ចេញសំឡេងទាក់ទាញកង្កែបញី ។ កង្កែបញីបញ្ចេញស៊ុត កង្កែបឈ្មោលបញ្ចេញស្ពែម៉ាតូសូអ៊ីតស្រោចលើស៊ុត ។ ស៊ុតបង្កកំណើតក្រៅសារពាង្គកាយមេ ។ រូបទី 6.11 បង្ហាញពីវដ្ត នៃការលូតលាស់របស់កង្កែប ។



*រូបទី6.11 : វដ្តជីវិតសត្វកង្កែប*

## 2.3 ថ្នាក់ល្មូន

ល្មូនជាសត្វឆ្អឹងកងអថេរកម្តៅដែលដកដង្ហើមតាមសួត ។ ស្បែករបស់វាគ្របដណ្តប់ដោយស្រកាក្រាស់ ។ ពស់ ជីងចក់ ថ្លែន អណ្តើក ក្រពើ ជាល្មូន ។ ល្មូនបន្សាំទាំងស្រុងទៅនិងជីវិតលើគោក ។ អណ្តើករស់នៅក្នុងទឹក ប៉ុន្តែវានៅតែដកដង្ហើមតាមសួត ។ អណ្តើកពងលើគោក ។ ស្បែកតម្រងនោម និងស៊ុតមានសំបកការពារ នេះជាលក្ខណៈបន្សាំទៅនិងការរក្សាទឹកក្នុងរាងកាយ ។

ល្មូនធ្វើការបង្កកំណើតក្នុងសារពាង្គកាយមេ ហើយបញ្ចេញស៊ុតនៅលើដី ។ ពេលនៅក្នុងរាងកាយមេ ស៊ុតត្រូវបានរុំព័ទ្ធដោយភ្នាសនិងសំបកសម្រាប់ការពារការលូតលាស់របស់អំប្រីយ៉ុងនិងរក្សាការបាត់បង់ជាតិទឹក ។ អំប្រីយ៉ុងត្រូវបានការពារដោយទឹកភ្លោះ ។ ស៊ុតស្តុកអាហារដែលកើតពីខ្លាញ់និង ប្រូតេអ៊ីនសម្រាប់ចិញ្ចឹមជីវិតអំប្រីយ៉ុងនៅពេលកំពុងលូតលាស់ ។



*រូបទី6.12 : ស៊ុតល្មូន*

ភ្នាសអាឡង់ត័រវាប់រងដំណកដង្ហើមនិងការបញ្ចេញចោល ។ រន្ធតូចៗរបស់សំបកស៊ុត អនុញ្ញាតឱ្យអុកស៊ីសែនចូលក្នុងស៊ុតនិងឱ្យឧស្ម័នកាបូនិចចេញពីស៊ុត ។

## 2.4 បក្សី

បក្សីជាសត្វឆ្អឹងកងថេរកម្តៅ ។ខ្លួនរបស់វាគ្របដណ្តប់ដោយរោមនិងស្លាប ។ បក្សីផ្លាស់ទីដោយការហើរយ៉ាងរហ័ស ។ បេះដូងបក្សីមាន4ថត ។

## ក. ប្រដាប់របត់ឈាមនិងប្រដាប់ដង្ហើម




*រូបទី6.13 : ប្រដាប់ដង្ហើមបក្សី*




*រូបទី6.14 : របត់ឈាមបក្សី*

ពេលហើរបក្សីត្រូវការថាមពលច្រើន ដូចនេះកោសិកាទាំងឡាយត្រូវតែទទួលបានអុកស៊ីសែនច្រើន ដើម្បីបញ្ចេញថាមពលដែលស្តុកទុកនៅក្នុងម៉ូលេគុលអាហារ ។ បក្សីមានសរីរាង្គដែលបន្សុំាទៅនឹងការហើរ ដូចជាប្រព័ន្ធថង់ខ្យល់ដែលភ្ជាប់ទៅនឹងសួត(រូបទី 6.13) ។ ថង់ខ្យល់នេះអាចឱ្យបក្សីទទួលបានអុកស៊ីសែនច្រើន នៅពេលបក្សីស្រូបខ្យល់ចូលម្តងៗ ។ ក្រៅពីប្រព័ន្ធថង់ខ្យល់ ឆ្អឹងប្រហោងក៏ជួយសម្រាលទម្ងន់បក្សីក្នុងការហើរផងដែរ ។

បេះដូងបក្សីមាន 4 ថតគឺ ថតលើ 2 និងថតក្រោម 2 ។ បក្សីមានប្រព័ន្ធរបត់ឈាមទ្វេ(រូបទី 6.14) ។ បេះដូងស្តាំរបស់បក្សីរុញឈាមខ្សត់អុកស៊ីសែនទៅសួតដែលនៅទីនោះមានការចាប់យកអុកស៊ីសែនពីបរិយាកាស ។ ឈាមសម្បូរអុកស៊ីសែនត្រូវបានបញ្ជូនពីសួតទៅកាន់បេះដូងឆ្វេងដែលបន្ទាប់មកបេះដូងរុញឈាមនេះទៅកាន់សរីរាង្គទាំងអស់នៃរាងកាយ ។

## ខ. ការបន្តពូជ

បក្សីធ្វើការបង្កកំណើតក្នុងនិងភ្ញាស់ស៊ុត ។ ស៊ុតបក្សីមានលក្ខណៈដូចស៊ុតរបស់ល្មូនដែរ ប៉ុន្តែសំបករបស់វារឹងជាងសំបកស៊ុតល្មូន ។ ស៊ុតបក្សីលូតលាស់នៅសីតុណ្ហភាពប្រហាក់ប្រហែលនឹងកម្តៅខ្លួនបក្សី ដូចនេះបក្សីមេត្រូវតែក្រាបពងដើម្បីផ្តល់កម្តៅឱ្យដល់ស៊ុត ។ ពេលស៊ុតញាស់ កូនបក្សីចោះសំបកស៊ុតចេញមកក្រៅ ។ ក្រោយពេលញាស់ កូនបក្សីខ្លះអាចដើររកចំណីដោយខ្លួនឯងបានភ្លាម (មាន់ ទា . . .) ។ កូនបក្សីខ្លះទៀតត្រូវការឱ្យមេបញ្ចុកអាហារវារហូតដល់វាចេះហើរបាន (ចាប ព្រាប . . .) ។

## 2.5 ថនិកសត្វ

ថនិកសត្វ ជាសត្វឆ្អឹងកងថេរកម្តៅដែលមានស្បែកគ្របដណ្តប់ដោយរោម ។ ថនិកសត្វមេចិញ្ចឹមកូនដោយទឹកដោះដែលបញ្ចេញដោយក្រពេញទឹកដោះ ។ ថនិកសត្វខ្លះរស់ក្នុងទឹក(ត្រីបាឡែន)ខ្លះរស់នៅលើដើមឈើហើយផ្លាស់ទីដោយហើរ (ប្រចៀវ) ភាគច្រើនដើរលើដី ។

## ក. រូបផ្ទុំថនិកសត្វ

រូបទី 6.15 បង្ហាញពីរូបផ្ទុំរបស់ថនិកសត្វ ។

## ខ. ប្រដាប់របត់ឈាម

ថនិកសត្វដកដង្ហើមតាមសួត ។ វាមានសន្ទះទ្រូងដែលខណ្ឌផ្នែកទ្រូងនិងពោះ ។ សួតមានផ្ទៃសើមដ៏ធំល្វឹងល្វើយសម្រាប់ធ្វើបណ្តូរឧស្ម័នរវាងខ្យល់ក្នុងសួតទៅនឹងឈាមនៅក្នុងសរសៃឈាម ។ ដូចបក្សីដែរ ថនិកសត្វមានបេះដូង 4ថត ។ ថនិកសត្វមានប្រដាប់របត់ឈាមទ្វេដូចបក្សី ។ ប្រដាប់របត់ឈាមបែបនេះមានប្រសិទ្ធិភាពក្នុងការចាប់យកអុកស៊ីសែន ($O_2$) ទៅឱ្យកោសិកា ។




*រូបទី6.15 : រូបផ្ទុំថនិកសត្វ*

## គ. ការបន្តពូជ

ការបន្តពូជធ្វើឡើងក្នុងសារពាង្គកាយមេ ។ អំប្រីយ៉ុងលូតលាស់យ៉ាងយូរក្នុងស្បូន ហើយចិញ្ចឹមជីវិតដោយសារសុករបស់មេ រហូតដល់ប្រព័ន្ធទាំងអស់នៃរាងកាយកូនអាចដំណើរការបានដោយឯករាជ្យ ។ អាហារនិងអុកស៊ីសែនឆ្លងកាត់ពីសុកម្តាយទៅទារក ។ កាកសំណល់និងឧស្ម័នកាបូនិចឆ្លងកាត់ពីទារកទៅសារពាង្គកាយមេដែលបន្ទាប់មកត្រូវបំបាត់ចោលតាមរយៈប្រដាប់បញ្ចេញចោលរបស់មេ ។ ទងសុកភ្ជាប់កូនទៅនឹងសុករបស់មេ ។ ក្រោយកំណើត កូនត្រូវបានថែរក្សានិងចិញ្ចឹមដោយទឹកដោះរបស់មេ ។

### មេរៀនសង្ខេប

- ដង្កូវខ្លួនសំប៉ែត មានរាងសំប៉ែតហើយទន់ ។ ដង្កូវខ្លះជាបរាសិតលើកោសិកាធ្មុលដូចជាតេញ៉ាជាដើម ។ មនុស្សមានបរាសិតតេញ៉ាក្នុងខ្លួនកាលណាគេបរិភោគសាច់ជ្រូកឬសាច់គោដែលមិនបានចម្អិនឬសម្លាប់គីសបានល្អ ។
- ដង្កូវខ្លួនមូល មានរាងមូលស្រួចចុងដើម ។ វារស់ជាបរាសិតលើសារពាង្គកាយធ្មុល ដូចជាព្រូនជាដើម ។ ព្រូនជាសត្វឯកភេទដែលធ្វើការបង្កកំណើតក្នុង ។
- ដង្កូវខ្លួនកង់ មានខ្លួនវែងហើយសារពាង្គកាយចែកជាកង់ៗ ។ ជន្លេនជាសត្វទ្វេភេទ ។ ប៉ុន្តែវាមិនធ្វើស្វ័យបង្កកំណើតទេ ។ ជន្លេនមានប្រយោជន៍ដោយធ្វើឱ្យដីធូរនិងមានជីជាតិ ។ វាគឺជាចំណីរបស់ត្រីនិងបក្សីផងដែរ ។

- ត្រី ជាសត្វឆ្អឹងកងមុនគេបង្អស់ដែលបន្សាំជីវិតក្នុងទឹក អាស្រ័យដោយមានសរីរាង្គដូចជា ព្រុយ ស្រកា ស្រកី ប្លោកខ្យល់ជាដើម ។ ត្រីជាសត្វអថេរកម្ដៅ ឯកភេទ ហើយការបង្ក កំណើតប្រព្រឹត្តទៅក្រៅសារពាង្គកាយនិងនៅក្នុងទឹក ។
- អំភឹបជាសត្វអថេរកម្ដៅរស់ក្នុងទឹក ដោយដកដង្ហើមតាមស្រកី (កូនក្អុក) ។ បន្ទាប់មកវាទៅរស់នៅលើគោកដោយដកដង្ហើមតាមសួត ។ ពេលពេញវ័យវាចុះក្នុងទឹកដើម្បីបន្តពូជ ។ ការបង្កកំណើតប្រព្រឹត្តទៅក្រៅសារពាង្គកាយ ។
- ល្មូនជាសត្វអថេរកម្ដៅ រស់នៅលើគោក ។ ល្មូនខ្លះរស់នៅក្នុងទឹកដូចជា អណ្ដើក ក្រពើជាដើម ។ ល្មូនមានស្បែកក្រាស់ តម្រងនោម ស៊ុតរុំព័ទ្ធដោយសំបកដែលការពារការបាត់បង់ជាតិទឹក ។ ការបង្កកំណើតប្រព្រឹត្តទៅក្នុងសារពាង្គកាយមេ ដោយបញ្ចេញជាស៊ុតរួចញាស់ ។
- បក្សីជាសត្វអថេរកម្ដៅខ្លួនរបស់វាគ្របដណ្ដប់ដោយរោមនិងស្លាប ។ បក្សីមានសរីរាង្គដែលបន្សាំទៅនឹងការហើរ ដូចជាស្លាប ថង់ខ្យល់ ឆ្អឹងប្រហោង ។ ការបង្កកំណើតប្រព្រឹត្តទៅក្នុងសារពាង្គកាយមេដោយបញ្ចេញជាស៊ុត ហើយមេក្រាបពងដើម្បីភ្ញាស់កូន ។
- ថនិកសត្វជាសត្វថេរកម្ដៅ ។ វាចិញ្ចឹមកូនដោយទឹកដោះ ។ ថនិកសត្វខ្លះរស់នៅក្នុងទឹក (ត្រីបាឡែន) ខ្លះហើរលើអាកាស (ប្រជៀវ) និងខ្លះទៀតនៅលើដី (ជ្រូក គោ ក្របី . . .) ។ ការបង្កកំណើតប្រព្រឹត្តទៅក្នុងសារពាង្គកាយមេ ។ អំប្រីយ៉ុងលូតលាស់យូរនៅក្នុងស្បូនហើយរស់បានអាស្រ័យដោយសុករបស់មេ ។ ទងសុកភ្ជាប់រវាងសុកមេទៅនឹងកូន ។ កូនកើតមកចិញ្ចឹមជីវិតដោយទឹកដោះរបស់មេ ។

## ? សំណួរនិងលំហាត់

1. ដូចម្ដេចហៅថាសត្វឥតឆ្អឹងកង ?
2. ដូចម្ដេចហៅថាសត្វឆ្អឹងកង ?
3. ចូរពណ៌នាពីវដ្ដជីវិតរបស់គេញ៉ា ។
4. ចូរប្រៀបធៀបប្រដាប់របត់ឈាមត្រីនិងបក្សី ?
5. តើត្រីបន្តពូជដូចម្ដេច ?
6. តើថនិកសត្វបន្តពូជដូចម្ដេចដែរ ?

## ពិសោធន៍ : ការសង្កេតសរីរាង្គក្នុងរបស់ត្រី

**1.** វត្ថុបំណង

សង្កេតមើលសរីរាង្គផ្សេងៗក្នុងសារពាង្គកាយត្រី ។

**2.** សម្ភារៈ

ត្រីក្អែករស់ ក្តារសម្រាប់វះសាច់ កូនកន្ត្រៃវះសាច់ ។

**3.** ដំណើរការ

- ពេលប្រើសម្ភារៈមុតស្រួចត្រូវប្រុងប្រយ័ត្ននិងត្រូវអនុវត្តតាមការណែនាំរបស់គ្រូអ្នក ។
- យកត្រីដាក់នៅលើក្តារវះសាច់ ។ បន្ទាប់មកយកផ្នែកខាងចុងនៃកូនកន្ត្រៃ ស៊កចូលតាមក្លូអាក់ ហើយកាត់ថ្នមៗពីក្លូអាក់ទៅដល់ផ្នែក គម្របស្រកី ( ចំណុច3.3 ) ។
- បន្ទាប់មកកាត់ពីក្លូអាក់ទៅកន្លែងខ្សែរឆ្នូតចំហៀង រួចបន្តទៅដល់គម្របស្រកី( ចំណុច3.4 ) ។ ចៀរយកសាច់ត្រីមួយផ្នែកនោះចេញដូចបង្ហាញក្នុងរូប ( ចំណុច3.5 ) ។




**4.** សន្និដ្ឋាន

ក. ចូរសង្កេតមើលសរីរាង្គផ្សេងៗរបស់ត្រីដែលអ្នកអាចមើលឃើញក្នុងពេលពិសោធន៍ ។

ខ. ចូរផ្ទៀងផ្ទាត់សរីរាង្គទាំងនេះជាមួយរូបភាពដែលបង្ហាញក្នុងសៀវភៅ ។

## ? សំណួរនិងលំហាត់ជំពូក1

I. ចូរគូសសញ្ញា ( ✓) ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. វិទ្យាសាស្ត្រដែលសិក្សាពីការធ្វើចំណែកថ្នាក់ភាវៈរស់ហៅថា

☐ក. ការវិវត្ត ☐ខ. ជីវវិទ្យា ☐គ. តាក់សូណូមី ☐ឃ. ការលូតលាស់ ។

2. ពួកបែងចែកជា

☐ក. អម្ប្រូ ☐ខ. ប្រភេទ ☐គ. ថ្នាក់ ☐ឃ. សាខា ។

3. ប្រវត្តិនៃការវិវត្តរបស់សារពាង្គកាយមួយប្រភេទឬមួយក្រុមហៅថា

☐ក. ដើមឈើមែកធាងពូជអម្ប្រូ ☐គ. បម្រែរូបរបស់កង្កែប

☐ខ. ចំណែកថ្នាក់ភាវៈរស់ ☐ឃ. វដ្តជីវិតរបស់រុក្ខជាតិ ។

4. ប្រព័ន្ធចំណែកថ្នាក់របស់លីណេ ហៅភាវៈរស់សំគាល់ដោយពាក្យ

☐ក. មួយម៉ាត់ ☐ខ. ពីរម៉ាត់ ☐គ. បីម៉ាត់ ☐ឃ. បួនម៉ាត់ ។

5. រុក្ខជាតិគ្មានសរសៃនាំមាន

☐ក. ស្លែនិងអេប៉ាទិច ☐ខ. អេប៉ាទិចនិងសារាយ

☐គ. ស្លែនិងបំប្រេក ☐ឃ. បំប្រេកនិងរុក្ខជាតិមានគ្រាប់ ។

6. ជំងឺដែលបណ្តាលមកពីវីរុសគឺ

☐ក. គ្រុនផ្តាសាយ ☐ខ. លើសឈាម ☐គ. ទឹកនោមផ្អែម ☐ឃ. ស្រែង ។

7. បាក់តេរីដែលមានរាងមូលហៅថា

☐ក. កុកស៊ី ☐ខ. ស្ពៀរីឡូម ☐គ. បាស៊ី ☐ឃ. កូឡូនី ។

8. ការចេញពន្លកជាការបន្តពូជរបស់

☐ក. ផ្សិតផ្ទះ ☐ខ. ដំបែ ☐គ. ក្រា ☐ឃ. ផ្សិតធំ ។

9. សរីរាង្គដែលផលិតទឹកដោះដើម្បីចិញ្ចឹមកូនហៅថា

☐ក. ក្រពេញទឹកដោះ ☐ខ. សុក ☐គ. ស៊ុត ☐ឃ. តែ ។

10. សត្វដែលមិនមែននៅក្នុងថ្នាក់ល្មូនជា

☐ក. ថ្លែន ☐ខ. ពស់ ☐គ. អណ្តើក ☐ឃ. សាឡាម៉ង់ ។

11. កូនក្អុកជាកូនញាស់របស់

☐ក. ត្រី ☐ខ. សាឡាម៉ង់ ☐គ. កង្កែបឬគីង្គក់ ☐ឃ. ពស់ឬថ្លែន ។

II. ចូរបំពេញចន្លោះនៃ ឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. កម្រិតតូចជាងគេបំផុតនៅក្នុងប្រព័ន្ធចំណែកថ្នាក់គឺ . . . . . . . . . . . . . ។
2. កម្រិតធំជាងគេនៅក្នុងប្រព័ន្ធចំណែកថ្នាក់គឺ . . . . . . . . . . . . ។
3. សរីរាង្គ . . . . . . . . . . ជាសរីរាង្គដែលមានទម្រង់ក្នុងដូចគ្នាតែមាននាទីផ្សេងៗគ្នា ។
4. សរីរាង្គ . . . . . . . . . . ជាសរីរាង្គដែលមាននាទីដូចគ្នាតែមានទម្រង់ក្នុងខុសគ្នា ។
5. វីរុសដែលបរាសិតនៅលើបាក់តេរីជា . . . . . . . . . . . . ។
6. បាក់តេរីមានរូបរាងបីបែប . . . . . . . . . . ស្ពៀរីឡូមនិង . . . . . . ។
7. ការបន្តពូជដោយភេទរបស់បាក់តេរីហៅថា . . . . . . . . . . . ។
8. អាមីបប្រើប្រាស់ . . . . . . . . . . . ដើម្បីផ្លាស់ទីនិងចាប់អាហារ ។
9. ស្ប៉រ៉ូសូអ៊ែដែលបង្កជំងឺគ្រុនចាញ់ដល់មនុស្សឈ្មោះថា. . . . . . . . . . . . . ។
10. ប្រូទីសសត្វដែលផ្លាស់ទី ដោយរោមញ័រជា . . . . . . . . . . . ។
11. អឺគ្លែនមានលក្ខណៈជា . . . . . . . . . . . និង. . . . . . . . . . ។
12. កោសិការបស់ផ្សិតភាគច្រើនមានរូបរាងជា . . . . . . . . . . . . ។
13. ផ្សិតបន្តពូជដោយ . . . . . . ដែលស្ថិតនៅក្នុងសរីរាង្គពិសេសមួយហៅថា . . . . . . . ។
14. ផ្សិតផ្ទួរ . . . . . . . . . ផលិតសារធាតុម្យ៉ាងដែលសម្លាប់បាក់តេរីនៅក្បែរវា ។
15. ក្រោយពីរបកគំហើញថ្នាំពេនីស៊ីលីន ប្រភេទថ្នាំ . . . . . . . . ផ្សេងទៀតត្រូវបានផលិតចេញពីបាក់តេរីនិងផ្សិត ។
16. រុក្ខជាតិគ្មានសរសៃនាំមាន . . . . . . . . . . . . និង . . . . . . . . . . . ។
17. បណ្ណង្គជាតិជារុក្ខជាតិ . . . . . . . . . . . ។
18. ជាលិកាសរសៃនាំបង្កឡើងពី . . . . . . . . . . . .និង . . . . . . . . . . . . ។
19. ឧស្ម័នចូលនិងចេញពីស្លឹកតាម . . . . . . . . . . . ។
20. ដង្កូវខ្លួនសំប៉ែត . . . . . . . . . . .បរាសិតក្នុងខ្លួនមនុស្ស ។
21. ដង្កូវខ្លួនកង់ដែលជួយឱ្យដីមានជីជាតិគឺ . . . . . . . . . . ។

22. កង្កែបទើបនឹងញាស់ប្រើប្រាស់ ..........ដើម្បីដកដង្ហើម ។នៅពេលពេញវ័យ វាដកដង្ហើមតាម.......... និងស្បែក ។

23. បេះដូងត្រីមាន ............ដែលវាច់រងរបត់ឈាមទោល ។

24. អំប្រីយ៉ុងល្មូនត្រូវបានការពារដោយ ..........។

25. សរីរាង្គរបស់បក្សីដែលបន្សាំនឹងការហើរគឺ ..........។

26. បេះដូងបក្សីមាន ............ដែលវាច់រងរបត់ឈាមទ្វេ ។

III. ចូរឆ្លើយសំណួរខាងក្រោមនេះ :

1. ហេតុអ្វីបានជាជីវវិទូធ្វើចំណែកថ្នាក់ ?

2. ការធ្វើអត្តសញ្ញាណសារពាង្គកាយ ដោយឈ្មោះវិទ្យាសាស្ត្រមានអត្ថប្រយោជន៍អ្វី ?

3. ចូរពន្យល់ហេតុអ្វីបានជាគេថាបាក់តេរីជាកោសិកាប្រូការីយ៉ូត ?

4. ហេតុអ្វីបានជាគេថាផ្សិតជារុក្ខជាតិគ្មានសរសៃនាំ ?

5. តើលីកែនជាសារពាង្គកាយដូចម្តេច ? ហេតុអ្វី ?

6. ប្រសិនបើសារាយត្រូវវិនាសបាត់អស់ពីក្នុងទឹក តើនឹងមានអ្វីកើតឡើង ចំពោះភាវៈរស់នៅលើផែនដី?

7. តើប្រូទីសផ្សិតមានលក្ខណៈដូចផ្សិតត្រង់កន្លែងណា?

8. ចំពោះរុក្ខជាតិ តើដំណាក់កាលស្ប៉ូរ៉ូភីតខុសពីកាម៉េតូភីតដូចម្តេច ?

9. ហេតុអ្វីបានជាបក្សីអាចហើរបានឆ្ងាយ?

10. ចូរពណ៌នាពីប្រដាប់របត់ឈាមទ្វេរបស់ថនិកសត្វ ?

# ជំពូក 2 ឯកសណ្ឋានភាពនៃភាវៈរស់



តើសត្វ ស្មៅ ដើមឈើ និងមនុស្សមានលក្ខណៈរួមអ្វីដែលដូចគ្នា ? ដោយសារភាវៈទាំងនេះជាសារពាង្គកាយ ដូចនេះវាបង្កឡើងពីកោសិកា។ តើកោសិកានៃភាវៈរស់ទាំងនេះមានលក្ខណៈដូចគ្នានិងខុសគ្នាដូចម្តេចដែរ ?

**មេរៀនទី 1 : កោសិកា**

**មេរៀនទី 2 : ប្រូការីយ៉ូតនិងអឺការីយ៉ូត**

មេរៀនទី

# 1 កោសិកា

**ចប់មេរៀននេះ សិស្សអាច**

- ❑ បង្ហាញថាកោសិកាជាអ្វី
- ❑ ធ្វើអត្តសញ្ញាណអំពីធាតុកោសិកា
- ❑ ប្រៀបធៀបកោសិកាសត្វនិងកោសិការុក្ខជាតិ ។

គ្រប់សារពាង្គកាយសុទ្ធតែបង្កឡើងដោយកោសិកា។ កោសិកា ជាឯកតាបង្កនៃរូបផ្តុំនិងនាទីរបស់សារពាង្គកាយឬភាវៈរស់ ។

## 1. ទំហំនិងរូបផ្តុំកោសិកា

### 1.1 ទំហំកោសិកា

ក្នុងសារពាង្គកាយមានកោសិកាច្រើនប្រភេទ ។ ក្នុងធម្មជាតិមានសារពាង្គកាយឯកកោសិកាច្រើនប្រភេទ ។ អ្នកអាចមើលឃើញអាមីបដែលមានប្រវែង 1mm ដោយភ្នែកទទេបាន ។ ប៉ុន្តែអ្នកមិនអាចមើលឃើញកោសិកាថ្ពាល់របស់អ្នកដោយមិនប្រើមីក្រូទស្សន៍បានទេ ។ កោសិកានេះ មានប្រវែង 0.01mm ។ រូបភាពទី 1.1 បង្ហាញអំពីទំហំខុសៗគ្នារបស់កោសិកានៅក្នុងសារពាង្គកាយ ។




*រូបទី 1.1 ទំហំខុសៗគ្នារបស់កោសិកា*

### 1.2 រូបផ្តុំកោសិកា

ក្នុងរូបភាពទី1.2 បង្ហាញអំពី ធាតុកោសិកា នៅក្នុងកោសិការុក្ខជាតិនិងសត្វដែលពិនិត្យដោយមីក្រូទស្សន៍ ។

- **ភ្នាសគ្រោង** (ឬភ្នាសសែលុយឡូស) ជាស្រទាប់រឹងនៃរូបធាតុគ្មានជីវិតដែលនៅព័ទ្ធជុំវិញកោសិការុក្ខជាតិ ។ កោសិកាសត្វគ្មានភ្នាសគ្រោងនេះទេ ។ វាមាននាទីទ្រទ្រង់និងការពារកោសិកា ។
- **ភ្នាសស៊ីតូប្លាស** : គ្រប់កោសិកាមានភ្នាសស៊ីតូប្លាស ។ ភ្នាសនេះស្ថិតនៅផ្នែកខាងក្នុងនៃភ្នាសគ្រោង ។ វាត្រួតពិនិត្យការចូលទៅក្នុងកោសិកានិងការចេញពីកោសិការបស់សារធាតុមួយចំនួន ។ សារធាតុចិញ្ចឹមនិងអុកស៊ីសែនចូលទៅក្នុងកោសិកាដោយឆ្លងកាត់តាមភ្នាសស៊ីតូប្លាសនេះ ។
- **ស៊ីតូប្លាស** : សារធាតុខាប់អន្ទិលដែលស្ថិតនៅចន្លោះណ្វៃយ៉ូនិងភ្នាសស៊ីតូប្លាស មានចលនាជាប់ជានិច្ច ។
- **ណ្វៃយ៉ូ** : មជ្ឈមណ្ឌលត្រួតពិនិត្យរបស់កោសិកា ។ ក្រូម៉ូសូមដែលស្ថិតនៅក្នុងណ្វៃយ៉ូ ផ្ទុកសម្ភារៈតំណពូជ សម្រាប់ដឹកនាំគ្រប់សកម្មភាពរបស់កោសិកា ។
- **មីតូកុងទ្រី** : មជ្ឈមណ្ឌលផលិតថាមពលរបស់កោសិកា ។ ក្នុងមីតូកុងទ្រី អាហារងាយមានស្ករជាដើមត្រូវបានបំបែកជាទឹកនិង $CO_2$ ដោយបញ្ចេញបរិមាណថាមពលយ៉ាងច្រើន ។ កោសិកាប្រើប្រាស់ថាមពលនេះដើម្បីដឹកនាំសកម្មភាពផ្សេងៗក្នុងកោសិកា។
- **ក្លរ៉ូប្លាស** : មានតែនៅក្នុងកោសិការុក្ខជាតិប៉ុណ្ណោះ ។ ជាតិពណ៌បៃតងនៅក្នុងក្លរ៉ូប្លាសគឺក្លរ៉ូភីលដែលមាននាទីចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយប្រើប្រាស់ថាមពលនេះ ដើម្បីផលិតអាហារសម្រាប់កោសិកា ។




*រូបទី 1.2 រូបផ្ចឹកោសិការុក្ខជាតិនិងសត្វ*

- **វ៉ាគុយអូល** : កោសិការុក្ខជាតិភាគច្រើនមានវ៉ាគុយអូលធំមួយ ។ វាជាកន្លែងស្តុកអាហារ និងរូបធាតុចាំបាច់ផ្សេងៗទៀតរបស់កោសិកា ។ វាក៏ជាកន្លែងស្តុកកាកសំណល់មេតាបូលីស ផងដែរ ។

## 2. រូបរាងផ្សេងៗរបស់កោសិកា

នៅក្នុងសារពាង្គកាយនីមួយៗ មានកោសិកាច្រើនប្រភេទដែលមានរូបរាងខុសៗគ្នា ។ រូបរាងកោសិកានីមួយៗតម្រូវទៅនឹងនាទីរបស់វានៅក្នុងសារពាង្គកាយ ។




*រូបទី 13 រូបរាងផ្សេងៗរបស់កោសិកាសត្វ*

### មេរៀនសង្ខេប

- កោសិកាជាឯកតាបង្កនៃរូបផ្គុំនិងនាទីរបស់សារពាង្គកាយ ។
- កោសិកានីមួយៗមានផ្នែកសំខាន់បីគឺ ភ្នាសស៊ីតូប្លាស ស៊ីតូប្លាស និងណ្វៃយ៉ូ ។ ក្នុងស៊ីតូប្លាសមានធាតុកោសិកាច្រើន ដូចជាមីតូកុងទ្រី វ៉ាគុយអូល ក្លរ៉ូប្លាស . . . ។
- កោសិកានីមួយៗមានរូបរាងខុសៗគ្នាដែលតម្រូវទៅតាមនាទីរបស់វា ។

## ? សំណួរនិងលំហាត់

1. តើកោសិកាជាអ្វី ?
2. ចូររាប់ឈ្មោះធាតុកោសិកានិងនាទីរបស់វា ។
3. តើកោសិកាសត្វនិងរុក្ខជាតិមានចំណុចដូចគ្នានិងខុសគ្នាអ្វីខ្លះ ?

# ពិសោធន៍ : ការសង្កេតកោសិកាសត្វនិងកោសិការុក្ខជាតិ

**1.** វត្ថុបំណង : - សង្កេតផ្នែកផ្សេងៗរបស់កោសិកានិងធាតុកោសិកា

- ប្រៀបធៀបកោសិកាសត្វនិងកោសិការុក្ខជាតិ ។

**2.** សម្ភារៈ : មីក្រូទស្សន៍ បន្ទះកញ្ចក់ បន្ទះកញ្ចក់ស្តើង ឈើចាក់ធ្មេញសំប៉ែត កូនតង្កៀប ចកកន្ទុយក្អែ ទឹកមេទីឡែន។

**3.** ដំណើរការ

## ក. កោសិការុក្ខជាតិ




- យកកូនតង្កៀបដកយកកូនស្លឹកមួយដោយប្រុងប្រយ័ត្ន ចេញពីផ្នែកខាងក្រោមក្បែរត្រួយចកកន្ទុយក្អែ ។ ដាក់ស្លឹកទាំងមូលក្នុងតំណក់ទឹកនៅលើបន្ទះកញ្ចក់ ហើយគ្របវាដោយបន្ទះកញ្ចក់ស្តើង ។
- ចូរសង្កេតមើលរូបផ្តុំកោសិកានៅក្នុងស្លឹកចកកន្ទុយក្អែដោយប្រើអុបសិចទីបលេខតូច បន្ទាប់មកបង្វិលយកអុបសិចទីបលេខធំដើម្បីមើលឱ្យបានច្បាស់ ។ ចូរសង្កេតផ្នែកផ្សេងៗនៃកោសិកា ។
- ចូររកកោសិកាចកកន្ទុយក្អែណាមួយដែលអ្នកអាចមើលឃើញក្លរ៉ូប្លាសច្បាស់ ។ គូររូបកោសិកានេះ ហើយដាក់ចំណងជើងភ្នាសគ្រោង ក្លរ៉ូប្លាសនិងផ្នែកផ្សេងៗទៀតដែលអ្នកអាចមើលឃើញ ។

## ខ. កោសិកាសត្វ




- យកផ្នែកសំប៉ែតនៃឈើចាក់ធ្មេញ កោសយកកោសិកាផ្នែកខាងក្នុងថ្ពាល់របស់អ្នកថ្នមៗ ។ បន្ទាប់មកយកចុងឈើចាក់ធ្មេញនោះផ្តិតថ្នមៗនៅលើបន្ទះកញ្ចក់ ។
- បន្ថែមសូលុយស្យុងខៀវមេទីឡែនមួយតំណក់ ហើយរង់ចាំ1 - 2 វិនាទី ។ បន្ទាប់មកយកបន្ទះកញ្ចក់ស្តើងគ្របពីលើថ្នមៗ ។
- ពិនិត្យមើលកោសិកាក្នុងមីក្រូទស្សន៍ដោយប្រើអុបសិចទីបលេខតូច បន្ទាប់មកលេខធំ ។ ចូរគូរកោសិកាថ្ពាល់មួយដោយដាក់ចំណងជើងផ្នែកផ្សេងៗនៃកោសិកានេះ ។

**4.** សន្និដ្ឋាន : ប្រៀបធៀបកោសិកាទាំងពីរខាងលើ ។

មេរៀនទី

# 2 ប្រូការីយ៉ូតនិងអឺការីយ៉ូត

**ចប់មេរៀននេះ សិស្សអាច**

- ❒ បង្ហាញអត្តសញ្ញាណកោសិកាប្រូការីយ៉ូតនិងអឺការីយ៉ូត
- ❒ ប្រៀបធៀបកោសិកាប្រូការីយ៉ូតនិងអឺការីយ៉ូត ។

## 1. ប្រូការីយ៉ូត



*រូបទី 2.1 ប្រូការីយ៉ូត (បាក់តេរី)*

ប្រូការីយ៉ូត ជាសារពាង្គកាយឯកកោសិកាដែលគ្មានណ្វៃយ៉ូពិតប្រាកដ ។ វាគ្មានធាតុកោសិកាដូចជា មីតូកុងឌ្រី គ្លរ៉ូប្លាស និងភ្នាសដែលនៅព័ទ្ធជុំវិញធាតុកោសិកាទាំងនេះ ។ ដោយគ្មានភ្នាសព័ទ្ធជុំវិញសម្ភារៈតំណពូជ ដូចនេះប្រូការីយ៉ូតមិនអាចដំណើរការនូវសកម្មភាពពិសេសៗបានឡើយ ។ ប្រូការីយ៉ូតដំបូងមានអាយុយ៉ាងតិចណាស់ 3,5 រយកោដិឆ្នាំកន្លងមក ។ វាជាសារពាង្គកាយងាយ ហើយតូចល្អិតអង្កត់ផ្ចិតពី 1 – 2μm ។ ប្រូការីយ៉ូតបច្ចុប្បន្នតូចល្អិតដូចបុព្វសត្វរបស់វាមានអង្កត់ផ្ចិតពី 1 – 15μm ។ ប្រូការីយ៉ូតធ្លាប់ស្គាល់ដែលបង្កជំងឺដល់មនុស្សនិងបណ្តាលឱ្យអាហារខូចស្ថិតនៅក្នុងក្រុមតែមួយគឺ បាក់តេរី ។

ប្រូការីយ៉ូតមាននៅគ្រប់ទីកន្លែង ។ បាក់តេរីខ្លះដែលបណ្តាលឱ្យមានជំងឺធ្ងន់ដល់មនុស្សក៏ស្ថិតនៅក្នុងក្រុមប្រូការីយ៉ូតនេះដែរ ។ វាលូតលាស់និងបន្តពូជយ៉ាងរហ័ស ។ ខ្លះរស់នៅមិនត្រូវការ $O_2$ ខ្លះទៀតមិនអាចរស់នៅក្នុងកន្លែងគ្មាន $O_2$ ទេ ។ ខ្លះទៀតអាចផលិតអាហារបានដោយខ្លួនឯង ។

## 2. អឺការីយ៉ូត



*រូបទី2.2 : កោសិកាអឺការីយ៉ូត(កោសិកាសត្វ)*

អឺការីយ៉ូត ជាសារពាង្គកាយដែលកោសិការបស់វាមានណ្វៃយ៉ូពិតប្រាកដ ។ ណ្វៃយ៉ូជាកន្លែងផ្ទុកសម្ភារៈតំណពូជរបស់កោសិកា ។ ក្នុងស៊ីតូប្លាសមានធាតុកោសិកាជាច្រើនដែលជួយឱ្យកោសិកាអឺការីយ៉ូតធ្វើសកម្មភាពតាមវិធីផ្សេងៗ

ខុស អំពីប្រូការីយ៉ូត។ ធាតុកោសិកាទាំងនោះគឺ មីតូកុងឌ្រី ក្លរ៉ូប្លាស និងវ៉ាគុយអូល។ ធាតុកោសិកាទាំងនោះមានរូបផ្ដុំខុសៗគ្នាដែលតម្រូវទៅនឹងនាទីខុសៗគ្នានៅក្នុងកោសិកា។ អឺការីយ៉ូតមានប្រូទីស ផ្សិត រុក្ខជាតិ និងសត្វ។

## 3. ប្រៀបធៀបរវាងប្រូការីយ៉ូតនិងអឺការីយ៉ូត

តារាងសង្ខេបលក្ខណៈប្រូការីយ៉ូតនិងអឺការីយ៉ូត

| ក្រុម | ប្រូការីយ៉ូត | អឺការីយ៉ូត |
|---|---|---|
| រជ្ជៈ |  បាក់តេរី |  ប្រូទីស  ផ្សិត  រុក្ខជាតិ  សត្វ |
| សម្ភារៈតំណពូជ | គ្មានភ្នាសណ្វៃយ៉ូរុំព័ទ្ធសម្ភារៈតំណពូជ | សម្ភារៈតំណពូជស្ថិតក្នុងណ្វៃយ៉ូដែលមានភ្នាសរុំព័ទ្ធជុំវិញ។ |
| ធាតុកោសិកា | ស៊ីតូប្លាស ភ្នាសស៊ីតូប្លាស ភ្នាសគ្រោង | ស៊ីតូប្លាស ភ្នាសគ្រោង ភ្នាសស៊ីតូប្លាស មីតូកុងឌ្រី ក្លរ៉ូប្លាស |

### មេរៀនសង្ខេប

- កោសិកាដែលគ្មានណ្វៃយ៉ូពិតប្រាកដនិងគ្មានធាតុកោសិកាដូចជា មីតូកុងឌ្រី ក្លរ៉ូប្លាស ហៅថាប្រូការីយ៉ូត។ ប្រូការីយ៉ូតទាំងនេះ ជាបាក់តេរី។
- កោសិកាដែលមានណ្វៃយ៉ូពិតប្រាកដនិងធាតុកោសិកាដូចជា មីតូកុងឌ្រី ក្លរ៉ូប្លាស វ៉ាគុយអូល ហៅថា អឺការីយ៉ូត។ សារពាង្គកាយអឺការីយ៉ូតមានប្រូទីស ផ្សិត រុក្ខជាតិ និងសត្វ។

### សំណួរនិងលំហាត់

1. តើកោសិកាប្រូការីយ៉ូតមានលក្ខណៈពិសេសដូចម្ដេចខ្លះ ?
2. តើកោសិកាអឺការីយ៉ូតមានលក្ខណៈពិសេសដូចម្ដេចខ្លះ ?

## ? សំណួរនិងលំហាត់ជំពូក 2

**I. ចូរគូសសញ្ញា ( ✓ ) ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1. ថាមពលកោសិកាផលិតនៅក្នុង

☐ ក. ណៃ្វយ៉ូ ☐ ខ. ប្រដាប់កុលស៊ី ☐ គ. វ៉ាគុយអូល ☐ ឃ. មីតូកុងឌ្រី ។

2. ចំពោះរុក្ខជាតិ ធាតុកោសិកាដែលផលិតអាហារគឺ

☐ ក. ក្លរ៉ូប្លាស ☐ ខ. មីតូកុងឌ្រី ☐ គ. ណៃ្វយ៉ូ ☐ ឃ. ប្រដាប់កុលស៊ី ។

3. ទឹក អាហារ និងសារធាតុផ្សេងៗផ្ទុកក្នុង

☐ ក. មីតូកុងឌ្រី ☐ ខ. វ៉ាគុយអូល ☐ គ. ក្លរ៉ូប្លាស ☐ ឃ. ណៃ្វយ៉ូ ។

**II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ**

1. មជ្ឈមណ្ឌលផលិតថាមពលរបស់កោសិកាគឺ . . . . . . . . . . ។
2. សម្ភារៈតំណពូជរបស់កោសិកាអឺការីយ៉ូតស្ថិតនៅក្នុង . . . . . . . . . . ។
3. ជាតិពណ៌បៃតងរបស់រុក្ខជាតិគឺ . . . . . . . ដែលស្ថិតនៅ . . . . . . . . . . ។
4. បាក់តេរីជាឯកកោសិកា . . . . . . . . . . ។
5. សារពាង្គកាយដែលកោសិការបស់វាមានណៃ្វយ៉ូពិតប្រាកដជា . . . . . . . . . . ។

**III. ចូរឆ្លើយសំណួរខាងក្រោមនេះ**

1. ចូរប្រៀបធៀបកោសិកាសត្វនិងកោសិការុក្ខជាតិ ។
2. ចូរប្រៀបធៀបពីនាទីរបស់ភ្នាសស៊ីតូប្លាសនិងភ្នាសក្រោង ។
3. ចូរពន្យល់ប្រយោគនេះ "កោសិកាជាឯកតាបង្កនៃរូបផ្គុំនិងនាទីរបស់សារពាង្គកាយ " ។
4. តើធាតុកោសិកាណាមួយដែលគេឱ្យឈ្មោះវាជា "មជ្ឈមណ្ឌលនៃថាមពល"របស់កោសិកា ? ហេតុអ្វីបានជាគេដាក់ឈ្មោះឱ្យវាដូច្នេះ ?
5. ចំពោះកោសិកាមួយដែលអ្នកមិនធ្លាប់ស្គាល់ តើអ្នកគួរវិនិច្ឆ័យបែបណាដើម្បីឱ្យដឹងថា វាជាកោសិកាសត្វ កោសិការុក្ខជាតិ ឬបាក់តេរី ។
6. ចូរបង្កើតតារាងមួយ ដោយសរសេរឈ្មោះធាតុកោសិកានៅក្នុងជួរម្ខាង ហើយសរសេរអំពី នាទីនីមួយៗដែលទាក់ទងទៅនឹងធាតុកោសិកានោះនៅជួរម្ខាងទៀត ។

# ជំពូក 3 មេតាបូលីស



បុរសនេះត្រូវការថាមពលដើម្បីកាប់គាស់ដីដាំដំណាំ ។ តើថាមពលទាំងនេះបានមកពីណា ? ចម្លើយងាយបំផុតគឺ " បានមកពីអាហារដែលពួកគេបរិភោគ " ។ កោសិកាប្រើប្រាស់ថាមពលគីមីដែលស្តុកទុកក្នុងអាហារសម្រាប់ធ្វើសកម្មភាពផ្សេងៗចាំបាច់នៃជីវិតដូចជា ការផ្លាស់ទី ការលូតលាស់ ការស្វែងរកចំណី ការរំលាយអាហារ ដំណកដង្ហើម . . . ។ ប្រសិនបើគ្មានថាមពល ជីវិតនឹងត្រូវបញ្ឈប់ភ្លាម ។ សកម្មភាពទាំងនេះផ្តើមចេញពីប្រតិកម្មគីមីផ្សេងៗដែលកើតមាននៅក្នុងកោសិកា ។ គ្រប់ប្រតិកម្មគីមីទាំងអស់នៅក្នុងសារពាង្គកាយហៅថា " មេតាបូលីស " ។

## មេរៀនទី 1 : រស្មីសំយោគ

## មេរៀនទី 2 : ដង្ហើមកោសិកា

មេរៀនទី

# 1 ស្នើសំយោគ

**ចប់មេរៀននេះ សិស្សអាច**

- ❒ រៀបរាប់ពីប្រភពថាមពលដែលភាវៈរស់ទទួលបាន
- ❒ បកស្រាយពីដំណាក់កាលទាំងពីរនៃរស្មីសំយោគ
- ❒ ពន្យល់ពីសារៈសំខាន់នៃរស្មីសំយោគនៅក្នុងបរិស្ថាន
- ❒ មានស្មារតីថែរក្សាធនធានធម្មជាតិ ។

## 1. ប្រភពថាមពល



នៅលើវាលស្មៅដ៏ធំមួយ សត្វក្តាន់មួយក្រុមកំពុងស៊ីស្មៅយ៉ាងសុខសាន្ត ។ ភ្លាមនោះ ពួកវាមានការតក់ស្លុតយ៉ាងខ្លាំង ដោយមានសត្វខ្លាមួយក្រុមកំពុងតែវាយលុកមកលើហ្វូងរបស់វា ។ សត្វខ្លាទាំង

នោះបានសម្លាប់សត្វក្តាន់មួយហើយស៊ីសាច់វា ។ ទាំងសត្វក្តាន់ ទាំងសត្វខ្លាត្រូវការអាហារដើម្បីចិញ្ចឹមជីវិតដូចគ្នា ។ ពួកវាទទួលបានថាមពលពីអាហារដែលវាស៊ី ។ ដូចនេះភាវៈរស់នីមួយៗត្រូវការថាមពល ។ កោសិកាទាំងអស់ក៏ត្រូវការថាមពលដែរ ដើម្បីបំពេញនាទីរបស់វា ដូចជាការផលិតប្រូតេអ៊ីននិងដំណឹកនាំសារធាតុចូលទៅក្នុងកោសិកានិងចេញពីកោសិកា ។ សាច់ក្តាន់ផ្តល់ថាមពលឱ្យកោសិការបស់សត្វខ្លាដែលត្រូវការថាមពល ឯស្មៅក៏ផ្តល់ថាមពលទៅឱ្យកោសិការបស់សត្វក្តាន់ដែរ ។ ប៉ុន្តែរុក្ខជាតិនិងសារពាង្គកាយផ្សេងទៀត ដូចជាសារាយនិងបាក់តេរីមួយចំនួន ទទួលបានថាមពលតាមរបៀបផ្សេងៗពីគ្នា ។ សារពាង្គកាយទាំងនេះ ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យដើម្បីផលិតអាហាររបស់ខ្លួន ។

## 2. រស្មីសំយោគជាអ្វី ?




*រូបទី1.2 : ការផ្ទេរថាមពល*

ភាវៈរស់ស្ទើរទាំងអស់ ទទួលបានថាមពលដោយផ្ទាល់ឬប្រយោលពីថាមពលពន្លឺព្រះអាទិត្យក្នុងរយៈពេលធ្វើរស្មីសំយោគ ។ស្មៅប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យដោយផ្ទាល់ ពីព្រោះវាផលិតអាហារនៅពេលរស្មីសំយោគ ។ នៅពេលក្តាន់ស៊ីស្មៅ វាទទួលបានថាមពលដែលស្តុកទុកនៅក្នុងស្មៅនោះ ។ ក៏ដូចគ្នាដែរ សត្វខ្លាទទួលបានថាមពលដែលស្តុកទុកក្នុងសាច់ក្តាន់ ។ សត្វទាំងពីរនេះទទួលបានថាមពលពន្លឺព្រះអាទិត្យដោយប្រយោលពីថាមពលដែលស្មៅទទួលបានដោយសាររស្មីសំយោគ ។

ដំណើរការដែលកោសិកាចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយប្រើប្រាស់ថាមពលនេះដើម្បីផលិតអាហារ ហៅថា **រស្មីសំយោគ** ។ ពាក្យរស្មីសំយោគជាពាក្យក្រេចគឺ **រស្មី** មានន័យថា ពន្លឺ សំយោគមានន័យថា ការរួមបញ្ចូលគ្នា ។

រុក្ខជាតិផលិតអាហារតាមរយៈដំណើររស្មីសំយោគ ។ សារពាង្គកាយដែលផលិតអាហាររបស់វាដោយផ្ទាល់ ហៅថា **ស្វ័យជីព** ។ សារពាង្គកាយដែលមិនអាចផលិតអាហាររបស់វាដោយផ្ទាល់បាន ហៅថា **បរជីព** ។

ពួកបរជីពជាច្រើនទទួលបានអាហារតាមការស៊ីសារពាង្គកាយដទៃទៀត ។ ឯពួកបរជីពមួយចំនួនទៀតដូចជាផ្សិតស្រូបយកអាហារពីសារពាង្គកាយផ្សេងទៀត ។

## 3. ដំណាក់កាលទាំងពីរនៃរស្មីសំយោគ

រស្មីសំយោគជាដំណើរការមួយស្មុគ្រស្មាញ ។ ក្នុងពេលធ្វើរស្មីសំយោគ រុក្ខជាតិនិងសារពាង្គកាយមួយចំនួនផ្សេងទៀត ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីបំប្លែងឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ឱ្យទៅជាឧស្ម័នអុកស៊ីសែន ($O_2$) និងស្ករ ។ រស្មីសំយោគអាចចែកចេញជាពីរដំណាក់កាលគឺ ការចាប់យកថាមពលពន្លឺព្រះអាទិត្យនិងការផលិតស្ករ ។

### 3.1 ដំណាក់កាលទី 1 : ការចាប់យកថាមពលពន្លឺព្រះអាទិត្យ




*រូបទី 1.3 : ការចាប់យកថាមពលពន្លឺព្រះអាទិត្យដោយក្លរ៉ូប្លាស*

ដំណាក់កាលទី1 នៃដំណើររស្មីសំយោគពាក់ព័ន្ធទៅនឹងការចាប់យកថាមពលពន្លឺព្រះអាទិត្យ ។ ចំពោះរុក្ខជាតិ ការចាប់យកថាមពលនេះភាគច្រើនកើតមាននៅក្នុងស្លឹករុក្ខជាតិតែប៉ុណ្ណោះ ។ គួររំលឹកផងដែរថា ក្លរ៉ូប្លាសជាធាតុកោសិកាពណ៌បៃតងដែលស្ថិតនៅក្នុងកោសិការុក្ខជាតិ ។ ពណ៌បៃតងនេះបានមកពីប្រព័ន្ធជាតិពណ៌ដែលមាននាទីស្រូបយកពន្លឺ ។ ជាតិពណ៌សំខាន់នៅក្នុងក្លរ៉ូប្លាសដែលប្រើប្រាស់សម្រាប់ចាប់យកថាមពលពន្លឺក្នុងពេលរស្មីសំយោគជា **ក្លរ៉ូភីល** ។

ក្លរ៉ូភីលមាននាទីប្រហាក់ប្រហែលទៅនឹងបន្ទះកញ្ចក់ច្រើពន្លឺព្រះអាទិត្យនៅក្នុងម៉ាស៊ីនគិតលេខដែលប្រើថាមពលពន្លឺព្រះអាទិត្យ ។ បន្ទះកញ្ចក់នេះចាប់យកថាមពលពន្លឺ ហើយប្រើប្រាស់វាដើម្បីធ្វើឱ្យម៉ាស៊ីនគិតលេខដំណើរការបាន ។ ចំពោះក្លរ៉ូភីលក៏ដូចគ្នាផងដែរ វាចាប់យកថាមពលពន្លឺហើយប្រើប្រាស់ដើម្បីធ្វើឱ្យដំណាក់កាលទី2 នៃដំណើររស្មីសំយោគអាចដំណើរការបាន ។

## ៣.2 ដំណាក់កាលទី 2 : ការប្រើប្រាស់ថាមពលសម្រាប់ផលិតអាហារ

នៅក្នុងដំណាក់កាលទី2 កោសិកាប្រើប្រាស់ថាមពលដែលចាប់បាននេះ ដើម្បីផលិតស្ករ ។ សម្រាប់ដំណាក់កាលនេះ កោសិកាត្រូវការរូបធាតុដើមពីរគឺ ទឹក ($H_2O$) និងឧស្ម័នកាបូនិច ($CO_2$) ។ ចំពោះរុក្ខជាតិ ឫសស្រូបយកទឹកពីក្នុងដី ។ បន្ទាប់មកទឹកធ្វើចលនាឡើងតាមដើមឆ្ពោះទៅកាន់ស្លឹករុក្ខជាតិ ។ ឧស្ម័នកាបូនិចមាននៅក្នុងខ្យល់ ។ ឧស្ម័ននេះចូលក្នុងរុក្ខជាតិតាមរន្ធចំហតូចៗដែលស្ថិតនៅផ្នែកខាងក្រោមនៃស្លឹក ហៅថា **ស្តូម៉ាត** ។ ក្នុងស្លឹក ទឹកនិងឧស្ម័នកាបូនិចធ្វើដំណើរទៅកាន់ក្លរ៉ូប្លាស ។

ក្នុងក្លរ៉ូប្លាស ទឹកនិងឧស្ម័នកាបូនិចទទួលរងប្រតិកម្មគីមីជាបន្តបន្ទាប់ ។ ប្រតិកម្មនេះប្រព្រឹត្តទៅបាន ដោយសារថាមពលដែលមាននៅក្នុងដំណាក់កាលទី1 ។ ប្រតិកម្មទាំងនេះ បង្កើតបានផលិតផលគីមីមួយគឺ ស្ករដែលមានអាតូមកាបូនចំនួន6 ។ ម៉ូលេគុលស្ករនេះ ជាគ្លុយកូសដែលមានរូបមន្តគីមី ($C_6H_{12}O_6$) ។ គួររំលឹកឡើងវិញផងដែរ ស្ករជាប្រភេទមួយនៃគ្លុយស៊ីត ។ កោសិកាទាំងឡាយអាចប្រើប្រាស់ថាមពលនៅក្នុងស្ករដើម្បីដឹកនាំសកម្មភាពសំខាន់ៗនៅក្នុងកោសិកា ។

ផលិតផលមួយផ្សេងទៀតនៃរស្មីសំយោគគឺ អុកស៊ីសែន ($O_2$) ។ អុកស៊ីសែននេះភាយចេញពីស្លឹកតាមស្តូម៉ាត ។ វាជាការពិត អុកស៊ីសែនស្ទើរតែទាំងអស់នៅក្នុងបរិយាកាសនៃផែនដី ត្រូវបានផលិតឡើងដោយភាវៈរស់តាមដំណើររស្មីសំយោគ ។

ដំណើររស្មីសំយោគអាស្រ័យដោយកត្តាជាច្រើន ដូចជា អាំងតង់ស៊ីតេពន្លឺ សីតុណ្ហភាព ទឹកនិងដង់ស៊ីតេឧស្ម័នកាបូនិចជាដើម ។




*រូបទី1.4 :ការប្រើប្រាស់ថាមពលសម្រាប់ផលិតអាហារ*

## 3.3 សមីការរស្មីសំយោគ

ដំណើររស្មីសំយោគអាចសង្ខេបបានតាមសមីការគីមីដូចខាងក្រោម :

$$6CO_2 + 6H_2O \xrightarrow[\text{ក្លរ៉ូភីល}]{\text{ថាមពលពន្លឺ}} C_6H_{12}O_6 + 6O_2$$

ឧស្ម័នកាបូនិច ទឹក ស្ករ អុកស៊ីសែន

ចូរកត់សំគាល់ថា រូបធាតុដើមគឺ ឧស្ម័នកាបូនិចប្រាំមួយម៉ូលេគុល($6CO_2$) និងទឹកប្រាំមួយម៉ូលេគុល ($6H_2O$) ស្ថិតនៅក្នុងអង្គទីមួយនៃសមីការ ។ ផលិតផលរស្មីសំយោគគឺ ស្ករមួយម៉ូលេគុល ($C_6H_{12}O_6$) និងឧស្ម័នអុកស៊ីសែនប្រាំមួយម៉ូលេគុល ($6O_2$) ដែលស្ថិតនៅក្នុងអង្គទីពីរនៃសមីការ ។ សញ្ញាព្រួញ ត្រូវអានថា " ឱ្យផលជា " សម្រាប់ភ្ជាប់រូបធាតុដើមទៅនិងផលិតផល ។ ថាមពលពន្លឺដែលចាំបាច់សម្រាប់ប្រតិកម្មគីមីកើតមាន ត្រូវបានសរសេរនៅពីខាងលើសញ្ញាព្រួញ ។ ឯជាតិពណ៌បៃតង " ក្លរ៉ូភីល " ដែលមាននាទីចាប់យកថាមពលពន្លឺព្រះអាទិត្យនៅពេលរស្មីសំយោគត្រូវបានសរសេរនៅពីខាងក្រោមសញ្ញាព្រួញ ។

តើមានអ្វីកើតឡើងចំពោះស្ករដែលផលិតបាននៅក្នុងរស្មីសំយោគ ?

កោសិការុក្ខជាតិប្រើប្រាស់ស្ករមួយចំនួនសម្រាប់ជាអាហាររបស់វា ។ កោសិកាបំបែកម៉ូលេគុលស្ករ ដើម្បីបញ្ចេញថាមពលដែលស្តុកទុកក្នុងស្ករ ។ បន្ទាប់មកថាមពលនេះ ត្រូវយកទៅប្រើប្រាស់ដើម្បីដឹកនាំសកម្មភាពផ្សេងៗរបស់រុក្ខជាតិ ។ ម៉ូលេគុលស្ករមួយចំនួនផ្សេងទៀតរបស់រុក្ខជាតិ បំប្លែងទៅជាសមាសធាតុផ្សេងៗទៀត ដូចជា សែលុយឡូសជាដើម ។ ម៉ូលេគុលស្ករខ្លះទៀតអាចស្តុកទុកក្នុង

កោសិការុក្ខជាតិសម្រាប់ប្រើប្រាស់នៅពេលក្រោយ ។ នៅពេលអ្នកបរិភោគអាហារដែលមានប្រភពពីរុក្ខជាតិ ដូចជាដំឡូងបារាំង ការ៉ុតជាដើម អ្នកកំពុងតែបរិភោគថាមពលដែលស្តុកទុកនៅក្នុងរុក្ខជាតិនោះ ។

## មេរៀនសង្ខេប

- ភាវៈរស់ស្ទើរទាំងអស់ទទួលបានថាមពលដោយផ្ទាល់និងប្រយោលពីថាមពលពន្លឺព្រះអាទិត្យដែលចាប់យកក្នុងរយៈពេលធ្វើរស្មីសំយោគ ។
- រស្មីសំយោគជាដំណើរការដែលកោសិកាចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយប្រើប្រាស់ថាមពលនេះដើម្បីផលិតអាហារ ។ សារពាង្គកាយដែលអាចផលិតអាហារដោយខ្លួនវាផ្ទាល់ហៅថា ស្វ័យជីព ។ សារពាង្គកាយដែលស៊ីសារពាង្គកាយដទៃទៀតជាអាហារហៅថាបរជីព ។
- ក្នុងពេលធ្វើរស្មីសំយោគ រុក្ខជាតិនិងសារពាង្គកាយមួយចំនួនផ្សេងទៀតប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ ដើម្បីបំប្លែងឧស្ម័នកាបូនិច ($CO_2$) និងទឹកឱ្យទៅជាឧស្ម័នអុកស៊ីសែន ($O_2$) និងស្ករ ($C_6H_{12}O_6$) ។ សមីការសង្ខេបនៃដំណើររស្មីសំយោគមានដូចតទៅ :

$$6CO_2 + 6H_2O \xrightarrow[\text{ក្លរ៉ូភីល}]{\text{ថាមពលពន្លឺព្រះអាទិត្យ}} C_6H_{12}O_6 + 6O_2$$

ឧស្ម័នកាបូនិច + ទឹក → ស្ករ + អុកស៊ីសែន

## សំណួរនិងលំហាត់

1. ហេតុអ្វីបានជាភាវៈរស់ត្រូវការថាមពល ?
2. តើរុក្ខជាតិទទួលបានថាមពលយ៉ាងដូចម្តេច ?
3. ចូរសរសេរសមីការសង្ខេបអំពីដំណើររស្មីសំយោគ ។
4. តើសារធាតុចាំបាច់សម្រាប់រស្មីសំយោគមានអ្វីខ្លះ ?
5. តើផលិតផលរបស់រស្មីសំយោគមានអ្វីខ្លះ ?

# ពិសោធន៍ : ដំណើររស្មីសំយោគ

រស្មីសំយោគ ជាដំណើរដែលរុក្ខជាតិបៃតងនិងសារពាង្គកាយមួយចំនួនប្រើប្រាស់ថាមពលពន្លឺ ដើម្បីសំយោគសារធាតុចិញ្ចឹមសម្រាប់ខ្លួនវា ។ ក្នុងអំឡុងរស្មីសំយោគ ឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ត្រូវបានបំប្លែងជាឧស្ម័នអុកស៊ីសែន ($O_2$) និងគ្លុយកូស ($C_6H_{12}O_6$) ។ បន្ទាប់មកគ្លុយកូសបំប្លែងទៅជាសារធាតុផ្សេងៗដូចជា សែលុយឡូស ប្រូតេអ៊ីន លីពីត អាមីដុងជាដើម ។ ដំណើររស្មីសំយោគអាស្រ័យទៅនិងកត្តាសំខាន់ៗមួយចំនួន រួមមានអាំងតង់ស៊ីតេពន្លឺ សីតុណ្ហភាព ទឹក ដង់ស៊ីតេឧស្ម័នកាបូនិច ។

1. **វត្ថុបំណង :** សង្កេតល្បឿនរស្មីសំយោគអាស្រ័យទៅនឹងអាំងតង់ស៊ីតេពន្លឺ ។
2. **សម្ភារៈ :** ពិលប្រើថ្មបី កូនសារាយឬចកកន្ទុយឆ្កែ កន្ត្រៃ បន្ទាត់ នាឡិកា ដបជ័រថ្លា(ឬបំពង់កែវ) ទឹក ។
3. **ដំណើរការ**




កាត់ចកកន្ទុយឆ្កែប្រវែង 10-15cm បន្ទាប់មកដាក់វាក្នុងដបជ័រដែលមានទឹក ដោយដាក់ផ្នែកគល់រុក្ខជាតិឡើងលើ ។

គ្រិតចម្ងាយ 5cm 10cm 20cm 30cm និង 40cm ពីដបជ័រថ្លា ។




បើកពន្លឺពិលហើយដាក់នៅចម្ងាយ 5cm (គ្រិតទី 1) ។ រង់ចាំមើលពពុះទឹកចេញពីគល់ចកកន្ទុយឆ្កែ រយៈពេលប្រហែល 30 វិនាទីទើបអាចពិសោធបាន ។

រាប់ចំនួនពពុះទឹកពីរលើក ។ ក្នុងមួយលើកមាន 1 នាទី ។ ធ្វើបែបនេះគ្រប់ចម្ងាយដែលបានគ្រិត ។

ចំណាំ : រាល់ចម្ងាយនីមួយៗពីដបជ័រថ្លា ត្រូវរាប់ចំនួនពពុះទឹកឱ្យបាន2ដង ក្នុង1ដងមាន1 នាទី បន្ទាប់មកធ្វើមធ្យមភាគ ។

## 4. លទ្ធផល

ក. ធ្វើតារាងលទ្ធផលតាមរយៈការពិសោធសង្កេត ។

| ល-រ | ចម្ងាយគិត ពីដបជ័រ | ចំនួនពពុះទឹក លើកទី 1/1 នាទី | ចំនួនពពុះទឹក លើកទី 2/1 នាទី | មធ្យមភាគពពុះទឹក |
|---|---|---|---|---|
| 1 | 5cm | | | |
| 2 | 10cm | | | |
| 3 | 20cm | | | |

ខ. សង់ដ្យាក្រាមដោយយកទិន្នន័យតារាងមកអនុវត្ត ។




## 5. សន្និដ្ឋាន

ក. ពេលចម្ងាយពន្លឺកាន់តែឆ្ងាយ តើអ្នកឃើញចំនួនពពុះទឹកមានការប្រែប្រួលដែរឬទេ ? តើវាបណ្ដាលមកពីមូលហេតុអ្វី ?

ខ. ពេលពពុះទឹកកើនឡើងនិងថយចុះ តើវាមានន័យដូចម្ដេចដែរ ?

គ. ហេតុអ្វីបានជារុក្ខជាតិត្រូវការទឹកជាចាំបាច់ ?

មេរៀនទី

# 2 ដង្ហើមកោសិកា

**ចប់មេរៀននេះ សិស្សអាច**

- ❒ រៀបរាប់ពីដំណាក់កាលទាំងពីរនៃដង្ហើមកោសិកា
- ❒ ប្រៀបធៀបដំណើររស្មីសំយោគនិងដង្ហើមកោសិកា
- ❒ ពន្យល់ពីប្រភេទទាំងពីរនៃល្បើង ។

អ្នកបានធ្វើដំណើរឆ្លងកាត់ព្រៃពេញមួយព្រឹក រួចហើយអ្នកឃ្លានយ៉ាងខ្លាំង ។ អ្នកក៏ទាញបាយកញ្ចប់ រួចចាប់ផ្ដើមបរិភោគយ៉ាងឆ្ងាញ់ពិសា ។ តើរាងកាយរបស់អ្នកត្រូវការអាហារដើម្បីអ្វី ?

## 1. ដង្ហើមជាអ្វី ?

អាហារផ្គត់ផ្គង់គ្លុយកូស ($C_6H_{12}O_6$) ដល់រាងកាយរបស់អ្នក ។ គ្លុយកូសជាស្ករម្យ៉ាងដែលសម្បូរថាមពល ។ ដង្ហើមជាដំណើរការមួយដែលកោសិកា បានថាមពលពីម៉ូលេគុលគ្លុយកូស ។ ក្នុងដំណើរដង្ហើម កោសិកាបំបែកម៉ូលេគុលអាហារងាយៗ ដូចជា ស្ករជាដើម ហើយបញ្ចេញថាមពលដែលស្តុកទុកក្នុងអាហារនោះ ។

### 1.1 ការស្តុកនិងការបញ្ចេញថាមពល

ថាមពលស្តុកទុកក្នុងកោសិកា ប្រៀបដូចជាលុយដែលគេរក្សាទុកក្នុងបញ្ជីគណនីសន្សំ ។ ក្នុងដំណើររស្មីសំយោគ រុក្ខជាតិចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយរក្សាថាមពលនោះទុកនៅក្រោមទម្រង់គ្លុយកូស រួមមានស្ករនិងអាមីដុង ។ ចំពោះមនុស្សក៏ដូចគ្នាដែរ នៅពេលបរិភោគអាហារ អ្នកបានបន្ថែមថាមពលដល់រាងកាយដើម្បីរក្សាទុក ។ ពេលណាកោសិកាត្រូវការថាមពល វាទាញយកថាមពលដែលស្តុកទុកនោះ មកប្រើប្រាស់តាមរយៈការបំបែកម៉ូលេគុលគ្លុយស៊ីតក្នុងដំណើរដង្ហើម ។

### 1.2 ដំណាកដង្ហើមនិងដំណើរដង្ហើម

ពាក្យដង្ហើមមានន័យពីរយ៉ាង ។ អ្នកប្រហែលជាធ្លាប់ប្រើពាក្យនេះក្នុងន័យ "ដំណាកដង្ហើម "គឺជាចលនាខ្យល់ចូលនិងចេញពីសួតរបស់អ្នក ។ ដើម្បីជៀសវាងការភាន់ច្រឡំ ដំណើរដង្ហើមដែលកើត

មាននៅក្នុងកោសិកាហៅថា ដង្ហើមកោសិកា ។ ដំណាកដង្ហើមស្រូបយកអុកស៊ីសែនចូលទៅក្នុងសួតដែលតាមធម្មតាវាចាំបាច់ណាស់សម្រាប់ដង្ហើមកោសិកា។

## 2. ដំណាក់កាលទាំងពីរនៃដង្ហើមកោសិកា

ក៏ដូចជារស្មីសំយោគដែរ ដង្ហើមកោសិកាមានពីរដំណាក់កាល។ ដំណាក់កាលទី1 កើតមាននៅក្នុងស៊ីតូប្លាសនៃកោសិកា។ នៅទីនោះ គ្លុយកូសត្រូវបានបំបែកជាម៉ូលេគុលតូចៗ។ ក្នុងដំណាក់កាលនេះ អុកស៊ីសែនពុំទាន់បានប្រើប្រាស់ទេ ហើយមានបរិមាណថាមពលបន្តិចបន្តួចតែប៉ុណ្ណោះដែលបញ្ចេញ។




*រូបទី 2.1 : ដំណាក់កាលទាំងពីរនៃដង្ហើមកោសិកា*

ដំណាក់កាលទី2 នៃដង្ហើមកោសិកាកើតមាននៅក្នុងមីតូកុងឌ្រី។ នៅទីនោះម៉ូលេគុលគ្លុយកូសតូចៗត្រូវបានបំបែកជាបន្តទៀត។ ប្រតិកម្មគីមីទាំងនេះត្រូវការអុកស៊ីសែន ហើយវាបញ្ចេញថាមពលយ៉ាងច្រើន។ ហេតុនេះហើយ គេហៅមីតូកុងឌ្រីថាជា " មជ្ឈមណ្ឌលថាមពល " នៃកោសិកា។ គួរកត់សំគាល់ថា ថាមពលត្រូវបានបញ្ចេញនៅក្នុងដំណាក់កាលទាំងពីរនេះ។ ផលិតផលពីរនៃដង្ហើមកោសិកាគឺ ឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ដែលត្រូវភាយចេញក្រៅកោសិកា។ ចំពោះសត្វភាគច្រើនឧស្ម័នកាបូនិចនិងទឹកមួយចំនួនសាយចេញក្រៅរាងកាយ នៅពេលដកដង្ហើមចេញ។ ដូចនេះពេលអ្នកដកដង្ហើមចូល អ្នកស្រូបយកអុកស៊ីសែនដែលជារូបធាតុដើមសម្រាប់ដង្ហើម។ ពេលដកដង្ហើមចេញ អ្នកបញ្ចេញឧស្ម័នកាបូនិចនិងទឹកដែលជាផលិតផលនៃដង្ហើមមកក្រៅ ។

សមីការសង្ខេបដង្ហើមកោសិកា

$$C_6H_{12}O_6 + 6O_2 \xrightarrow[\text{មីតូកុងទ្រី}]{} 6CO_2 + 6H_2O + \text{ថាមពល}$$

ស្ករ　　អុកស៊ីសែន　　ឧស្ម័នកាបូនិច　　ទឹក

គួរកត់សំគាល់ថា រូបធាតុដើមសម្រាប់ដង្ហើមកោសិកាគឺ ស្ករនិងអុកស៊ីសែន ($O_2$) ។ រុក្ខជាតិនិងសារពាង្គកាយផ្សេងទៀតដែលទទួលរងរស្មីសំយោគ ផលិតស្ករ ($C_6H_{12}O_6$) របស់វាផ្ទាល់។ គ្លុយកូសនៅក្នុងកោសិកាសត្វនិងសារពាង្គកាយដទៃទៀតបានមកពីអាហារដែលវាស៊ី។ អុកស៊ីសែនប្រើប្រាស់ក្នុងដង្ហើមកោសិកាបានមកពីខ្យល់ឬទឹកដែលនៅជុំវិញសារពាង្គកាយ។

## 3. ប្រៀបធៀបរស្មីសំយោគនិងដង្ហើមកោសិកា




*រូបទី2.2 : ការប្រៀបធៀបដំណើររស្មីសំយោគនិងដង្ហើមកោសិកា*

ក្នុងដំណើររស្មីសំយោគ ឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ត្រូវបានប្រើប្រាស់ដើម្បីផលិតស្ករ ($C_6H_{12}O_6$) និងអុកស៊ីសែន ($O_2$) ។ ក្នុងដង្ហើមកោសិកា ស្ករគ្លុយកូស ($C_6H_{12}O_6$) និងអុកស៊ីសែន ($O_2$) ត្រូវបានប្រើប្រាស់ដើម្បីផលិតឧស្ម័នកាបូនិច ($CO_2$) និងទឹក ($H_2O$) ។ រស្មីសំយោគនិងដង្ហើមកោសិកាជាដំណើរពីរផ្ទុយគ្នា។

ដំណើរការទាំងពីរនេះ រួមគ្នាបង្កើតបានជាវដ្តមួយដែលរក្សាស្ថិរភាពនៃកម្រិតអុកស៊ីសែននិងឧស្ម័នកាបូនិចនៅក្នុងបរិយាកាសនៃផែនដី។ អ្នកអាចសង្កេតឃើញក្នុងរូបភាពទី 2.2 ថាភាវៈរស់ទាំងអស់ប្រើប្រាស់ឧស្ម័នទាំងពីរនេះម្តងហើយម្តងទៀត។

**ល្បើង:** កោសិកាខ្លះអាចទទួលបានថាមពលពីអាហារ ដោយពុំមានប្រើប្រាស់ឧស្ម័នអុកស៊ីសែនទេ។ *ឧទាហរណ៍* សារពាង្គកាយឯកកោសិកាខ្លះរស់នៅកន្លែងគ្មានអុកស៊ីសែន ដូចជា ក្នុងជម្រៅនៃមហាសាគរឬក្នុងភក់បាតបឹង។ សារពាង្គកាយទាំងនេះទទួលបានថាមពលតាមរយៈ ល្បើង។ ល្បើងផ្តល់ថាមពលឱ្យកោសិកាដោយមិនប្រើប្រាស់អុកស៊ីសែន។ ក្នុងពេលល្បើង ម៉ូលេគុលស្ករនីមួយៗបញ្ចេញបរិមាណថាមពលតិចតួចជាងបរិមាណថាមពលដែលបញ្ចេញដោយដង្ហើមកោសិកា។

**ល្បើងអាល់កុល :** ដំបែនិងសារពាង្គកាយឯកកោសិកាមួយចំនួនផ្សេងទៀតបំបែកម៉ូលេគុលស្ករតាមរយៈ**ល្បើងអាល់កុល**។ គេហៅល្បើងអាល់កុល ព្រោះអាល់កុលជាផលិតផលមួយដែលបានពីដំណើរល្បើងនេះ។ ផលិតផលផ្សេងទៀត មានឧស្ម័នកាបូនិចនិងបរិមាណថាមពលតិចតួចក៏បានមកពីល្បើងនេះដែរ។ ល្បើងអាល់កុលមានសារៈសំខាន់ចំពោះអ្នកធ្វើនំនិងអ្នកផលិតស្រាបៀរ។ ឧស្ម័នកាបូនិចដែលផលិតដោយដំបែ បង្កើតបានជាប្រហោងខ្យល់ក្នុងម្សៅទន់ៗ។ លក្ខណៈនេះហៅថាម្សៅឡើងមេ។ ឧស្ម័នកាបូនិចនេះ ក៏ជាប្រភពនៃការឡើងពពុះនៅក្នុងគ្រឿងស្រវឹងផងដែរ ដូចជាស្រាបៀរជាដើម។

**ល្បើងអាស៊ីតឡាក់ទិច:** ល្បើងអាស៊ីតឡាក់ទិច កើតមាននៅក្នុងខ្លួនរបស់អ្នក។ នៅពេលមួយដែលអ្នករត់យ៉ាងលឿនក្នុងរយៈពេលយូរ នៅពេលនោះសាច់ដុំជើងរបស់អ្នកឡើងរឹងហើយអ្នកដកដង្ហើមញាប់ៗ។



នៅពេលសាច់ដុំរបស់កីឡាករប្រើប្រាស់ $O_2$ អស់ ល្បើងអាស៊ីតឡាក់ទិចផ្គត់ផ្គង់ថាមពលដល់កោសិកាសាច់ដុំ។

*រូបទី23 : ល្បើងអាស៊ីតឡាក់ទិច*

តើអ្នកប្រឹងដកដង្ហើមយ៉ាងណាដែរ? កោសិកាសាច់ដុំរបស់អ្នកប្រើប្រាស់អុកស៊ីសែនច្រើនជាងអុកស៊ីសែនដែលវាទទួលបាន ជាហេតុធ្វើឱ្យកោសិកាខ្វះអុកស៊ីសែន។ ដូចនេះដើម្បីទទួលបានថាមពល កោសិកាត្រូវការប្រើប្រាស់ល្បើង។ អាស៊ីតឡាក់ទិចជាផលិតផលមួយរបស់ដំណើរល្បើងនេះ។ នៅពេលអាស៊ីតឡាក់ទិចកើតឡើង អ្នកមានអារម្មណ៍ឈឺចុកចាប់ក្នុងសាច់ដុំ។ សាច់ដុំរបស់អ្នកហត់នឿយនិងចុះខ្សោយ។

## មេរៀនសង្ខេប

- ដង្ហើមជាដំណើរការដែលកោសិកាទទួលបានថាមពលពីម៉ូលេគុលគ្លុយកូស ។ ដង្ហើមកោសិកាកើតមាននៅក្នុងកោសិកានៃភាវៈរស់ ។
- ដង្ហើមកោសិកាមានពីរដំណាក់កាល ។ ដំណាក់កាលទី1 កើតមានក្នុងស៊ីតូប្លាសរបស់កោសិកាដោយគ្លុយកូសត្រូវបានបំបែកជាម៉ូលេគុលតូចៗ ហើយបញ្ចេញបរិមាណថាមពលតិចតួច ។ ដំណាក់កាលទី2 កើតមាននៅក្នុងមីតូកុងឌ្រី ដោយម៉ូលេគុលគ្លុយកូសតូចៗផ្សំជាមួយអុកស៊ីសែនបង្កើតជាឧស្ម័នកាបូនិចនិងទឹក ព្រមទាំងមានការបញ្ចេញបរិមាណថាមពលយ៉ាងច្រើន ។ សមីការដង្ហើមសង្ខេបដូចតទៅ :
- $C_6H_{12}O_6$ (គ្លុយកូស) + $6O_2$ (អុកស៊ីសែន) ⟶ $6CO_2$ (ឧស្ម័នកាបូនិច) + $6H_2O$ (ទឹក) + ថាមពល
- ល្បើងផ្តល់ថាមពលតិចតួចដល់កោសិកាដោយពុំត្រូវការអុកស៊ីសែនទេ ។

## សំណួរនិងលំហាត់

1. តើមានអ្វីកើតឡើងក្នុងដំណើរដង្ហើម ?
2. តើដង្ហើមកោសិកាកើតមាននៅកន្លែងណា?
3. ចូរពណ៌នាពីដំណាក់កាលទី 1 នៃដង្ហើមកោសិកា ។
4. ចូរពណ៌នាពីដំណាក់កាលទី 2 នៃដង្ហើមកោសិកា ។
5. ចូរសរសេរសមីការដង្ហើម ។
6. ចូរប្រៀបធៀបសមីការដង្ហើមនិងរស្មីសំយោគ ។
7. តើដំណើរការដែលកោសិកាទទួលបានថាមពលដោយមិនប្រើឧស្ម័នអុកស៊ីសែនជាអ្វី ?

## ពិសោធន៍ : ដង្ហើម

ដង្ហើមកោសិកា ជាដំណើរការដែលកោសិកាទទួលបានថាមពលពីការបំបែកម៉ូលេគុលគ្លុយកូសនៅក្នុងកោសិកា។ ផលិតផលនៃដង្ហើមកោសិកាគឺ ឧស្ម័នកាបូនិចនិងទឹក។ ដើម្បីបង្ហាញវត្តមានឧស្ម័នកាបូនិចដែលត្រូវបានផលិត អ្នកត្រូវប្រើទឹកកំបោរថ្លាជាសារធាតុចង្អុលបង្ហាញ។

**1.** វត្ថុបំណង : បង្ហាញអត្តសញ្ញាណឧស្ម័នកាបូនិចក្នុងដំណើរដង្ហើមកោសិកា។

**2.** សម្ភារៈ : កំបោរស ទឹក កែវជ័រឬដបជ័រថ្លា សន្លឹកក្រដាសអាលុយមីញ៉ូម ស្លឹករុក្ខជាតិ។

**3.** ដំណើរការ



## 4. លទ្ធផល

ចូរធ្វើតារាងសង្កេតលទ្ធផលទឹកកំបោរក្នុងដបទាំង4 ។

| លក្ខណៈទឹកកំបោរ | ដបជ័រទី 1 | ដបជ័រទី 2 | ដបជ័រទី 3 | ដបជ័រទី 4 (រុំ $A\ell$) |
|---|---|---|---|---|
| ថ្លា | | | | |
| ល្អក់ | | | | |

## 5. សន្និដ្ឋាន

1. តើទឹកកំបោរក្នុងដបជ័រទាំង4 មានលក្ខណៈខុសគ្នាដូចម្តេច ?
2. ហេតុអ្វីបានជាដបជ័រខ្លះមានទឹកកំបោរថ្លា ខ្លះទៀតទឹកកំបោរល្អក់ ? ចូរពន្យល់ ?
3. ហេតុអ្វីបានជាអ្នកចាំបាច់ផ្លុំខ្យល់ចូលក្នុងដបជ័រទី2 ទី3 និង ទី 4 ?
4. ហេតុអ្វីបានជាអ្នករុំសន្លឹកអាលុយមីញ៉ូមលើដបទី4 ?

## ? សំណួរនិងលំហាត់ជំពូក 3

**I.** ចូរគូសសញ្ញា ( ✓ ) ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. ផលិតផលរស្មីសំយោគជា

☐ក. $CO_2$ ☐ខ. $O_2$ ☐គ. $H_2O$ ☐ឃ. $H_2$ ។

2. ទឹក ឧស្ម័នកាបូនិច និងថាមពលទាំងអស់នេះជាផលិតផលរបស់

☐ក. ចំណែកកោសិកា ☐ខ. រស្មីសំយោគ ☐គ. ការលូតលាស់ ☐ឃ. ដង្ហើម ។

3. ធាតុកោសិកាដែលកើតមានរស្មីសំយោគជា

☐ក. មីតូកុងទ្រី ☐ខ. ណៃយ៉ូ ☐គ. ក្លរ៉ូភីល ☐ឃ. ក្លរ៉ូប្លាស ។

4. ដង្ហើមកោសិកាកើតមាននៅក្នុង

☐ក. ណៃយ៉ូ ☐ខ. ក្លរ៉ូប្លាស ☐គ. មីតូកុងទ្រី ☐ឃ. វ៉ាគុយអូល ។

**II.** ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ដំណើរដែលរុក្ខជាតិផលិតអាហារដោយខ្លួនឯងហៅថា . . . . . . . . . . . . . . ។
2. សារពាង្គកាយ . . . . . . . . . . . ផលិតអាហារដោយខ្លួនឯង ។
3. រុក្ខជាតិអាចផលិតអាហាររបស់វាបាន ព្រោះវាមានជាតិពណ៌បៃតង . . . . . . . . . . . . ។
4. សារពាង្គកាយ . . . . . . . . . . .ទទួលបានថាមពលពីសារពាង្គកាយដទៃទៀត ។
5. ក្នុងពេលដង្ហើមកោសិកា ថាមពលភាគច្រើនត្រូវបានស្តុកទុក . . . . . . . . . . . . . ។
6. ដំណើរបញ្ចេញថាមពលដោយមិនត្រូវការអុកស៊ីសែនគឺ . . . . . . . . . . . . . . ។
7. លឿងមានពីរប្រភេទគឺលឿង . . . . . . . . . . និងលឿង . . . . . . . . . . . . . ។
8. ថាមពលមួយចំនួនដែលបញ្ចេញក្នុងដំណើរដង្ហើមត្រូវបានស្តុកទុកនៅក្នុងទម្រង់ជា . . . . . ។

**III.** ចូរឆ្លើយសំណួរខាងក្រោម

1. សត្វល្អិតស៊ីស្លឹកឈើ ។ ចូរពន្យល់ថា តើសត្វល្អិតទទួលថាមពលពន្លឺព្រះអាទិត្យបានដោយរបៀបណា?
2. តើស្លឹកមានមុខងារដូចម្តេច?
3. ហេតុអ្វីបានជាស្លឹកមានពណ៌បៃតង?
4. ហេតុអ្វីបានជាគេថា ដំណើររស្មីសំយោគជាដំណើរស្រូបយកថាមពល?
5. តើកត្តាអ្វីខ្លះ មានឥទ្ធិពលទៅលើដំណើររស្មីសំយោគ ?

6. តើអ្នកយល់ថារុក្ខជាតិផលិតអុកស៊ីសែនច្រើននៅពេលថ្ងៃដែលមានពពកច្រើនឬនៅពេលថ្ងៃដែលមានពន្លឺថ្ងៃចាំងចែង ?

7. ហេតុអ្វីបានជាដង្ហើមកោសិកាបន្ថែមឧស្ម័នកាបូនិចទៅឱ្យបរិយាកាស ប៉ុន្តែរស្មីសំយោគមិនបន្ថែមឧស្ម័នកាបូនិចទេ ?

8. តើកោសិការុក្ខជាតិត្រូវការដង្ហើមដែរឬទេ ? ហេតុអ្វី ?

9. ហេតុអ្វីបានជាដង្ហើមកោសិកាមានសារៈសំខាន់ ?

10. តើផលិតផលរស្មីសំយោគមានប្រយោជន៍ដូចម្តេចខ្លះ?

11. ហេតុអ្វីបានជាគ្លុយកូសមានសារៈសំខាន់ចំពោះកោសិកា ?

12. ហេតុអ្វីបានជានៅដំណាក់កាលទី 2 នៃដង្ហើមកោសិកា មានការបញ្ចេញថាមពលច្រើនជាងនៅដំណាក់កាលទី ១ ?

IV. ចូរបំពេញតារាង ហើយប្រៀបធៀបដំណើររស្មីសំយោគនិងដង្ហើមកោសិកា ។

| លក្ខណៈពិសេស | រស្មីសំយោគ | ដង្ហើមកោសិកា |
| --- | --- | --- |
| រូបធាតុដើម | ទឹកនិងឧស្ម័នកាបូនិច | ក ______________ ? |
| ផលិតផល | ខ ______________ ? | គ ______________ ? |
| ការបញ្ចេញថាមពល | ឃ ______________ ? | មាន |

ជំពូក 4

# ជីវវិទ្យាមនុស្ស




នៅក្នុងវាលស្រែ យើងឃើញកសិករកំពុងភ្ជួររាស់ ដកស្ទូង វែកកណ្ដាប់យ៉ាងមមាញឹក ។កសិករទាំងនេះប្រឹងប្រែងធ្វើការងារគ្រប់ៗគ្នាគ្មានឈប់ឈរ ។ សកម្មភាពទាំងអស់នេះត្រូវបានចូលរួមដោយប្រព័ន្ធគ្រោងឆ្អឹងនិងប្រព័ន្ធសាច់ដុំ ។

**មេរៀនទី 1 : ប្រព័ន្ធគ្រោងឆ្អឹង**

**មេរៀនទី 2 : ប្រព័ន្ធសាច់ដុំ**

មេរៀនទី

# 1 ប្រព័ន្ធគ្រោងឆ្អឹង

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពន្យល់ពីនាទីរបស់គ្រោងឆ្អឹង
- ❑ ប្រៀបធៀបសន្លាក់អចល័តនិងចល័ត
- ❑ បង្ហាញពីលក្ខណៈពិសេសរបស់ឆ្អឹងនិងតំហែរក្សាវា ។

## 1. ឆ្អឹងជាអ្វី ?

សារពាង្គកាយមនុស្សទ្រទ្រង់ដោយប្រព័ន្ធគ្រោងឆ្អឹង ។




*រូបទី ១.១ : ប្រព័ន្ធគ្រោងឆ្អឹង*

ប្រព័ន្ធគ្រោងឆ្អឹងកើតឡើងពីបណ្តុំឆ្អឹងទាំងអស់នៃសារពាង្គកាយ ។ ប្រព័ន្ធគ្រោងឆ្អឹងមាននាទីច្រើនយ៉ាង ។ វាមាននាទីកំណត់រូបរាងនិងទ្រទ្រង់សារពាង្គកាយ ធ្វើឱ្យយើងមានចលនា ការពារសរីរាង្គខាងក្នុង ផលិតកោសិកាឈាម និងស្តុកទុកនូវសារធាតុខនិជនិងសារធាតុផ្សេងៗទៀតសម្រាប់ផ្តល់ឱ្យសារពាង្គកាយនៅពេលត្រូវការ ។

គ្រោងឆ្អឹងមាននាទីកំណត់រូបរាងនៃសារពាង្គកាយរបស់យើង ។ ឆ្អឹងខ្នងជាមជ្ឈមណ្ឌលនៃគ្រោងឆ្អឹង ។ ចូរពិនិត្យរូបទី 1.1 ។ ប្រសិនបើយើងយកម្រាមដៃទៅស្ទាបចំកណ្តាលខ្នងរបស់យើងពីលើចុះក្រោម យើងនិងប៉ះឆ្អឹងតូចៗចំនួន 26 ។ ឆ្អឹងតូចៗទាំងនេះជាឆ្អឹងកង ។ ដូចនេះ ឆ្អឹងខ្នងរបស់យើងកើតឡើងពីឆ្អឹងកង ។ យើងអាចគិតស្រមៃថា ឆ្អឹងកងនីមួយៗប្រៀបដូចជាអង្កាំមួយគ្រាប់ដែលដោតតគ្នាជាអង្កាំមួយខ្សែ ។ យើងឃើញថាខ្សែអង្កាំអាចពត់បត់បែនបាន ចំណែកឯឆ្អឹងខ្នងរបស់យើងវិញក៏អាចឱ្យយើងធ្វើចលនាបានដែរ ដូចជាឱនទៅមុខ ងាកទៅឆ្វេងឬស្តាំ។ ប្រសិនបើឆ្អឹងខ្នងរបស់យើងកើតពីឆ្អឹងវែងតែមួយនោះយើងមិនអាចធ្វើចលនាបែបនេះបានទេ ។

គ្រោងឆ្អឹងអាចឱ្យយើងធ្វើចលនាបាន ។ ឆ្អឹងភាគច្រើននៃសារពាង្គកាយភ្ជាប់ទៅនឹងសាច់ដុំ ។ សាច់ដុំកន្ត្រាក់ហើយទាញឆ្អឹងចុះឡើងដែលបណ្តាលឱ្យសារពាង្គកាយមានចលនា ។

ឆ្អឹងក៏មាននាទីការពារសរីរាង្គខាងក្នុងមួយចំនួននៃសារពាង្គកាយដែរ ។ *ឧទាហរណ៍* ឆ្អឹងលលាដ៍ក្បាលការពារសំណុំខួរក្បាល ឆ្អឹងសន្ទះទ្រូង ឆ្អឹងជំនីរ និងឆ្អឹងកងបង្កើតជាប្រអប់ទ្រូងដែលការពារសួតនិងបេះដូង ។ ឆ្អឹងរបស់យើងមួយចំនួនផលិតសារធាតុទាំងឡាយដែលសារពាង្គកាយត្រូវការ ។ ឆ្អឹងវែងនៃដៃឬជើងជារោងចក្រផលិតកោសិកាឈាមរបស់សារពាង្គកាយ ។ ឆ្អឹងក៏ជាកន្លែងស្តុកទុកនូវសារធាតុខនិជដូចជា កាល់ស្យូមនិងផូស្វ័រ ។ ឆ្អឹងបញ្ចេញសារធាតុទាំងនេះក្នុងបរិមាណតិចតួចទៅក្នុងឈាមកាលណាសារពាង្គកាយត្រូវការវា ។

## 2. សន្លាក់

ឧបមាថា ជើងរបស់យើងកើតឡើងពីឆ្អឹងវែងតែមួយ តើយើងអាចដើបដើរចេញពីគ្រែឬដើរទៅសាលារៀនយ៉ាងដូចម្តេច ? តែសំណាងល្អ ជើងរបស់យើងក៏ដូចជាដៃឬផ្នែកផ្សេងៗទៀតនៃសារពាង្គកាយដែរគឺ វាកើតឡើងពីឆ្អឹងច្រើនដែលតភ្ជាប់ជាមួយគ្នា។

សន្លាក់ គឺជាកន្លែងដែលឆ្អឹងពីរនៅជាប់គ្នា។ សន្លាក់មានពីរយ៉ាងគឺ សន្លាក់អចល័តនិងសន្លាក់ចល័ត ។ក្នុងសារពាង្គកាយ សន្លាក់ខ្លះតភ្ជាប់ឆ្អឹងហើយធ្វើឱ្យឆ្អឹងមានចលនាតែបន្តិចបន្តួចឬក៏គ្មានចលនាសោះតែម្តង ។ សន្លាក់បែបនេះ ហៅថាសន្លាក់អចល័ត ។ ឆ្អឹងលលាដ៍ក្បាលទាំងអស់របស់យើងតភ្ជាប់គ្នាដោយសន្លាក់អចល័ត ។




*រូបទី1.2 : ប្រភេទផ្សេងៗនៃសន្លាក់*

ភាគច្រើននៃសន្លាក់ក្នុងសារពាង្គកាយជាសន្លាក់ចល័ត ។ សន្លាក់ចល័តអាចធ្វើឱ្យសារពាង្គកាយធ្វើចលនាបានទូលំទូលាយ ។ ក្នុងសន្លាក់ចល័ត ឆ្អឹងតភ្ជាប់គ្នាដោយជាលិកាសន្ធានយ៉ាងមាំហៅថាសរសៃចំណង ។ សន្លាក់ភាគច្រើនមានជាលិកាសន្ធានមួយបែបទៀត ហៅថាឆ្អឹងខ្ចី ។

ឆ្អឹងខ្ចីគ្របដណ្តប់ក្បាលឆ្អឹង ហើយរក្សាឆ្អឹងដើម្បីទប់ទល់នឹងភាពកកិតរបស់ឆ្អឹងលើគ្នាទៅវិញទៅមក ។ *ឧទាហរណ៍* នៅក្បាលជង្គង់ ឆ្អឹងខ្ចីមាននាទីជាទ្រនាប់ដែលថែរក្សាឆ្អឹងភ្លៅទប់ទល់នឹងភាពកកិតទៅលើឆ្អឹងស្មងជើង ។ បន្ថែមលើនេះទៀត នៅក្បាលឆ្អឹងមានធាតុរាវរំអិលគឺ ទឹកសន្លាក់សម្រាប់ធ្វើឱ្យឆ្អឹងមានចលនារអិលលើគ្នា ។

## 3. ឆ្អឹងមាំហើយមានជីវិត

រូបទី 1.3 បង្ហាញពីរូបផ្ចុំឆ្អឹងភ្លៅ ។ ឆ្អឹងភ្លៅដែលជាឆ្អឹងវែងជាងគេក្នុងសារពាង្គកាយ ភ្ជាប់ឆ្អឹងត្រគាកទៅនឹងឆ្អឹងស្មងជើង ។ យើងសង្កេតឃើញមានភ្នាសមួយស្តើងតែរឹងគឺ សំបកឆ្អឹងដែលគ្របដណ្តប់ឆ្អឹង លើកលែងតែក្បាលឆ្អឹង ។ សរសៃឈាមនិងសរសៃប្រសាទចូលទៅក្នុងឆ្អឹងនិងចេញពីឆ្អឹងតាមរយៈភ្នាសនេះ ។ នៅក្រោមសំបកឆ្អឹង មានស្រទាប់ឆ្អឹងតាន់ដែលរឹងហើយហាប់ ។ ក្នុងនោះមានបំពង់តូចៗជាច្រើនដែលឆ្លងកាត់ ។ បំពង់ទាំងនេះដឹកនាំសរសៃឈាមនិងសរសៃប្រសាទពីផ្ទៃខាងក្រៅឆ្អឹង ទៅកាន់កោសិកាមានជីវិតដែលនៅខាងក្នុងឆ្អឹង ។

នៅខាងក្រោមឆ្អឹងតាន់របស់ឆ្អឹងភ្លៅ មានស្រទាប់ឆ្អឹងស្ពោត ។ ដូចជាអេប៉ុងដែរ ឆ្អឹងស្ពោតមានប្រហោងតូចៗជាច្រើន ។ ទម្រង់បែបនេះធ្វើឱ្យជាលិកាឆ្អឹងស្ពោតមានភាពស្រាលតែមាំ ។ គេឃើញមានឆ្អឹងស្ពោតនៅត្រង់ក្បាលឆ្អឹងវែង ។ក្នុងប្រហោងនៃឆ្អឹងជាច្រើនមានជាលិកាសន្ធានទន់ៗដែលមានឈ្មោះថាខួរឆ្អឹង ។ ខួរឆ្អឹងមានពីរប្រភេទគឺ ខួរឆ្អឹងក្រហមនិងខួរឆ្អឹងលឿង ។ ខួរឆ្អឹងក្រហមផលិតកោសិកាឈាម ។ ខួរឆ្អឹងលឿងមានខ្លាញ់បម្រុងទុក ។




*រូបទី13 : រូបផ្គុំឆ្អឹងភ្លៅ*

ឆ្អឹងមានជីវិត ។ វាបង្កឡើងពីកោសិកានិងជាលិកាឆ្អឹង ។ ដោយសារវាមានជីវិត ឆ្អឹងអាចបង្កើតជាលិកាថ្មីៗនៅពេលយើងលូតលាស់ ។ សូម្បីតែនៅពេលយើងឈប់លូតលាស់ហើយក៏ដោយក៏ជាលិកាឆ្អឹងនៅតែបន្តកកើតនៅក្នុងឆ្អឹងរបស់យើងទៀតដែរ ។

ឆ្អឹងមានភាពរឹងមាំ ដោយវាផ្ទុកនូវសារធាតុខនិជ ជាពិសេសកាល់ស្យូមនិងផូស្វ័រ ។

## 4. គាំទ្រឆ្អឹង

ដោយសារឆ្អឹងបំពេញមុខងារសំខាន់ៗជាច្រើនក្នុងសារពាង្គកាយ ដូចនេះអ្នកត្រូវយកចិត្តទុកដាក់ថែរក្សាសុខភាពឆ្អឹង ។ ចំណីអាហារសមស្របនិងការហាត់ប្រាណទៀងទាត់មានសារៈសំខាន់ណាស់សម្រាប់ការរក្សាសុខភាពឆ្អឹង ។

វិធីម្យ៉ាងដែលធានាឱ្យឆ្អឹងមានសុខភាពល្អគឺ ការបរិភោគអាហារត្រឹមត្រូវ ។ ដើម្បីថែរក្សាឆ្អឹងឱ្យរឹងមាំនៅពេលដែលវាកំពុងលូតលាស់ អ្នកត្រូវបរិភោគអាហារល្អត្រឹមត្រូវ មានបរិមាណកាល់ស្យូមនិងផូស្វ័រគ្រប់គ្រាន់ ។ សាច់ គ្រាប់ធញ្ញជាតិ បន្លែពណ៌បៃតងសុទ្ធតែជាប្រភពដ៏ល្អនៃកាល់ស្យូមនិងផូស្វ័រ ។ ផលិតផលទឹកដោះគោដូចជា ទឹកដោះគោជូរក៏ផ្តល់កាល់ស្យូមផងដែរ ។ អំបិលផូស្វាតសម្បូរនៅក្នុងសណ្តែកសៀង ទឹកដោះគោ ថ្លើម ប្រូម៉ាស់ និងគ្រាប់ធញ្ញជាតិ ។ វីតាមីន A និង D ជួយឱ្យសារពាង្គកាយស្រូបយកកាល់ស្យូមនិងផូស្វ័រ ។ ប្រភពវីតាមីន A មានបន្លែពណ៌បៃតង ការ៉ុត ទឹកដោះគោ និងថ្លើម ។ ប្រភពវីតាមីន D មានប័រ ទឹកដោះគោ និងថ្លើម ។ ប្រសិនបើក្នុងអាហាររបស់អ្នកខ្វះសារធាតុខនិជណាមួយ សារពាង្គកាយរបស់អ្នកនឹងស្រូបយក សារធាតុខនិជពីក្នុងឆ្អឹង ដើម្បីយកទៅចិញ្ចឹមឈាម សាច់ដុំ និងសរសៃប្រសាទ ។ កង្វះសារធាតុខនិជបណ្តាលឱ្យឆ្អឹងចុះខ្សោយនិងងាយបាក់ ។

ដើម្បីសាងសង់និងរក្សាឆ្អឹងឱ្យមានភាពមាំមួន យើងត្រូវឧស្សាហ៍ធ្វើលំហាត់ប្រាណ ។ លំហាត់ប្រាណទាំងនេះរួមមាន ការដើរ ការរត់ឬការរាំ ។ វាជួយធ្វើឱ្យឆ្អឹងរបស់យើងលូតលាស់ហើយកាន់តែរឹងមាំនិងហាប់ ។



## មេរៀនសង្ខេប

- ប្រព័ន្ធគ្រោងឆ្អឹងមាននាទីជាគ្រោងនិងជាទម្រនៃសារពាង្គកាយ ។ វាធ្វើឱ្យសារពាង្គកាយមានចលនា ការពារសរីរាង្គខាងក្នុង ផលិតកោសិកាឈាមនិងស្តុកទុកនូវសារធាតុខនិជនិងសារធាតុផ្សេងៗទៀតសម្រាប់សារពាង្គកាយ ។
- សន្លាក់ជាកន្លែងដែលឆ្អឹងពីរឬបីតភ្ជាប់គ្នា ។ សន្លាក់មានពីរយ៉ាងគឺ សន្លាក់អចល័តនិងសន្លាក់ចល័ត ។
- ឆ្អឹងកើតពីកោសិកានិងជាលិកា ហើយឆ្អឹងរីកចម្រើនលូតលាស់ ។ ដូចនេះឆ្អឹងជាទម្រង់មានជីវិត ។
- អាហារសមស្របនិងការហាត់ប្រាណជួយឱ្យឆ្អឹងមានសុខភាពល្អ ។

## សំណួរនិងលំហាត់

1. ចូរបង្ហាញពីនាទីរបស់ឆ្អឹង ។
2. តើសន្លាក់មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?
3. ហេតុអ្វីបានជាឆ្អឹងមានសភាពរឹងមាំ ?
4. ចូរពណ៌នាអំពីសន្លាក់ចល័ត ។

មេរៀនទី

# 2 ប្រព័ន្ធសាច់ដុំ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីប្រភេទផ្សេងៗរបស់សាច់ដុំ
- ពន្យល់ពីរបៀបធ្វើការរបស់សាច់ដុំ
- ថែរក្សាសុខភាពសាច់ដុំ ។

យើងបានឃើញអំពីនាទីរបស់ឆ្អឹងនិងសន្លាក់ក្នុងការបង្កើតចលនា ។ តែចលនានេះនិងប្រព្រឹត្តទៅបាន លុះត្រាតែមានការកន្ត្រាក់និងទាញរបស់សាច់ដុំ ។ អ្នកមិនអាចអង្គុយបានដោយគ្មានចលនារបស់សាច់ដុំនោះទេ ។

ក្នុងសារពាង្គកាយមនុស្សមានសាច់ដុំចំនួនប្រហែល 600 ដែលមាននាទីផ្សេងៗគ្នា ។

## 1. ប្រភេទផ្សេងៗនៃសាច់ដុំ

យើងអាចគ្រប់គ្រងសកម្មភាពមួយចំនួនដូចជា ដើរ សើច ញញឹម តែយើងមិនអាចគ្រប់គ្រងការកន្ត្រាក់នៃបេះដូងបានទេ ។ សាច់ដុំដែលយើងអាចបញ្ជាបានគឺ ជាសាច់ដុំឆន្ទៈ ។ *ឧទាហរណ៍* បើកសៀវភៅហើយអាន ដើបឈរ ដើរ ជាអំពើនៃសាច់ដុំឆន្ទៈ ។ ឯសាច់ដុំដែលយើងមិនអាចបញ្ជាបានជាសាច់ដុំអឆន្ទៈ ។ សារពាង្គកាយយើងមានជាលិកាសាច់ដុំបីប្រភេទគឺ សាច់ដុំជាប់ឆ្អឹង សាច់ដុំរលោង និងសាច់ដុំបេះដូង ។




*រូបទី2.1 : ប្រភេទទាំងបីនៃសាច់ដុំ*

### 1.1 សាច់ដុំជាប់ឆ្អឹង

សាច់ដុំជាប់ឆ្អឹងភ្ជាប់ទៅនឹងឆ្អឹង ដោយប្រើកម្លាំងកន្ត្រាក់និងទាញ ដើម្បីឱ្យឆ្អឹងមានចលនា ។ ផ្នែកខាងចុងសងខាងនៃសាច់ដុំជាប់ឆ្អឹងគឺ សរសៃពួរ ។ សរសៃពួរជាជាលិកាធីមាំសម្រាប់ភ្ជាប់សាច់ដុំទៅនឹងឆ្អឹង ។ កោសិកាសាច់ដុំជាប់ឆ្អឹងមានឆ្នូត ហេតុនេះហើយគេហៅសាច់ដុំជាប់ឆ្អឹងថាជាសាច់ដុំឆ្នូត ។ យើងអាចបញ្ជាសាច់ដុំជាប់ឆ្អឹងធ្វើអ្វីមួយតាមបំណង ដូចនេះសាច់ដុំជាប់ឆ្អឹងត្រូវបានគេចាត់ទុកថាជាសាច់ដុំឆន្ទៈ ។ សាច់ដុំជាប់ឆ្អឹងមានលក្ខណៈមួយគឺ វាមានប្រតិកម្មរហ័សណាស់ ។ *ឧទាហរណ៍* នៅពេលសញ្ញាចាប់ផ្តើម សាច់ដុំជើងរបស់អ្នករត់ប្រណាំងកន្ត្រាក់ដែលធ្វើឱ្យគេមានចលនាទៅមុខភ្លាម ។ ប៉ុន្តែសាច់ដុំជាប់ឆ្អឹងក៏មានលក្ខណៈមួយផ្សេងទៀតដែរ គឺវាមានការឆាប់នឿយហត់ហើយត្រូវការសម្រាក ។

### 1.2 សាច់ដុំរលីង

ផ្ទៃខាងក្នុងនៃសរីរាង្គក្នុងមួយចំនួនដូចជាផ្ទៃក្រពះ ពោះវៀន សរសៃឈាម ប្លោកនោមជាដើមមានសាច់ដុំរលីង ។ សាច់ដុំរលីងជាសាច់ដុំអឆន្ទៈ វាធ្វើការដោយស្វ័យប្រវត្តិ ដើម្បីត្រួតពិនិត្យចលនាមួយចំនួននៅក្នុងសារពាង្គកាយ ដូចជាការរំលាយអាហារជាដើម ។ កាលណាក្រពះកន្ត្រាក់ វាបញ្ចេញរសសម្រាប់ជួយក្នុងការរំលាយអាហារ ។ ផ្ទុយពីកោសិកាសាច់ដុំជាប់ឆ្អឹង កោសិកាសាច់ដុំរលីងគ្មានឆ្នូតទេ វាមានប្រតិកម្មយឺតនិងមិនឆាប់នឿយហត់ទេ ។

### 1.3 សាច់ដុំបេះដូង

ជាលិកាសាច់ដុំបេះដូងមានតែនៅក្នុងបេះដូង ។ សាច់ដុំបេះដូងមានលក្ខណៈខ្លះដូចសាច់ដុំរលីង និងលក្ខណៈខ្លះទៀតដូចសាច់ដុំជាប់ឆ្អឹង ។ វាដូចសាច់ដុំរលីង ព្រោះវាជាសាច់ដុំអឆន្ទៈ ។ វាដូចសាច់ដុំជាប់ឆ្អឹង ព្រោះសាច់ដុំបេះដូងជាសាច់ដុំឆ្នូត ។ ប៉ុន្តែសាច់ដុំបេះដូងមិនចេះនឿយហត់ទេ ព្រោះវាអាចកន្ត្រាក់ប្រហែល 70 ដងក្នុងមួយនាទី ។

## 2. ចលនានិងការកន្ត្រាក់របស់សាច់ដុំ

### 2.1 សាច់ដុំធ្វើការជាគូ

ដូចជាសាច់ដុំជាប់ឆ្អឹងដទៃទៀតដែរ នៅពេលវាធ្វើការ សាច់ដុំដែកន្ត្រាក់រួញខ្លីហើយរឹង ។ កោសិកាសាច់ដុំកន្ត្រាក់ នៅពេលដែលវាទទួលរំញោចពីប្រព័ន្ធប្រសាទ ។ ដោយសារកោសិកាសាច់ដុំអាចបានត្រឹមតែរួញខ្លីប៉ុណ្ណោះ ដូចនេះសាច់ដុំជាប់ឆ្អឹងត្រូវតែធ្វើការជាគូ ។ នៅពេលសាច់ដុំមួយ

កន្ត្រាក់ សាច់ដុំមួយទៀតក្នុងគូជាមួយគ្នារលាមកប្រវែងដើមវិញ ។ *ឧទាហរណ៍* សកម្មភាពសាច់ដុំដៃនៅពេលយើងបត់ដៃត្រង់កន្លែងកែងដៃ ។ នៅពេលយើងបត់ដៃឡើងដោយយកប្រអប់ដៃដាក់លើស្មា យើងសង្កេតឃើញ សាច់ដុំវាវពីរដែលនៅផ្នែកខាងមុខនៃដើមដៃកន្ត្រាក់ឡើងប៉ោងខ្លីហើយរឹង ។




*រូបទី2.2 : សាច់ដុំធ្វើការជាគូ*

ចំណែកសាច់ដុំវាវបីដែលនៅផ្នែកខាងក្រោយដើមដៃរលា ហើយត្រឡប់មកប្រវែងដើមវិញ ។ បើយើងលាតសន្ធឹងដៃយើងឱ្យត្រង់វិញ សាច់ដុំវាវបីកន្ត្រាក់ហើយសាច់ដុំវាវពីររលាហើយវាត្រឡប់មកសភាពដើមវិញ ។

សាច់ដុំភ្លៅដែលធ្វើឱ្យជើងបត់ឬលានៅត្រង់ជង្គង់ ក៏ធ្វើការជាគូដែរ ។

## 2.2 តម្រូវការសាច់ដុំនៅពេលធ្វើចលនា

ពេលសាច់ដុំកន្ត្រាក់ដើម្បីបង្កើតចលនា វាត្រូវការថាមពល ។ ថាមពលនេះ បានមកពីជង្ហើមកោសិកាដែលជាប្រតិកម្មអុកស៊ីតកម្មនៃគ្លុយកូសក្នុងកោសិកា ។ ប្រភពគ្លុយកូសមាននៅក្នុងអាហារ និងផ្លែឈើ ។ ការបំបែកអាមីដុងក្នុងបាយ ក៏ផ្តល់គ្លុយកូសដែរ ។ ខ្លាញ់និងប្រូតេអ៊ីន ក៏ជាប្រភពផ្តល់ថាមពលដែរ ។ គ្លុយកូសដែលបានពីអាហារត្រូវដឹកនាំតាមឈាមចូលទៅក្នុងសាច់ដុំ ហើយបំប្លែងជាគ្លីកូសែនបម្រុងទុក ។ កាលណាសាច់ដុំកន្ត្រាក់ គ្លីកូសែនប្លែងជាគ្លុយកូស ។ សាច់ដុំក៏ត្រូវការដកដង្ហើមដែរ ដូចនេះវាចាប់យកអុកស៊ីសែន($O_2$)និងបញ្ចេញឧស្ម័នកាបូនិច($CO_2$) ។

# 3. ការថែរក្សាសាច់ដុំ

ការធ្វើលំហាត់ប្រាណទៀងទាត់ មានសារៈសំខាន់ណាស់ក្នុងការរក្សាភាពមាំមួននិងភាពទន់ភ្លន់នៃសាច់ដុំ ។ លំហាត់ប្រាណធ្វើឱ្យទំហំកោសិកាសាច់ដុំឡើងធំ ដូចនេះសាច់ដុំទាំងមូលត្រូវរីកធំ ។ កាលណាសាច់ដុំរីកធំវានឹងមានភាពរឹងមាំ ។ ការកម្តៅសាច់ដុំមុនធ្វើលំហាត់ប្រាណ ធ្វើឱ្យសាច់ដុំកាន់តែមានភាពរហ័សរហួន ។ ដើម្បីរក្សាខ្លួនយើងឱ្យមានរាងសមល្អ យើងត្រូវតែធ្វើលំហាត់ប្រាណឬលេងកីឡា ។

## មេរៀនសង្ខេប

- ក្នុងសារពាង្គកាយមានជាលិកាសាច់ដុំបីប្រភេទ ៖ ជាលិកាសាច់ដុំជាប់ឆ្អឹង សាច់ដុំរលីង និងសាច់ដុំបេះដូង ។ សាច់ដុំជាប់ឆ្អឹងជាសាច់ដុំឆន្ទៈ ចំណែកសាច់ដុំរលីងនិងសាច់ដុំបេះដូងជាសាច់ដុំអឆន្ទៈ ។
- សាច់ដុំមាននាទីកន្ត្រាក់ បង្កើតចលនា ។ សាច់ដុំជាប់ឆ្អឹងធ្វើការជាគូ ។ កាលណាសាច់ដុំមួយកន្ត្រាក់ សាច់ដុំមួយទៀតដែលជាគូត្រូវរលា ហើយត្រឡប់មកសភាពដើមវិញ ។
- សាច់ដុំធ្វើការត្រូវការថាមពលដែលបានមកពីអុកស៊ីតកម្មនៃគ្លុយកូស ។ ប្រភពគ្លុយកូសមានក្នុងអាហារនិងផ្លែឈើ ។
- លំហាត់ប្រាណទៀងទាត់ធ្វើឱ្យសាច់ដុំរឹងមាំ ។

## ? សំណួរនិងលំហាត់

1. តើជាលិកាសាច់ដុំមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. ចូរពន្យល់អំពីរបៀបធ្វើការជាគូនៃសាច់ដុំ ?
3. នៅពេលកន្ត្រាក់ តើកោសិកាសាច់ដុំបានថាមពលពីណា ?
4. ដូចម្ដេចហៅថាសាច់ដុំឆន្ទៈ ? សាច់ដុំអឆន្ទៈ ?



## ពិសោធន៍ ៖ សង្កេតសាច់ដុំនិងឆ្អឹងស្លាបមាន់

**1.** វត្ថុបំណង

សង្កេតលក្ខណៈរបស់ឆ្អឹងស្លាបមាន់ និងបង្ហាញពីរបៀបភ្ជាប់គ្នារវាងសាច់ដុំនិងឆ្អឹង ។

**2.** សម្ភារៈ

ស្លាបមាន់ស្រស់ ក្ដារសម្រាប់វះសាច់ កូនកន្ត្រៃ ដង្កៀប ក្រដាសជូតមាត់ ។

**3.** ដំណើរការ

- ប្រយ័ត្នពេលអ្នកប្រើសម្ភារៈមុតស្រួច ត្រូវមានការប្រុងប្រយ័ត្នហើយអនុវត្តតាមការណែនាំរបស់គ្រូអ្នក ។

- លាងស្លាបមាន់ បន្ទាប់មកជូតវាឱ្យស្ងួតទឹកជាមួយក្រដាសជូតមាត់ ហើយដាក់វាលើក្ដារវះសាច់ ។
- លាតសន្ធឹងស្លាបមាន់ ។ យកឡាមចៀរស្បែកមាន់ត្រង់គែមស្លាប(រូបទី 1) ។បន្ទាប់មកប្រើឡាមចៀរស្បែកមាន់ចេញពីសាច់ដុំដោយប្រុងប្រយ័ត្ន(រូបទី 2) ។
- សង្កេតមើលទម្រង់សាច់ដុំស្លាបមាន់ ពិនិត្យមើលសរសៃពួរ ព្រមទាំងកត់ចំណាំទីតាំងដែលសាច់ដុំភ្ជាប់ទៅនឹងឆ្អឹងផ្សេងៗ ។ទាញសាច់ដុំកំភួនដៃមាន់ ដើម្បីពិនិត្យមើលចលនារបស់ប្រអប់ដៃ ។
- កាត់សាច់ដុំចេញពីឆ្អឹង ។ សង្កេតមើលឆ្អឹងដើមដៃ កំភួនដៃ (ឆ្អឹងស្លាបមាន់)ព្រមទាំងកន្លែងដែលឆ្អឹងភ្ជាប់ជាមួយគ្នានៅត្រង់សន្លាក់ ពិនិត្យមើលសរសៃចំណង ។ ធ្វើចលនាឆ្អឹងមាន់ ហើយសង្កេតមើលពីរបៀបធ្វើការរបស់សន្លាក់ ។
- ប្រយ័ត្នពេលបញ្ចប់ការងារ ត្រូវលាងដៃនឹងសាប៊ូឱ្យស្អាតព្រមទាំងសំអាតកន្លែងធ្វើការងារផង ។



រូបទី1 ***រូបទី2.3 : សាច់ដុំស្លាបមាន់*** រូបទី 2

## 4. លទ្ធផល

ចូរគូរគំនូសបំប្រួញសាច់ដុំ សរសៃពួរនិងឆ្អឹងដែលអ្នកបានសង្កេត ។

## 5. សន្និដ្ឋាន

ក. តើសាច់ដុំនិងសរសៃពួរមានលក្ខណៈខុសគ្នាដូចម្ដេច ?

ខ. តើទម្រង់របស់សរសៃពួរមានទំនាក់ទំនងដូចម្ដេចជាមួយនាទីរបស់វា ?

គ. តើសាច់ដុំនីមួយៗភ្ជាប់ជាមួយឆ្អឹងប៉ុន្មាន ? ហេតុអ្វី ? តើវាជាប្រភេទសាច់ដុំអ្វី ?

## សំណួរនិងលំហាត់ជំពូក 4

**I.** ចូរគូសសញ្ញា (✓) ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ

1. ឆ្អឹងភ្ជាប់ទៅនឹងសាច់ដុំដោយ

☐ក. សរសៃចំណង ☐ខ. ស្បែក

☐គ. ឆ្អឹងខ្ចី ☐ឃ. សរសៃពួរ ។

2. សារធាតុខនិជស្តុកទុកក្នុង

☐ក. ឆ្អឹង ☐ខ. ស្បែក

☐គ. សាច់ដុំ ☐ឃ. ឈាម ។

3. ជាលិកាសន្ទានខន់ៗដែលឃើញនៅផ្នែកខាងក្នុងនៃឆ្អឹងជា

☐ក. ស៊ីតូប្លាស ☐ខ. ខួរឆ្អឹង

☐គ. ឆ្អឹងខ្ចី ☐ឃ. សារធាតុខ្លាញ់ ។

4. សាច់ដុំដែលជួយឱ្យឆ្អឹងធ្វើចលនាបានជា

☐ក. សាច់ដុំបេះដូង ☐ខ. សាច់ដុំជាប់ឆ្អឹង

☐គ. សាច់ដុំរលីង ☐ឃ. សាច់ដុំអាការៈក្នុង ។

5. ជាលិកាសាច់ដុំបេះដូងស្ថិតនៅក្នុង

☐ក. បំពង់អាហារ ☐ខ. បេះដូង

☐គ. ក្រពះ ☐ឃ. ប្លោកនោម ។

**II.** ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ឆ្អឹងលលាដ៍ក្បាលតភ្ជាប់គ្នាដោយ . . . . . . . . . ។
2. ធាតុរំអិលដែលធ្វើឱ្យឆ្អឹងមានចលនាលើគ្នាហៅថា . . . . . . . . . ។
3. សារធាតុគីមីដែលធ្វើឱ្យឆ្អឹងរឹងមាំជា . . . . . . . . . និង . . . . . . . . . ។
4. សាច់ដុំអឆន្ទៈពីរប្រភេទគឺ. . . . . . . . . និង . . . . . . . . . ។
5. សាច់ដុំដែលភ្ជាប់ជាមួយឆ្អឹងហៅថា . . . . . . . . . ។

III. ចូរបកស្រាយរូបភាព

1. ពណ៌នាសកម្មភាពសាច់ដុំ "ក" និង "ខ" នៅពេលឆ្អឹងនៅក្នុងរូបភាពទី 2.4 ធ្វើចលនាពីស្ថានភាពទី 1 ទៅស្ថានភាពទី 2 ។
2. ពណ៌នាសកម្មភាពរបស់សាច់ដុំ "ក" និង "ខ" នៅពេលឆ្អឹងនៅក្នុងរូបភាពទី 2.5 ធ្វើចលនាពីស្ថានភាពទី 1 ទៅស្ថានភាពទី 2 ។



*រូបទី 2.4*



*រូបទី 2.5*

IV. ចូរឆ្លើយសំណួរ

1. ចូរពន្យល់ហេតុអ្វីបានជាគេថាឆ្អឹងមានជីវិត ?
2. ពណ៌នាពីលក្ខណៈខុសគ្នារវាងសាច់ដុំអឆន្ទៈនិងឆន្ទៈ ។ ចូរឱ្យឧទាហរណ៍ពីប្រភេទសាច់ដុំនីមួយៗ ។
3. តើសារពាង្គកាយរបស់អ្នកមានលក្ខណៈដូចម្ដេច ប្រសិនបើឆ្អឹងខ្នងរបស់អ្នកកើតឡើងពីឆ្អឹងវែងតែមួយប៉ុណ្ណោះ ?
4. ហេតុអ្វីបានជាគេថាវាមានសារៈសំខាន់ដែលសាច់ដុំបេះដូងមិនមែនជាសាច់ដុំឆន្ទៈ ?
5. ហេតុដូចម្ដេចបានជាសាច់ដុំនិងឆ្អឹងមាននាទីរួមគ្នាក្នុងការធ្វើចលនា ? ចូរពន្យល់ ។
6. ពិនិត្យរូបសន្លាក់ត្រង់កែងដៃ ហើយដាក់ចំណងជើងលើរូបភាព ។



ជំពូក 5

# ជីវវិទ្យាក្នុងវិស័យកសិកម្ម



ពូជសត្វ ពូជផ្លែឈើនិងបន្លែ ជាពិសេសពូជស្រូវដែលយើងបរិភោគរាល់ថ្ងៃ ជាលទ្ធផលនៃការបង្កាត់។ ជាមួយគ្នានេះដែរ រុក្ខជាតិទាំងនេះលូតលាស់និងផ្តល់ផ្លែផ្កាបានល្អដោយសារជីជាតិ។ យើងសង្កេតឃើញថា ជីធម្មជាតិជាប្រភពដ៏ល្អបំផុតក្នុងការផ្តល់ជីជាតិឱ្យដី។ វត្ថុធាតុដើមសម្រាប់ផលិតជីធម្មជាតិងាយរកណាស់ ដូចជាកាកសំណល់ផ្ទះបាយ លាមកសត្វ កាកសំណល់ដំណាំ និងស្លឹកឈើបៃតងដែលដុះនៅជុំវិញភូមិដ្ឋាននិងនៅតាមវាលស្រែ។

**មេរៀនទី 1 : ជី**

**មេរៀនទី 2 : ការបង្កាត់**

មេរៀនទី

# 1 ជី

ចប់មេរៀននេះ សិស្សអាច

- ❐ កំណត់និយមន័យនៃពាក្យ " ជី "
- ❐ ពណ៌នាពីប្រភេទផ្សេងៗរបស់ជីធម្មជាតិនិងឱ្យឧទាហរណ៍
- ❐ ប្រៀបធៀបជីគីមីនិងជីធម្មជាតិ ។

រុក្ខជាតិទាំងអស់ដែលដុះនៅលើដី ត្រូវការសារធាតុចិញ្ចឹមសម្រាប់ការលូតលាស់របស់វា ។ សារធាតុចិញ្ចឹមទាំងនេះគេហៅថា ជី ។

## 1. និយមន័យ

ជីជាសារធាតុមួយចំនួនដែលបន្ថែមទៅឱ្យដី ដើម្បីបង្កើនផលិតភាពរបស់ដី ។ ជីអាចមានប្រភពចេញពីធម្មជាតិដូចជា ជីកំប៉ុស្ត ឬមួយគេអាចបង្កើតវាបានដោយសំយោគចេញពីសារធាតុគីមីដូចជា នីត្រាត ផូស្វាត . . . ។

## 2. ប្រភេទផ្សេងៗនៃជី

ជីចែកចេញជាពីរប្រភេទគឺ ជីគីមីនិងជីធម្មជាតិ ។

### 2.1 ជីគីមី

ជីគីមី ផលិតឡើងអំពីថ្មរ៉ែឬសារធាតុគីមីផ្សេងៗ ។ *ឧទាហរណ៍* ជីអ៊ុយរ៉េ ជីផូស្វាត ជីអាសូត ជីប៉ូតាស្យូម . . . ។ ជីគីមីមានច្រើនពណ៌ ។ សាច់ជីល្អិតម៉ដ្ឋមិនធុំក្លិនរុក្ខជាតិឬសត្វរលួយ ។ វាមិនត្រូវការសំណើមហើយត្រូវរក្សាទុកនៅក្នុងកន្លែងស្ងួត ។

### 2.2 ជីធម្មជាតិ

ជីធម្មជាតិ ជាជីដែលបានមកពីវត្ថុផ្សេងៗមានជីវិតដូចជា រុក្ខជាតិ សត្វ ឬកម្ទេចកំទីដែលសេសសល់ពីរុក្ខជាតិនិងសត្វ ។ *ឧទាហរណ៍* ជីលាមកសត្វ ជីកំប៉ុស្ត ជីអាចម៍ជន្លេន ជីស្រស់ជាដើម ។

ដីធម្មជាតិច្រើនតែមានពណ៌ត្នោតស្ទើរខ្មៅ ។ សាច់ដីគគ្រើម ហើយធុំក្លិនសំណល់រុក្ខជាតិ សត្វដែលពុករលួយ ។ វាត្រូវការសំណើម ហើយត្រូវរក្សាវាទុកនៅកន្លែងសើមជានិច្ច ។

## 2.3 ការផលិតដីកំប៉ុស្ដ

### ក. និយមន័យ

ពាក្យ កំប៉ុស្ដ មិនមែនជាពាក្យខ្មែរទេ ប៉ុន្តែបើប្រែជាភាសាខ្មែរមានន័យថា ការផ្សំបញ្ចូលគ្នានៃសារធាតុសរីរាង្គដែលរលួយឬពុកម៉ដ្ឋ ។

ដូចនេះដីកំប៉ុស្ដ ជាដីដែលបានមកពីការរលួយនៃស្លឹករុក្ខជាតិនិងលាមកសត្វគ្រប់ប្រភេទ ព្រមទាំងកាកសំណល់ផ្សេងៗនៃផ្ទះបាយ ។ វាជួយឱ្យដំណាំលូតលាស់បានល្អជាងការប្រើដីលាមកសត្វឬរុក្ខជាតិស្រស់តែមួយមុខ ព្រោះវាផ្សំឡើងពីសារធាតុសរីរាង្គច្រើនមុខ ។

### ខ. របៀបធ្វើដីកំប៉ុស្ដរយៈពេលខ្លី

ធាតុផ្សំ : លាមកសត្វស្រស់ ។ ស្លឹកឈើស្រស់និងស្ងួតគ្មានជំងឺឬគ្មានជាតិថ្នាំពុល ( ប្រសិនបើស្លឹករុក្ខជាតិមានជាតិថ្នាំពុល វាអាចមានឥទ្ធិពលដល់គុណភាពដីនិងសកម្មភាពរបស់មីក្រូសារពាង្គកាយក្នុងការបំបែកឬធ្វើឱ្យដីពុកផុយ) ។

របៀបធ្វើ

- កាប់ចិញ្ច្រាំស្លឹកឈើស្រស់ឬស្ងួតឱ្យល្អិតតូចៗ ។
- លាយស្លឹកឈើដែលចិញ្ច្រាំរួចនេះជាមួយលាមកសត្វស្រស់ក្នុងបរិមាណស្មើគ្នាឱ្យបានសព្វល្អ ។
- យកល្បាយនេះមកចាក់គរជាគំនរដែលមានទទឹងនិងបណ្ដោយយ៉ាងតិចបំផុតប្រវែង 1m និងកម្ពស់ខ្ពស់បំផុត 1m ។
- ត្រូវដាក់គំនរដីនេះនៅឱ្យឆ្ងាយពីផ្ទះ ដើម្បីជៀសវាងការប៉ះពាល់ដល់សុខភាព ។



រូបទី ១.J : របៀបធ្វើដី

- គ្របស្លឹកចេកឬបាវចាស់ៗពីលើគំនរដី ដោយធានាឱ្យមានខ្យល់ចេញចូល ។ ប្រសិនបើគ្មានខ្យល់ចេញចូលទេ វាបង្កឱ្យមានសត្វតូចៗគ្មានប្រយោជន៍ច្រើន ហើយពួកនេះបង្កឱ្យមានជំងឺដល់ដំណាំ ។

- បីឬបួនថ្ងៃក្រោយមក ជីនៅក្នុងគំនរឡើងក្តៅ ។ ប្រសិនបើមិនក្តៅទេ អ្នកត្រូវលាយលាមកសត្វស្រស់បន្ថែមទៀត ។ ពេលនេះត្រូវជ្រោយជីត្រឡប់ពីក្នុងមកក្រៅនិងពីក្រៅចូលទៅក្នុងវិញ ដើម្បីឱ្យជីរលួយបានសព្វល្អ ។ តែបើជីមិនបានរលួយអស់ទេ នៅពេលយកទៅប្រើ វានិងបញ្ចេញកម្តៅដែលអាចប៉ះពាល់ដល់ឫសដំណាំនិងធ្វើឱ្យដំណាំរលួយ ។
- បន្ទាប់មកត្រូវជ្រួយត្រឡប់ជីរៀងរាល់ពីរថ្ងៃម្តង ។ ធ្វើរបៀបនេះរយៈពេលពី 14-16ថ្ងៃ ។ នៅចុងបញ្ចប់អ្នកអាចយកវាទៅប្រើប្រាស់បានតាមត្រូវការ ។

## គ. វិធីប្រើប្រាស់

ជីកំប៉ុស្តអាចយកទៅប្រើប្រាស់នៅលើដំណាំគ្រប់ប្រភេទ ។ របៀបលាយជីជាមួយដីមុនដាំត្រូវធ្វើដូចតទៅ :

- ចំពោះបន្លែ : ក្រោយពីលើករងហើយ អ្នកត្រូវជ្រួយដីឱ្យបានសព្វល្អ បន្ទាប់មកភ្ជួរឬជ្រុំដីលុបពីលើ ។ អ្នកត្រូវប្រើជីមួយបង្គីសម្រាប់ផ្ទៃដីមួយម៉ែតបួនជ្រុង ។
- ចំពោះដំណាំស្រូវ : សម្រាប់ជាជីទ្រាប់បាត អ្នកត្រូវភ្ជួរលុបមុនពេលស្ទូងមួយឬពីរថ្ងៃ ។ អ្នកត្រូវប្រើជីពី 10-20តោននៅលើផ្ទៃដីមួយហិចតា ។
- ចំពោះស្រែដែលមានដីខ្សាច់ច្រើនត្រូវដាក់ជីបីដង :
  + លើកទី 1 ដាក់រួចភ្ជួររាស់ហើយស្ទូងតែម្តង
  + លើកទី 2 ដាក់ក្រោយពេលស្ទូងពី 20-30ថ្ងៃ
  + លើកទី 3 ដាក់នៅពេលស្រូវមូលដើម ។

ជីកំប៉ុស្តអាចយកទៅប្រើនៅពេលដំណាំលូតលាស់ហើយ ដូចជា :

- យកជីទៅរោយជុំវិញគល់ដំណាំឬរងដំណាំនៅពេលវាកំពុងលូតលាស់ ។
- លាយជីជាមួយទឹក ហើយស្រោចនៅលើដំណាំដែលមានលក្ខណៈដូចគ្នានិងជីកំប៉ុស្តទឹកដែរ ជាពិសេសស្រោចជីនេះដើម្បីបំប៉នកូនដំណាំនិងមុនពេលដំណាំជិតចេញផ្កា ។ អ្នកអាចប្រើជី 1kg លាយជាមួយទឹកពី 8-10 ℓ ។
- អ្នកអាចប្រើវាដាក់ក្នុងស្រះចិញ្ចឹមត្រីដើម្បីបង្កើនការលូតលាស់នៃរុក្ខជាតិទឹកដែលជាចំណីត្រីផ្ទាល់តែម្តង ។



រូបទី1.2 : របៀបដាក់ជីក្នុងចង្អូរជុំវិញដើមឈើ



រូបទី1.3 : របៀបដាក់ជីក្នុងចង្អូរកណ្តាលរងដំណាំ

# 3. គុណសម្បត្តិនិងគុណវិបត្តិ

## 3.1 ជីគីមី

### ក. គុណសម្បត្តិ

- ជ្រើសរើសប្រើតាមតម្រូវការ នៃដំណាំគ្រប់ប្រភេទដោយបង្កើនសារធាតុអាហារដល់ដី ។
- ឆាប់រលាយជាមួយដីដែលធ្វើឱ្យដំណាំបានផលយ៉ាងឆាប់រហ័សនិងចំណេញពេលវេលា ។
- ដឹកជញ្ជូនបានស្រួល ហើយប្រើកន្លែងតិចល្មមសម្រាប់រក្សាទុក ។
- បរិមាណធាតុអាហារគ្រឹះខ្ពស់ ។
- មិនមានសត្រូវដំណាំមកលាយឡំជាមួយ ។
- ធ្វើឱ្យដីមានជាតិអាស៊ីតឬបាសបានងាយនិងផ្តល់ទិន្នផលខ្ពស់ក្នុងរយៈពេលខ្លី ។

### ខ. គុណវិបត្តិ

- ជីគីមីផ្តល់ធាតុសំខាន់ 1-2 ឬ 3-4 មុខ ដូចជា អាសូត ផូស្វាត ប៉ូតាស្យូម ហើយជួនកាលស៊ុលផាតឬកាល់ស្យូម ។
- មានតម្លៃថ្លៃដោយទិញនៅទីផ្សារ ។
- ត្រូវមានចំណេះក្នុងការប្រើប្រាស់វាទើបទទួលបានផលល្អ ។
- ប្រើច្រើនពេកអាចបណ្តាលឱ្យដំណាំខូចខាត ។
- ប្រើជីគីមីយូរឆ្នាំធ្វើឱ្យដីហាប់ ហឹរ ។ ដូចនេះត្រូវកែប្រែដីថ្មីទៀតទើបអាចដាំដំណាំបាន ។
- ងាយរងការបំផ្លាញរបស់សត្វល្អិតចង្រៃ ដូចនេះត្រូវប្រើថ្នាំសម្លាប់សត្វចង្រៃបន្ថែមទៀត ។

## ៣.2 ជីធម្មជាតិ

### ក. គុណសម្បត្តិ

- បង្កើនសារធាតុសរីរាង្គដល់ដី ធ្វើឱ្យដីផុសល្អនិងខ្យល់ចេញចូលបាន ។
- បរិមាណធាតុអាហារតិចតួច ប៉ុន្តែមានធាតុអាហារដទៃទៀតគ្រប់គ្រាន់សម្រាប់ការលូតលាស់របស់រុក្ខជាតិ ។
- ជួយឱ្យការប្រើជីគីមីមានប្រសិទ្ធភាពនិងឱ្យផលតបស្នងប្រសើរជាងការប្រើជីគីមីតែម្យ៉ាង ។
- រលាយខ្លួនបន្តិចម្តងៗដែលជាប្រយោជន៍ដល់ដំណាំដាំជាប់បន្តក្នុងរយៈពេលយូរពី2-3ឆ្នាំទើបថយគុណភាព ។ ដូចនេះ ការចុះខុនក្នុងការរៀបចំជីឱ្យផលសមគួរទៅតាមតម្លៃ ។
- រកបានក្នុងចម្ការច្បារដំណាំទូទៅហើយមានតម្លៃថោក ។
- មិនធ្វើឱ្យដីមានជាតិអាស៊ីតឬបាស ។ វាជួយឱ្យគ្រាប់ដីខ្សាច់ស្អិតជាប់គ្នាដែលធ្វើឱ្យដីខ្សាច់ ហៀមទឹកបានច្រើននិងបានយូរ ។ វាជួយឱ្យគ្រាប់ដីឥដ្ឋមិនសូវស្អិតជាប់គ្នាដែលធ្វើឱ្យដីឥដ្ឋផុស ល្អ ។
- ងាយក្នុងការប្រើប្រាស់ ។ ទោះបីប្រើច្រើនប៉ុន្មានក៏មិនបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ផលដំណាំដូចជាជីគីមីទេ ។
- ធ្វើឱ្យគុណភាពដីកាន់តែល្អឡើងក្នុងរយៈពេលយូរឆ្នាំ ។
- ស្ថិតនៅជាមួយដីស្រទាប់លើ ដីកំប៉ុស្តមិនអាចហូរច្រោះតាមទឹកបានឡើយ ។

### ខ. គុណវិបត្តិ

- ពិបាកក្នុងការដឹកជញ្ជូន ។
- មានក្លិនអាក្រក់ ដូចជាក្លិនសំណល់រុក្ខជាតិឬសត្វដែលរលួយ ។
- ការបញ្ចេញធាតុអាហារតិចដែលមានប្រយោជន៍ដល់ដំណាំប្រព្រឹត្តទៅយឺតៗដោយ ប្រើរយៈពេលយូរ ។
- ប្រើប្រាស់ដំបូងផ្តល់ទិន្នផលទាបក្នុងរយៈពេលខ្លី ។
- មានសត្រូវនិងជំងឺឆ្លងមកជាមួយ ដូចជាពងរុយ គ្រាប់រុក្ខជាតិគ្មានប្រយោជន៍និងជំងឺផ្សេងៗ ។
- អាចបាត់បង់មួយចំណែកដោយសារទឹកភ្លៀងហូរនាំទៅជាមួយ ។
- ទាមទារកន្លែងធំដើម្បីទុកដាក់ជី ។

## មេរៀនសង្ខេប

- ដីជាប្រភពនៃសារធាតុចិញ្ចឹមឬជាអាហារបម្រុងសំខាន់របស់រុក្ខជាតិ ។
- ដីមានពីរប្រភេទគឺ ដីគីមីនិងដីធម្មជាតិ ។ ដីគីមីផលិតឡើងពីថ្មរ៉ែនិងសារធាតុគីមីផ្សេងៗ ដូចជា ដីអ៊ុយរ៉េ ដីផូស្វាត ដីអាសូត ដីប៉ូតាស្យូម . . . ។ ដីធម្មជាតិ ជាដីដែលផលិតឡើងពីវត្ថុនានាដែលមានជីវិត ដូចជា រុក្ខជាតិ សត្វ និងកម្ទេចកំទីដែលសេសសល់ពីរុក្ខជាតិនិងសត្វ ដូចជា ដីលាមកសត្វ ដីកំប៉ុស្ត ដីស្រស់ ដីអាចម៍ជន្លេន ដីកំប៉ុស្តទឹកជាដើម ។
- ដីកំប៉ុស្តជាប្រភេទមួយនៃដីធម្មជាតិដែលមានធាតុផ្សំពីកាកសំណល់សរីរាង្គផ្សេងៗរបស់រុក្ខជាតិនិងសត្វ ។ គេអាចផលិតវាបានក្នុងរយៈពេលខ្លីពី 14-16ថ្ងៃ ។
- ដីគីមីធ្វើឱ្យដំណាំលូតលាស់បានរហ័ស ប៉ុន្តែការប្រើវាយូរឆ្នាំអាចបណ្តាលឱ្យខូចគុណភាពដី ហើយដំណាំទទួលបានទិន្នផលទាប ។
- ដីធម្មជាតិបង្កើនសារធាតុចិញ្ចឹមគ្រប់គ្រាន់ដល់ដីសម្រាប់ការលូតលាស់របស់រុក្ខជាតិ ។ ការប្រើវាយូរឆ្នាំជួយបង្កើនគុណភាពដីឱ្យកាន់តែប្រសើរឡើងៗ ហើយផលដំណាំទទួលបានទិន្នផលខ្ពស់ ។

## ? សំណួរនិងលំហាត់

1. តើដីមានប៉ុន្មានប្រភេទ ? **អ្វីខ្លះ** ?
2. ដូចម្តេចហៅថាដីកំប៉ុស្ត ? តើវត្ថុធាតុដើមអ្វីខ្លះដែលគេយកមកធ្វើដីកំប៉ុស្ត ?
3. ចូរប្រៀបធៀបដីគីមីនិងដីធម្មជាតិ ។
4. ហេតុដូចម្តេចបានជាគេចាំបាច់ជួយត្រឡប់ដី ?

## ពិសោធន៍ : ជីកំប៉ុស្តទឹក

**1.** វត្ថុបំណង

ផលិតជីកំប៉ុស្តទឹកនិងប្រើប្រាស់ជីលើដំណាំផ្សេងៗ ។

**2.** សម្ភារៈ

លាមកសត្វ (មាន់ ទា ប្រជៀវ . . .) ស្លឹករុក្ខជាតិដែលមានឫសជ្រៅ ហើយក្លិនខ្លាំងដូចជា ទន្ទ្រានខែត្រ កន្ទ្រាកព្រៃឬស្លឹកឈើពពួកកក្កូរដូចជា ស្លឹកអង្កាញ់ ក្ដុមទេស អង្កាដី. . . ក្អមពាងស្អរឬធុងសាំង បាវមួយនិងដុំថ្មមួយដុំ ឈើវែងមួយ គម្របពាងធ្វើអំពីឈើ ។

**3.** ដំណើរការ

### ក. របៀបធ្វើ


រូបទី1.4 : ជីកំប៉ុស្តទឹក

- ច្រកស្លឹកឈើនិងលាមកសត្វចូលក្នុងបាវដោយវាស់បរិមាណឱ្យបានច្បាស់លាស់ ។
- ដាក់បាវច្រកជីនេះទៅក្នុងពាងរួចដាក់ដុំថ្មសង្កត់ពីលើ ។
- ចាក់ទឹកចូលក្នុងពាង ដោយចំណុះទឹកស្មើនឹង 20ដងនៃចំណុះជី (*ឧទាហរណ៍* ប្រសិនបើយើងច្រកជីមួយប៉ោតចូលក្នុងបាវ យើងត្រូវប្រើទឹក 20ប៉ោតចាក់ចូលទៅក្នុងពាង) ។ បន្ទាប់មកយកគម្របពាងធ្វើអំពីឈើ គ្របពាងឱ្យបានជិតល្អ ។

### ខ. របៀបថែរក្សា

- ត្រូវគ្របពាងជីឱ្យបានល្អ ដើម្បីការពារកុំឱ្យរុយពងដាក់និងជះក្លិនស្អុយចេញមកក្រៅ ។
- ត្រូវកូរជីរៀងរាល់ថ្ងៃ មួយថ្ងៃកូរពីរដង ។ ក្នុងមួយដងកូរឱ្យបានប្រហែលប្រាំនាទី ហើយកូរបង្វិលទៅបង្វិលមក ។ ការកូរនេះនាំឱ្យខ្យល់អុកស៊ីសែន ($O_2$) ចូលក្នុងទឹកដើម្បីបង្កលក្ខខណ្ឌឱ្យមីក្រូសារពាង្គកាយដែលរស់នៅត្រូវការអុកស៊ីសែន ($O_2$) មានសកម្មភាពខ្លាំង ។ បើយើងមិនកូរជីនេះទេនោះនឹងសម្បូរដោយមេរោគមិនត្រូវការខ្យល់ ។

- រយៈពេលបីអាទិត្យ ជីលែងមានក្លិនស្អុយ ។ យើងអាចប្រើវាបាន ។ ជីនេះអាចរក្សាទុកបានមួយខែទៀត តែត្រូវទុកក្នុងម្លប់ ។ ជៀសវាងកុំបន្ថែមវត្ថុធាតុដើម ត្រូវប្រើវាឱ្យអស់ហើយធ្វើថ្មីម្តងទៀត ។

## គ. របៀបស្រោច

- ជី 1ℓ សម្រាប់ស្រោចលើផ្ទៃដី $1m^2$
- លាយជីជាមួយទឹកធម្មតាក្នុងចំណុះស្មើគ្នាសម្រាប់ស្រោចលើដំណាំផ្ទាល់ក្នុងមួយសប្តាហ៍ម្តងៗ ។
- ស្រោចពី 2 - 3 ដងក្នុងមួយសប្តាហ៍ចំពោះដំណាំដែលជួបបញ្ហាជីជាតិខ្លាំង ។
- ដំណាក់កាលសំខាន់សម្រាប់ប្រើជីទឹកមាន :
  - ពេលកូនដំណាំកំពុងលូតលាស់
  - មុនពេលដំណាំចេញផ្កា
  - ពេលដំណាំលេចចេញរោគសញ្ញាប្លែកៗ ។ ***ឧទាហរណ៍*** ស្លឹកប្តូរពណ៌ឬដំណាំបង្ហាញរោគសញ្ញាខ្វះជីជាតិ ។

## 4. សន្និដ្ឋាន

តាមរយៈការពិសោធនេះ តើអ្នកយល់ឃើញថាជីកំប៉ុស្តគោកនិងជីកំប៉ុស្តទឹក មួយណាងាយធ្វើជាងគេ?

មេរៀនទី

# 2 ការបង្កាត់

**ចប់មេរៀននេះ សិស្សអាច**

- ❒ កំណត់និយមន័យនៃពាក្យបង្កាត់
- ❒ រៀបរាប់ពីរបៀបបង្កាត់ផ្សេងៗលើរុក្ខជាតិ
- ❒ អនុវត្តការបង្កាត់ដោយរបៀបតមែក ។

ការចិញ្ចឹមសត្វមួយចំនួនឬការដាំបន្លែ ផ្លែឈើជាពិសេសអង្ករដែលលក់នៅទីផ្សារសព្វថ្ងៃភាគច្រើនវាជាលទ្ធផលនៃការបង្កាត់ ។ *ឧទាហរណ៍* អង្ករនាងមិញ ផ្កាខ្ញី សុមាលី ដកម្លិះ ជាដើម ។ រូបភាពទី 2.1 នេះបង្ហាញពីពូជស្រូវផ្សេងៗដែលមានលក់នៅទីផ្សារ ។



*រូបទី2.1 : ពូជអង្ករផ្សេងៗ*

## 1. និយមន័យ

ការបង្កាត់ជាលំនាំនៃការបន្តពូជតាមរបៀបជម្រើស ដើម្បីបង្កើនចំនួនកូនចៅជំនាន់ក្រោយឱ្យបានកើនឡើងតាមតម្រូវការ ព្រមទាំងរក្សាទុកនូវលក្ខណៈសម្បត្តិនិងគុណភាពរបស់រុក្ខជាតិនិងសត្វបានល្អ ។ មិនតែប៉ុណ្ណោះថែមទាំងធ្វើឱ្យពូជកាន់តែល្អប្រសើរជាងមុនទៀត ។

ពូជសត្វស្រុកនិងរុក្ខជាតិដាំទាំងអស់បានបង្កើតឡើងដោយមនុស្សតាមរបៀបជម្រើសនិមិត្តដែលប្រព្រឹត្តទៅអស់រយៈពេលច្រើនពាន់ឆ្នាំមកហើយ ។ មនុស្សបានរក្សាពូជល្អទុកសម្រាប់ដាំបន្តទៀត ហើយយកពូជអាក្រក់ធ្វើជាអាហារ ។ ពីជំនាន់មួយទៅជំនាន់មួយ ការងារបែបនេះចេះតែបន្តជានិច្ចរហូតដល់មនុស្សបានស្រាវជ្រាវរកឃើញនូវច្បាប់តំណពូជនិងបម្រែបម្រួល ។ ក្រោយមក មនុស្សមានលទ្ធភាពកែប្រែទិសដៅនៃដំណើរជីវិតរបស់រុក្ខជាតិនិងសត្វហើយជ្រើសរើសដើម្បីផលិតបែបសត្វស្រុក ព្រមទាំងរុក្ខជាតិដាំប្រកបដោយទិន្នផលខ្ពស់ដែលបង្កើតបានជាបដិវត្តបៃតងល្បីល្បាញនៅឆ្នាំ 1970 ។

# 2. ការបង្កាត់រុក្ខជាតិ

ការបង្កាត់អាចកើតឡើងរវាងឯកត្តៈនៃពូជតែមួយ ដើម្បីរក្សានូវលក្ខណៈដែលគេចង់បាននៅជំនាន់ក្រោយឬរវាងពូជផ្សេងៗពីគ្នាក្នុងប្រភេទតែមួយ ដើម្បីបង្កើតបម្រែបម្រួលខ្លាំងព្រមទាំងធ្វើឱ្យមានលក្ខណៈថ្មីៗ កាន់តែច្រើនឡើង ។

## 2.1 ការបង្កាត់ដោយប្រើភេទ

ការបង្កាត់ដោយប្រើភេទមានពីរបែប ។ ចំពោះរុក្ខជាតិខ្លះ គ្រាប់លំអងត្រូវផ្ទេរពីថ្នោកលំអងទៅស្ទិចម៉ាតនៃផ្កាតែមួយ ។ ដំណើរនេះហៅថា **ស្វ័យដំណើរលំអង** ។ នៅពេលគ្រាប់លំអងរបស់ផ្កានៃរុក្ខជាតិមួយធ្លាក់លើស្ទិចម៉ាតរបស់ផ្កានៃរុក្ខជាតិផ្សេងទៀត ហៅថា **ដំណើរលំអងកាត់** ។ ស្វ័យដំណើរលំអងអាចមានតែនៅលើផ្កាខ្លះ ប៉ុន្តែផ្កាខ្លះទៀតមិនអាចកើតមានស្វ័យដំណើរលំអងនេះទេ ។




***រូបទី2.2 : វិធីបង្កាត់ពូជរុក្ខជាតិ***

ដើម្បីបង្កាត់ពូជរុក្ខជាតិដែលគេចង់បាន អ្នកបង្កាត់ច្រើនធ្វើនៅលើរុក្ខជាតិពីរផ្សេងគ្នា ដោយរុក្ខជាតិទាំងពីរនោះមានលក្ខណៈប្រសើរខុសគ្នា ។ រូបភាពទី 2.2 បង្ហាញពីវិធីបង្កាត់នេះ ។ ដំបូងដើម្បីការពារកុំឱ្យមានស្វ័យដំណើរលំអង អ្នកត្រូវដកយកថ្នោកលំអង (គ្រាប់លំអង) ចេញពីផ្កាទី 1 ។ បន្ទាប់មកអ្នកត្រូវប្រើជក់ ដើម្បីផ្តិតយកគ្រាប់លំអងរបស់ផ្កាមួយផ្សេងទៀត (ផ្កាទី 2) ហើយយកគ្រាប់លំអងនេះទៅដាក់នៅលើស្ទិចម៉ាតរបស់ផ្កាទី 1 ។ *ឧទាហរណ៍* គេបង្កាត់ពូជប៉េងប៉ោះពីរបែបជាមួយគ្នា ។ ពូជមេផ្លែក្រហមរលោង គ្រាប់ច្រើននិងពូជបាពណ៌មិនល្អ សាច់ច្រើន ។ លក្ខណៈនៃសន្តានក្រោយ ផ្លែពណ៌ក្រហមស្រស់និងសាច់ច្រើន ។ តែការបង្កាត់នេះបានតែនៅជំនាន់ $F_1$ ទេ ។ ប្រសិនបើគេបង្កាត់ជំនាន់ $F_1$ ជាមួយគ្នាតទៀតនោះនឹងមានបម្រែបម្រួលហើយលេចចេញនូវលក្ខណៈអាក្រក់ ។

(ពណ៌ស្រស់ គ្រាប់ច្រើន)ពូជមេ ពូជបា (ពណ៌មិនស្រស់ សាច់ច្រើន)

$F_1$ (ពណ៌ស្រស់ សាច់ច្រើន)

## 2.2 ការបង្កាត់ដោយមិនប្រើភេទ

ចំពោះរុក្ខជាតិដុះដាលដោយឥតគ្រាប់ ថ្វីបើវាជាពូជមិនសុទ្ធ ប៉ុន្តែគេអាចរក្សាលក្ខណៈទាំងអស់របស់វា ដូចពូជដើមនិងបង្កើនចំនួនរុក្ខជាតិនោះ ប្រសិនបើវាមានលក្ខណៈដែលគេចង់បាន ។ ការបង្កាត់ដោយមិនប្រើភេទមានការសាកមែក ការភ្ជាប់ភ្នែក ការតដើម ការភ្ជាប់មែក ។ វិធីបង្កាត់បែបនេះមានភាពងាយស្រួលជាងវិធីបង្កាត់ដោយប្រើភេទ ហើយប្រើរយៈពេលខ្លីនិងទទួលផលបានឆាប់រហ័ស ។ ប្រជាជនយើងនិយមអនុវត្តការបង្កាត់បែបនេះ ដើម្បីបង្កើនចំនួនរុក្ខជាតិទៅតាមតម្រូវការនៃទីផ្សារ ។ រុក្ខជាតិទាំងអស់នោះភាគច្រើនជាប្រភេទរុក្ខជាតិផ្កាដាំលំអនិងរុក្ខជាតិស៊ីផ្លែមួយចំនួន ។

### ក. ការសាកមែក

ការសាកមែកជាការធ្វើឱ្យមែករុក្ខជាតិមានដុះឫសក្នុងពេលដែលមែកនោះនៅជាប់នឹងដើមមេ ។ ពេលមែកដុះឫសល្អហើយ គេកាត់វាចេញពីដើមមេ ហើយយកទៅផ្សាំមុននិងដាំឬយកទៅដាំតែម្តងក៏បានដែរ ។

ចំពោះការសាកមែកគេច្រើនធ្វើលើដើមផ្កាកុលាប ក្រូចឆ្មារ ក្រូចសើច ហើយទទួលបានពូជល្អដូចពូជដើមមេ ។



រូបទី2.3 : ការសាកមែក

### ខ. ការភ្ជាប់ភ្នែក




រូបទី2.4 : ការភ្ជាប់ភ្នែក

ការភ្ជាប់ភ្នែកជាការនាំយកភ្នែករបស់ដើមពូជល្អទៅភ្ជាប់ជាមួយដើមមេដែលជារុក្ខជាតិប្រភេទដូចគ្នា ។ ពេលណាភ្នែករបស់ដើមពូជល្អលូតលាស់ចេញជាមែក ទើបកាត់ផ្នែកខាងចុងនៃដើមមេចោល ។

ចំពោះការភ្ជាប់ភ្នែក គេច្រើនធ្វើលើដើមកុលាប ពុទ្រា ក្រូចពោធិ៍សាត់ ហើយទទួលបានផលជាផ្លែឬផ្កាច្រើនពូជនៅលើដើមតែមួយ ។

## គ. ការភ្ជាប់ដើម

ការផ្លាស់ចុងត្រួយរបស់ដើមមេឱ្យទៅជាចុងត្រួយរបស់ពូជល្អ ដែលមានភ្នែកច្រើនមកភ្ជាប់និងដើមមេ ។ ការភ្ជាប់នេះត្រូវធ្វើឱ្យសាច់ភ្លាសនៃចុងត្រួយពូជល្អនិងដើមមេដែលមានប្រភេទដូចគ្នាផ្សារភ្ជាប់គ្នា។ ក្រោយមកវាលូតលាស់ដូចជា ដើមរុក្ខជាតិតែមួយ ។

ចំពោះការភ្ជាប់ដើមគេច្រើនធ្វើលើដើមកុលាប ព្រូទ្រា ស្វាយ ហើយទទួលបានផលផ្លែឬផ្ការបស់ពូជល្អ ។



រូបទី25 : ការភ្ជាប់ដើម

## ឃ. ការភ្ជាប់មែក




រូបទី25 :ការភ្ជាប់មែក

ការនាំយកដើមដែលបានមកពីការបណ្តុះគ្រាប់ពូជ(សម្រាប់ធ្វើជាដើមទម្រ) ដោយកាត់ចុងត្រួយរបស់វាចោល ហើយគេយកទៅភ្ជាប់ជាមួយមែកដើមពូជល្អនៃប្រភេទដូចគ្នា ។ រយៈពេលពី30ទៅ 40ថ្ងៃ ស្នាមតភ្ជាប់គ្នាជិតបានល្អហើយ ទើបគេកាត់ចុងត្រួយមែកពូជល្អក្រោមកន្លែងតល់មែកផ្តោបនោះចេញពីដើមមេ ។ បន្ទាប់មក គេយកវាទៅដាំបន្តទៀត ។

## 3. អត្ថប្រយោជន៍នៃការបង្កាត់រុក្ខជាតិ

បច្ចុប្បន្ននេះ គេយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការបង្កាត់រុក្ខជាតិដោយប្រើភេទនិងដោយមិនប្រើភេទទេ ។ ការបង្កាត់ទាំងនេះផ្តល់នូវផលប្រយោជន៍ដូចតទៅ

- បង្កើតនូវលក្ខណៈថ្មីៗដែលគេចង់បាន
- រក្សាពូជល្អឱ្យនៅគង់វង្ស
- បង្កើនគុណភាពនិងទិន្នផលនៃពូជរុក្ខជាតិ
- បង្កើននូវភាពធន់របស់រុក្ខជាតិទៅនឹងបម្រែបម្រួលបរិស្ថាន
- ទប់ទល់នឹងជំងឺផ្សេងៗរបស់រុក្ខជាតិដែលបណ្តាលពីវីរុស បាក់តេរី ឬផ្សិត
- បង្កើននូវភាពធន់របស់រុក្ខជាតិទៅនឹងសត្វចង្រៃ ។

## មេរៀនសង្ខេប

- ការបង្កាត់ជាលំនាំនៃការបន្តពូជតាមរបៀបជម្រើស ដើម្បីបង្កើនចំនួនកូនចៅជំនាន់ក្រោយឱ្យបានច្រើនទៅតាមតម្រូវការ ព្រមទាំងរក្សាទុកនូវលក្ខណៈគុណសម្បត្តិនិងគុណភាពរបស់រុក្ខជាតិនិងសត្វឱ្យបានល្អ ។ មិនតែប៉ុណ្ណោះធ្វើឱ្យពូជកាន់តែល្អប្រសើរជាងមុន ។
- វិធីបង្កាត់រុក្ខជាតិមានពីរយ៉ាងគឺ ការបង្កាត់ដោយប្រើភេទនិងការបង្កាត់ដោយមិនប្រើភេទ ។ ការបង្កាត់ដោយប្រើភេទមានដំណើរលំអងកាត់និងស្វ័យដំណើរលំអង ។ ការបង្កាត់ដោយមិនប្រើភេទមានការសាកមែក ការភ្ជាប់ភ្នែក ការភ្ជាប់ដើម និងការភ្ជាប់មែក ។

## សំណួរនិងលំហាត់

1. ដូចម្ដេចហៅថាការបង្កាត់ ?
2. តើការបង្កាត់ដោយប្រើភេទមានអ្វីខ្លះ ?
3. តើការបង្កាត់ដោយមិនប្រើភេទមានអ្វីខ្លះ ?

## ពិសោធន៍ : ការបន្តពូជរុក្ខជាតិដោយវិធីតមែក

### 1. វត្ថុបំណង

អនុវត្តការតមែករបស់ដើមកុលាប ។

### 2. សម្ភារៈ

កាំបិតតូច ប្លាស្ទិចឬកំណាត់កៅស៊ូ ដើមផ្កាកុលាបពីរដើមដែលមានពូជខុសគ្នា ក្រដាសកាតុងក្រាស់សម្រាប់កត់ឈ្មោះពូជ ខែ ឆ្នាំ និងកន្លែងតមែក ។

### 3. ដំណើរការ

#### ក. របៀបជ្រើសរើស

- ការជ្រើសរើសដើមទម្រសម្រាប់តមែក ។
  - ដើមរឹងប៉ុងល្អ គ្មានជំងឺ និងសត្វល្អិតចង្រៃមកយាយី ។
  - អាយុមិនចាស់ឬមិនខ្ចីពេក ។

- ដើមមានទំហំប្រហាក់ប្រហែលគ្នានិងមែកពូជល្អឬមានទំហំប៉ុនគ្នាកាន់តែប្រសើរ ។

• ការជ្រើសរើសមែកពូជល្អសម្រាប់តមែក

- មែកត្រង់ រឹងប៉ឹង និងលូតលាស់ល្អ ។
- ជ្រើសរើសចុងត្រួយឱ្យមានទំហំពាក់កណ្ដាលនៃគល់របស់មែក ព្រោះចុងត្រួយលូតលាស់លឿនជាងគល់មែក ។
- មែកមានភ្នែកត្រួយឬភ្នែកខាងរឹងប៉ឹង ហើយលេចចេញពន្លកត្រួយឡើងច្បាស់ ។
- មានទំហំប្រហាក់ប្រហែលឬទំហំប៉ុនដើមទម្រ ។

## ១. របៀបធ្វើ




- ប្រើកាំបិតមុត ដើម្បីចិតមែកដើមទម្ររាងជាឡូហ៍ដែលមានប្រវែងប្រហែលពីរធ្នាប់ ។
- ត្រៀមត្រួយនៃមែកពូជល្អ (ពូជដែលចង់បាន) ដោយក្ដិចស្លឹកចេញ ។ ប្រើកាំបិតមុតចិតមែកបញ្ឆិតចុះឱ្យសមល្មមជាមួយស្នាមចិតរបស់ដើមទម្រ ។
- យកត្រួយពូជល្អមកស៊កក្នុងដើមទម្រដែលត្រៀមជាស្រេចនោះ ។ ក្នុងពេលធ្វើគួរត្រូវចៀសវាងពីការប៉ះទង្គិចឬកកិតដែលធ្វើឱ្យខូចនិងរលាត់មុខកាត់ ។ លក្ខណៈទាំងនេះអាចធ្វើឱ្យមុខកាត់ទាំងពីរជាប់គ្នាមិនបានល្អ ។
- បន្ទាប់ពីស៊កត្រួយហើយ ប្រើប្លាស្ទិចរុំឱ្យណែន ។ ត្រូវរុំពីក្រោមឡើងលើ ដើម្បីការពារកុំឱ្យទឹកចូលដែលអាចធ្វើឱ្យខូចខាតបាន ។ ពី 30 ទៅ45 ថ្ងៃ បើស្នាមតភ្ជាប់រវាងមែកពូជល្អនិងដើមទម្របានល្អហើយ ទើបគេស្រាយប្លាស្ទិចនោះចេញ ។

## 4. សន្និដ្ឋាន

តាមរយៈពិសោធន៍នេះ តើអ្នកសង្កេតឃើញថា ការភ្ជាប់មែកមានសារៈសំខាន់ដូចម្ដេច?

## សំណួរនិងលំហាត់ជំពូក5

I. ចូរគូសសញ្ញា ( ✓ ) ក្នុងប្រអប់មុខចម្លើយត្រឹមត្រូវ

1. លក្ខណៈមិនមែនជីធម្មជាតិគឺ

☐ក. ជីមានសំណើម ☐ខ. ជីមានក្លិនរបស់រុក្ខជាតិនិងសត្វរលួយ

☐គ. សាច់ជីល្អិតម៉ដ្ឋ ☐ឃ. ជីមានពណ៌ត្នោតស្ទើរខ្មៅ ។

2. ការបង្កាត់រុក្ខជាតិដោយប្រើភេទគឺ

☐ក. ការសាកមែក ☐ខ. ការភ្ជាប់មែក

☐គ. ការភ្ជាប់ភ្នែក ☐ឃ. ការបណ្ដុះគ្រាប់ ។

3. តើគេប្រើផ្នែកណារបស់រុក្ខជាតិដើម្បីសាកមែក ?

☐ក. ភ្នែក ☐ខ. ស្លឹក

☐គ. មែក ☐ឃ. គ្រាប់ ។

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ជីអាចម៍ជន្លេន ជីស្រស់ជា .............. ។

2. ជី....... ផលិតឡើងពីថ្មរ៉ែ ។

3. ជីដែលបានពីការរលួយនៃស្លឹករុក្ខជាតិ លាមកសត្វ និងកាកសំណល់ផ្ទះបាយជា ..... ។

4. ការធ្វើឱ្យមែករុក្ខជាតិដុះឫសក្នុងពេលភ្ជាប់និងដើមមេហៅថា ............ ។

5. ការយកភ្នែកដើមពូជល្អ ទៅភ្ជាប់និងដើមមួយផ្សេងទៀតហៅថា ........... ។

6. ការប្ដូរចុងត្រួយរបស់ដើមមួយ ដោយចុងត្រួយនៃដើមពូជល្អជា ............ ។

7. ការផ្ទេរគ្រាប់លំអង ....... ពីល្អោកលំអងទៅស្ទិចម៉ាតនៃផ្កាតែមួយហៅថា ......... ។

III. ចូរឆ្លើយសំណួរ

1. តើជីគីមីពិតជាល្អត្រឹមត្រូវសម្រាប់ជីស្រែឬចម្ការឬទេ ?

2. ហេតុអ្វីបានជាជីកំប៉ុស្តជួយឱ្យដំណាំលូតលាស់បានល្អជាងការប្រើជីលាមកសត្វឬជីស្រស់តែមួយមុខ?

3. ដើម្បីរក្សាពូជរុក្ខជាតិមិនសុទ្ធមួយឱ្យដូចពូជដើម តើគេត្រូវធ្វើដូចម្ដេច ?

# បទានុក្រម

| | |
|---|---|
| កាម៉ែតូភីត | សារពាង្គកាយរុក្ខជាតិដែលដុះចេញពីស្ប៉ៃ ហើយផលិតកាម៉ែតទាំងពីរភេទ ឬកាម៉ែតភេទណាមួយ ។<br>*ឧទាហរណ៍* ដើមស្លែ ជាកាម៉ែតូភីត ។ |
| កូទីឡេដុង | ស្លែបអំប្រីយ៉ុងក្នុងគ្រាប់រុក្ខជាតិដែលផ្តល់អាហារដល់កូនរុក្ខជាតិ ។ |
| ក្លរ៉ូប្លាស | ធាតុកោសិការុក្ខជាតិដែលផ្ទុកជាតិពណ៌(ក្លរ៉ូភីល)និងជាកន្លែងធ្វើរស្មីសំយោគ ។ |
| ខួរឆ្អឹង | ជាលិកានៅក្នុងប្រហោងកណ្តាលនៃឆ្អឹងមួយចំនួនដែលផលិតកោសិកាឈាមនិងស្តុកខ្លាញ់លើស ។ |
| គីទីន | ប៉ូលីសាក់ការីតដែលកើតឡើងពីគ្លុយកូសជាច្រើន ហើយទម្រង់របស់វាដូចគ្នាទៅនឹងសែលុយឡូស ។ វាបង្កើតជាគ្រោងឆ្អឹងក្រៅ (សំបក ស្នូក)របស់ឧរង្គសត្វ គ្រុយស្តាសេ និងអាកត្រូប៉ូត ។ |
| គីស | ទម្រង់រាងដូចថង់ដែលមានភ្នាសព័ទ្ធជុំវិញសារពាង្គកាយមួយ (ស្ថិតក្នុងវគ្គសំងំ) ។ |
| គុយទីន | សារធាតុក្រមួន នៅក្នុងសំណើផ្ទុកនូវអាស៊ីតខ្លាញ់និងអ៊ីដ្រុកស៊ីតដែលភ្ជាប់ជាមួយគ្នាក្នុងលំដាប់តម្រៀបមួយសាំញ៉ាំ ។ |
| គុយទីគុល | សារធាតុក្រមួនដែលគ្របពីលើអេពីឌែមរបស់ស្លឹកនិងរបស់ដើមរុក្ខជាតិភាគច្រើន ។ ភ្នាសស្ថិតស្ថិតនៅផ្នែកខាងក្រៅនៃសាពាង្គកាយដង្កូវបរាសិតខ្លួនសំប៉ែត ដែលការពារទប់ទល់នឹងសកម្មភាពរំលាយនៃធ្នូលរបស់វា ។ |
| គ្លីកូសែន | គ្លុយស៊ីតដែលកើតឡើងពីម៉ូលេគុលគ្លុយកូសជាច្រើន ។ |
| គ្លុយស៊ីត | ម៉ូលេគុលសរីរាង្គដែលកើតឡើងពីកាបូន អ៊ីដ្រូសែននិងអុកស៊ីសែន និងមានរូបមន្ត ($C_6H_{12}O_6$) ។<br>*ឧទាហរណ៍* អាមីដុង គ្លីកូសែន . . . ។ |

| | |
|---|---|
| ជាលិកា | កោសិកាដូចគ្នាមួយក្រុមដែលធ្វើការជាមួយគ្នា ដើម្បីបំពេញមុខងាររួមមួយ ។ *ឧទាហរណ៍* ជាលិកាសាច់ដុំ ជាលិកាអេពីតែម ។ |
| ជាលិកាសន្ធាន | ក្រុមជាលិកាឯកទេសដែលមាននាទីភ្ជាប់និងទ្រទ្រង់ផ្នែកផ្សេងៗនៃសារពាង្គកាយ ។ |
| ជើងបញ្ឆោត | ភាគលយនៃស៊ីតូប្លាស(ជាបណ្ដោះអាសន្ន)ដើម្បីចាប់អាហារឬផ្លាស់ទី ។ |
| ដង្ហើមកោសិកា | ដំណើរការបំបែកម៉ូលេគុលអាហារ តាមរយៈការធ្វើអុកស៊ីតកម្មនៅក្នុងមីតូកុងទ្រី ដើម្បីផលិតថាមពលគីមីដែលកោសិកាអាចប្រើប្រាស់បាន ។ |
| ដីបាស | ដីមានជាតិប្រៃ ។ ដីប្រភេទនេះរុក្ខជាតិភាគច្រើនមិនសូវដុះលូតលាស់បានល្អទេ ។ |
| ដីអាស៊ីត | ប្រភេទដីមានជាតិជូ ។ ដំណាំភាគច្រើនមិនសូវដុះលូតលាស់ល្អលើដីប្រភេទនេះទេ ។ |
| ដីល្អ | ប្រភេទដីមានជីជាតិដែលមានមីក្រូសារពាង្គកាយរស់នៅច្រើន ។ ដីប្រភេទនេះ អាចឱ្យដំណាំលូតលាស់បានល្អនិងទទួលបានទិន្នផលខ្ពស់ ។ |
| ធាតុកោសិកា | ទម្រង់ពិសេសដែលស្ថិតនៅក្នុងស៊ីតូប្លាសរបស់កោសិកាមាននាទី ដោយឡែកៗពីគ្នាក្នុងមេតាបូលីសកោសិកា ។<br>*ឧទាហរណ៍* មីតូកុងទ្រី ក្លរ៉ូប្លាស . . . ។ |
| ថាមពល | លទ្ធភាពដែលធ្វើឱ្យសារពាង្គកាយមួយឬអង្គធាតុមួយដំណើរការបាន ។ |
| បរាសិត | ភាវៈរស់ដែលរស់នៅលើឬក្នុងភាវៈរស់មួយទៀតហើយស្រូបយកសារធាតុចិញ្ចឹមពីភាវៈរស់នោះ ។ |
| ប៉េលីគុល | ស្រទាប់ប្រូតេអ៊ីនក្រាស់ព័ទ្ធជុំវិញភ្នាសកោសិការបស់ប្រូទីសមួយចំនួន ។ |
| ប្រដាប់របត់ឈាមបិទ | ប្រដាប់របត់ឈាមដែលឈាមធ្វើចលនាតែក្នុងសរសៃឈាមប៉ុណ្ណោះ ។<br>*ឧទាហរណ៍* ត្រី ជន្លេន បក្សី . . . ។ |

| | |
|---|---|
| ប្រដាប់របត់ឈាមទោល | ដំណើរឈាមរត់មួយជុំគឺ ចេញពីបេះដូងទៅសរីរាង្គហើយត្រឡប់ចូលបេះដូងវិញ ។ |
| ប្រដាប់របត់ឈាមទ្វេ | ដំណើរឈាមរត់ពីរជុំ គឺចេញពីបេះដូងទៅសួត ហើយត្រឡប់ចូលបេះដូងវិញនិងចេញពីបេះដូងទៅសរីរាង្គហើយត្រឡប់ចូលបេះដូងវិញ ។ |
| ផ្កាសែល | សរីរាង្គទោលឆ្មារវែង ហើយចល័តសម្រាប់ប្រើជាសរីរាង្គចលករនៃប្រូតូសូអ៊ែមួយចំនួននិងស្ពែម៉ាតូសូអ៊ីត ។ |
| ភ្នាសស៊ីតូប្លាស | ភ្នាសព័ទ្ធជុំវិញស៊ីតូប្លាសកោសិកា ។ វាមាននាទីក្នុងបណ្ដូររូបធាតុរវាងកោសិកា និងមជ្ឈដ្ឋានខាងក្រៅ ។ |
| មីក្រូសារពាង្គកាយ | សារពាង្គកាយតូចបំផុតដែលមិនអាចមើលឃើញដោយភ្នែកទទេតែគេអាចមើលឃើញដោយមីក្រូទស្សន៍ ។ |
| មេតាបូលីស | សំណុំប្រតិកម្មគីមីទាំងឡាយ នៅក្នុងសារពាង្គកាយរួមមាន ការលូតលាស់ សម្រូបអាហារ សំយោគប្រូតេអ៊ីន ។ បណ្តុំនៃរាល់សកម្មភាពបំបែក (អសមានកម្ម )និងសំយោគម៉ូលេគុល(សមានកម្ម)ដែលប្រព្រឹត្តទៅក្នុងកោសិកាហៅថា មេតាបូលីស ។ |
| រីសូអ៊ីត | ទម្រង់រាងដូចឫសឆ្មារៗដែលមាននាទីភ្ជាប់ដើមទៅនិងដីសម្រាប់ស្រូបយកទឹកនិងសារធាតុចិញ្ចឹម ។ |
| រោមញ័រ | រោមឆ្មារៗដូចសក់របស់ប្រូទីសមួយចំនួន ប្រើសម្រាប់ធ្វើចលនា ។ *ឧទាហរណ៍* ប៉ារ៉ាមេស៊ី ។ |
| វីរុស | ភាគតូចល្អិតបំផុតដែលស្ថិតនៅចន្លោះភាវៈរស់និងភាវៈគ្មានជីវិត ។ |
| សត្វថេរកម្ដៅ | សត្វដែលមានសីតុណ្ហភាពសារពាង្គកាយមិនប្រែប្រួលតាមមជ្ឈដ្ឋានជុំវិញ ។ |
| សត្វអថេរកម្ដៅ | សត្វដែលមានសីតុណ្ហភាពសារពាង្គកាយប្រែប្រួលតាមមជ្ឈដ្ឋានជុំវិញ ។ |
| សត្វទ្វេភេទ | សារពាង្គកាយមានពីរភេទដែលអាចបង្កើតកាម៉ែតញីផងនិងកាម៉ែតឈ្មោលផង ។ |